# របាយការណ៍ផែនទីអង្គការសង្គមស៊ីវិល
# ស្តីពី
# កម្មវិធីអន្តរាគមន៍សម្រាប់វិស័យអប់រំ
## ឆ្នាំ២០២៤ - ២០២៨




## ខែមីនា ឆ្នាំ២០២៤

**គាំទ្រដោយ**

EDUCATION OUTLOUD advocacy & social accountability
GPE Transforming Education
OXFAM DANMARK

**រៀបចំដោយ**

NGO Education Partnership

# មាតិកា


**អក្សរកាត់** 3

**ខ្លឹមសារសង្ខេបប្រតិបត្តិ** ..... 1

**សេចក្តីផ្តើម** ..... 3

១) សាវបាន ..... 3

២) គោលដៅ និងវិសាលភាព ..... 3

៣) វិធីសាស្ត្រ និងដែនកំណត់ ..... 4

I. **ព័ត៌មានអំពីអង្គការសង្គមស៊ីវិល** ..... 5

១) អង្គការសង្គមស៊ីវិលដែលឆ្លើយតប និងប្រភេទ ..... 5

២) កម្មវិធីអង្គការសង្គមស៊ីវិល ..... 5

II. **លទ្ធផលរកឃើញ** ..... 22

១) ការប៉ាន់ប្រមាណគម្រោងថវិកា ..... 22

២) ការស្រាវជ្រាវ/សិក្សា និងសកម្មភាពបណ្តុះបណ្តាលជាក់លាក់ ..... 23

៣) ជំនាញឯកទេស ..... 25

៤) បញ្ហាប្រឈមរបស់NGOsក្នុងការធ្វើផែនទី ..... 26

៥) ការបណ្តុះបណ្តាលដែលមានស្រាប់តាមរយៈNGOs ..... 32

៦) ភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការ ..... 34

៧) យេនឌ័រ និងបរិយាបន្ន ..... 35

៨) យុទ្ធសាស្ត្រតស៊ូមតិរបស់NGOsដែលចូលរួមក្នុងការធ្វើផែនទី ..... 38

III. **សេចក្តីសន្និដ្ឋាន** ..... 39

**ឧបសម្ព័ន្ធ** 1

| អក្សរកាត់ | ឈ្មោះជាភាសាអង់គ្លេស និងខ្មែរ |
|---|---|
| AARJ | Association for Aid and Relief, Japan \| សមាគមសម្រាប់ជំនួយ និងសង្គ្រោះនៃប្រទេសជប៉ុន |
| AOP | Annual Operation Plan \| ផែនការប្រតិបត្តិប្រចាំឆ្នាំ |
| AREDOC | Action for Rural Economic Development of Cambodia \| អង្គការសកម្មភាពដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជនបទកម្ពុជា |
| AusCam | AusCam Freedom Project \| អង្គការសេរីភាពកម្ពុជាអូស្ត្រាលី |
| BK | Bandos Komar Association \| សមាគមន៍បណ្តុះកុមារ |
| BLCP | Buddhist Library Cambodia Project \| អង្គការគម្រោងពុទ្ធិកបណ្ណាល័យកម្ពុជា |
| CARE | CARE Cambodia \| អង្គការឃែរ |
| CCAFO | Cambodian Children's Advocacy Foundation Organization \| អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា |
| CCF | Cambodian Children's Fund \| អង្គការមូលនិធិកុមារកម្ពុជា |
| COCD | Cambodian Organization for Children and Development \| អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ |
| CPRDE | Cambodian Organization for Research Development and Education<br>អង្គការកម្ពុជា ដើម្បីស្រាវជ្រាវ អភិវឌ្ឍន៍ និងអប់រំ |
| CRC-Cambodia | Child Rights Coalition Cambodia \| អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា |
| CRF | Child Rights Foundation Organization \| អង្គការមូលនិធិសិទ្ធិកុមារ (ម.ស.ក.) |
| CSO | Civil Society Organization \| អង្គការសង្គមស៊ីវិល |
| CTOD | Community Training Organization for Development \| អង្គការបណ្តុះបណ្តាលសហគមន៍ដើម្បីអភិវឌ្ឍន៍ |
| DTMT | District Training and Monitoring Team \| ក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក |
| DVVI | DVVI Organization \| អង្គការឌីវីវីអន្តរជាតិ |
| EA | Epic Arts \| អង្គការអេពិកអាត |
| EOL | EDUCATION OUT LOUD |
| ESP | Education Sector Plan \| ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| ESWG | Education Sector Working Group \| ក្រុមការងារវិស័យអប់រំ |
| EYC | Empowering Youth in Cambodia \| អង្គការពង្រឹងយុវជនកម្ពុជា |
| FH-Cambodia | Food for the Hungry Cambodia \| អង្គការអាហារសម្រាប់ជនស្រេកឃ្លានកម្ពុជា |
| GNC | Good Neighbors Cambodia \| អង្គការហ្គូដណេបឺសកម្ពុជា |
| HI | Humanity & Inclusion \| អង្គការជនពិការអន្តរជាតិ |
| ICC | Integral Cooperation Cambodia organization \| អង្គការសហការគ្រប់ជ្រុងជ្រោយដើម្បីកម្ពុជា |
| ISF Cambodia | Indochina Starfish Foundation \| អង្គការផ្កាយសមុទ្រកម្ពុជា |
| JTWG | Joint Technical Working Group \| ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ |
| KCD | Khmer Community Development \| អង្គការខេមរអភិវឌ្ឍន៍សហគមន៍ |
| KNGO | Khmer New Generation Organization \| អង្គការខ្មែរជំនាន់ថ្មី |
| KrY | Krousar Yoeung Association \| សមាគមគ្រួសារយើង |

| | |
|---|---|
| KT | Krousar Thmey Organization \| អង្គការគ្រួសារថ្មី |
| KYA | Khmer Youth Association \| សមាគមយុវនជនខ្មែរ |
| LOC | Lotus Outreach Cambodia \| អង្គការឡូធឹសអៅរីចខេមបូឌា |
| MCC | Mennonite Central Committee |
| MHM | Menstrual Hygiene Management \| ការគ្រប់គ្រងអនាម័យពេលមករដូវ |
| MI | Mith Samlanh \| អង្គការមិត្តសំឡាញ់ |
| MoEYS | Ministry of Education, Youth and Sports |
| NEP | NGO Education Partnership \| ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល |
| NISE | National Institute of Special Education |
| NTFP | Non-Timber Forest Products \| អង្គការអនុផលព្រៃឈើ |
| OCCO | The Orphanage for Cambodian Children Organization \| អង្គការមណ្ឌលកុមារកំព្រាសំរាប់ក្មេងកម្ពុជា |
| OEC | Operation Enfants du Cambridge \| អង្គការប្រតិបត្តការកុមារកម្ពុជា |
| PE&D | Planete Enfants & Développement \| អង្គការPE&D |
| P-ESWG | Provincial Education Sector Working Group \| ក្រុមការងារវិស័យអប់រំថ្នាក់ខេត្ត |
| PLAN | Plan International Cambodia \| អង្គការភ្លែនអន្តរជាតិអន្តរជាតិកម្ពុជា |
| RAO | Rural Aid Organization \| អង្គការជំនួយជនបទ |
| RSO | Rabbit School Organization \| អង្គការសាលារៀនទន្សាយ |
| RTI | Research Triangle Institute \| វិទ្យាស្ថានស្រាវជ្រាវត្រីកោណ |
| RTI-IPEA | Research Triangle Institute -IPEA \| វិទ្យាស្ថានស្រាវជ្រាវត្រីកោណ (IPEA Project) |
| RtR | Room to Read Cambodia \| អង្គការរូមធូរីដកម្ពុជា |
| SCI | Save the Children Cambodia \| អង្គការសង្គ្រោះកុមារកម្ពុជា |
| SCO | Sunshine Cambodia Organization \| អង្គការពន្លឺកម្ពុជា |
| SDP | School Development Plan \| ផែនការអភិវឌ្ឍន៍សាលារៀន |
| SIPAR | SIPAR organization \| អង្គការស៊ីប៉ា |
| SP | Sovann Phoum Organization \| អង្គការសុវណ្ណភូមិ |
| SVC | Save Vulnerable Cambodians \| អង្គការសង្គ្រោះជនងាយរងគ្រោះកម្ពុជា |
| TDSO | Teacher Development Support Organization \| អង្គការគាំទ្រការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន |
| TLC | This Life Cambodia \| អង្គការជីវិតនៅកម្ពុជា |
| UWS | UWS Cambodia \| អង្គការ UWS កម្ពុជា |
| VSO | Voluntary Service Overseas \| អង្គការអ្នកស្ម័គ្រចិត្តបំរើការងារនៅបរទេស |
| VVOB | VVOB Organization \| អង្គការវីវីអូប៊ី |
| WASH | Water, Sanitation, and Hygiene |
| WE | Word Education \| អង្គការអប់រំពិភពលោក |
| WVI | World Vision International-Cambodia \| អង្គការទស្សនៈពិភពលោក |

## ខ្លឹមសារសង្ខេបប្រតិបត្តិ

អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (ហៅកាត់ថា "NEP") ជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល (NGOs)ជាង ៧២ ស្ថាប័ន ដែលធ្វើការលើវិស័យអប់រំ ក្នុងគោលបំណងផ្តល់សិទ្ធិអំណាចដល់អង្គការសង្គមស៊ីវិលលើការអភិវឌ្ឍន៍ និងអនុវត្តគោលនយោបាយអប់រំបរិយាបន្ន និងឆ្លើយតបនឹងយេនឌ័រ។ យើងធ្វើការតស៊ូមតិដើម្បីមានសម្លេងរបស់សង្គមស៊ីវិលនៅក្នុងក្រុមការងារវិស័យអប់រំ (ESWG) និងក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ (JTWG) ដែលជាវេទិកាសន្ទនាគោលនយោបាយអប់រំថ្នាក់ជាតិ។ NEP មានគោលបំណងពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិល ក៏ដូចជាក្រុមបាត់បង់ឱកាសក្នុងសង្គម លើការវិភាគគោលនយោបាយ តាមដានការអនុវត្តផែនការវិស័យអប់រំ Partnership Compact និងថវិកាជាតិ ព្រមទាំងពង្រឹងកិច្ចសន្ទនាគោលនយោបាយ និងការគ្រប់គ្រងចំណេះដឹងតាមរយៈវេទិកានានាដូចជា ធនាគារគោលនយោបាយ កម្មវិធី Telegram និង Google Drive ជាដើម។ យើងក៏ស្វែងរកកិច្ចសហប្រតិបត្តិការជាមួយសម្ព័ន្ធផ្សេងទៀតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកផងដែរ។

របាយការណ៍ផែនទីអង្គការសង្គមស៊ីវិលដែលធ្វើការលើវិស័យអប់រំនេះ បង្ហាញអំពីតួនាទីដ៏សំខាន់របស់អង្គការសង្គមស៊ីវិលខាងវិស័យអប់រំ (CSOs) ក្នុងការផ្សារភ្ជាប់គម្លាតទាំងនេះ។ មានNGOsចំនួនជាង ៥២ បានចូលរួមក្នុងការសិក្សានេះ ដែលបង្ហាញពីការយកចិត្តទុកដាក់លើការជួយដល់កុមារដែលមានតម្រូវការចាំបាច់បំផុត ពោលគឺកុមារមានស្ថានភាពជួបការលំបាក។ ទោះយ៉ាងណា នៅតែមានកង្វល់អំពីបញ្ហាវិសមភាព។ តំបន់ទីក្រុងភាគច្រើនតែងមានធនធានល្អៗ និងគ្រូបង្រៀនមានសមត្ថភាព បើធៀបនឹងសហគមន៍ជនបទ។ កត្តានេះបង្កើតឱ្យមានឱកាសមិនស្មើគ្នា ដែលរារាំងដល់អនាគតរបស់សិស្សានុសិស្សនៅក្នុងតំបន់ដែលទទួលបានសេវាមិនគ្រប់គ្រាន់។

ទីនេះជាពន្លឺនៃស្មារតីសហការរវាងអង្គការសង្គមស៊ីវិលកម្ពុជា។ គេស្វែងរកដំណោះស្រាយតាមរយៈកម្មវិធីអប់រំបណ្តុះបណ្តាលសម្រាប់គ្រូបង្រៀន ដោយផ្តោតលើវិធីសាស្ត្របង្រៀនបែបទំនើប និងសមាហរណកម្មបច្ចេកវិទ្យា។ ក្នុងការអនុវត្តការអប់រំបរិយាបន្នគឺជាអាទិភាពមួយ ដោយធានាថ្នាក់រៀនបំពេញតម្រូវការរបស់សិស្សមកពីមជ្ឈដ្ឋានផ្សេងៗគ្នា។ របាយការណ៍នេះសង្កត់ធ្ងន់លើសារៈសំខាន់នៃការធ្វើការរួមគ្នា។ វេទិកាកិច្ចសហប្រតិបត្តិការដូចជា ក្រុមការងារវិស័យអប់រំខេត្ត (PESWGs) គឺជាបណ្តុំនៃNGOs។ តាមរយៈការចែករំលែកចំណេះដឹង និងធនធាន គេអាចដោះស្រាយបញ្ហាប្រឈមកាន់តែមានប្រសិទ្ធភាព។

កិច្ចការនេះមិនតែងតែងាយស្រួលនោះទេ។ អស្ថិរភាពនយោបាយនៅក្នុងតំបន់ខ្លះបង្កការរំខានដល់គំនិតផ្តួចផ្តើមវិស័យអប់រំ។ ដើម្បីដោះស្រាយបញ្ហានេះ អង្គការសង្គមស៊ីវិល បាននិងកំពុងបង្កើតកម្មវិធីដែលមានភាពបត់បែនបាន ហើយអាចសម្របទៅនឹងការប្រែប្រួលកាលៈទេសៈ។ លើសពីនេះ កិច្ចសហការជាមួយអង្គការស្ថាប័នក្នុងស្រុកផ្តល់នូវការឆ្លុះបញ្ចាំងដ៏មានតម្លៃក្នុងការតម្រង់ទិសបញ្ហាប្រឈមទាំងនេះ។

របាយការណ៍នេះក៏បង្ហាញពីសារៈ**សំខាន់នៃការចូលរួមរបស់អាណាព្យាបាល និងសហគមន៍ផងដែរ។** នៅពេលដែលគ្រប់គ្នាវិនិយោគ នោះវិសាលភាពនៃកម្មវិធីអប់រំនឹងត្រូវបានពង្រីក។ អង្គការសង្គមស៊ីវិលដើរតួនាទីយ៉ាងសំខាន់ ក្នុងការជំរុញឱ្យមានការចូលរួមនេះ។ ការធ្វើផែនទីអង្គការសង្គមស៊ីវិលដែលធ្វើការនៅក្នុងវិស័យអប់រំ នេះបម្រើឱ្យគោល

បំណងដ៏មានសារៈសំខាន់។ វាកំណត់ពីវិស័យដែលអង្គការសង្គមស៊ីវិលអាចចូលរួមចំណែកច្រើនបំផុត បង្កើនប្រសិទ្ធភាពនៃការបែងចែកធនធាន និងផ្តល់នូវការឆ្លុះបញ្ចាំងផ្អែកលើទិន្នន័យសម្រាប់ភាគីពាក់ព័ន្ធទាំងអស់។

របាយការណ៍នេះជាការអំពាវនាវឱ្យអង្គការសង្គមស៊ីវិលផ្សេងទៀត ចូលរួមនៅក្នុងចលនាមួយនេះ។ តាមរយៈការចូលរួមក្នុងគំនិតផ្តួចផ្តើមបង្កើតផែនទីអនាគត កំណត់ឱកាសសម្រាប់កិច្ចសហប្រតិបត្តិការ និងការតស៊ូមតិដើម្បីឱ្យមានការផ្លាស់ប្តូរ គេអាចរួមចំណែកដល់អនាគតដ៏ភ្លឺស្វាងសម្រាប់វិស័យអប់រំនៅក្នុងប្រទេស កម្ពុជា។ តាមរយៈការធ្វើការរួមគ្នា អង្គការសង្គមស៊ីវិលដែលធ្វើការលើវិស័យអប់រំ អាចបង្កើតប្រព័ន្ធអប់រំមួយប្រកបដោយសមធម៌ និងកាន់តែមានប្រសិទ្ធភាព ដោយធានាបានថាកុមារកម្ពុជាទាំងអស់ មានឱកាសទទួលបានភាពជោគជ័យ ដោយមិនគិតពីសាវតា ឬកាលៈទេសៈអ្វីទាំងអស់។

ជាលទ្ធផលនៃការអង្កេត បានបង្ហាញពីរូបភាពវិជ្ជមានជារួម ដែលជាគ្រឹះដ៏រឹងមាំសម្រាប់សមភាពយេនឌ័រ និងការអប់រំបរិយាបន្នក្នុងចំណោមអង្គការស្ថាប័នទាំងនេះ។ ទោះជាយ៉ាងណា វាចាំបាច់ណាស់ដែលត្រូវប្រែក្លាយគោលនយោបាយទៅជាការអនុវត្តជាក់ស្តែង ក៏ដូចជាពង្រឹងការប្រមូល និងប្រើប្រាស់ទិន្នន័យ និងពង្រឹងភាពជាដៃគូស្របតាមចក្ខុវិស័យរួមតែមួយ។ កិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ មានសារៈសំខាន់ណាស់ក្នុងការធានាបានថាសិស្សគ្រប់រូបទទួលបានអត្ថប្រយោជន៍ពីការអប់រំបរិយាបន្ន និងបទពិសោធន៍នៃការអប់រំដែលមានសមធម៌យ៉ាងពិតប្រាកដ។

# សេចក្ដីផ្ដើម

## ១) សារបាន

ក្រសួងអប់រំ យុវជន និងកីឡា (ក្រសួងអ.យ.ក) អនុម័តវដ្តនៃការរៀបចំផែនការ និងគោលនយោបាយជាប្រចាំ ដើម្បីពិនិត្យគោលនយោបាយអប់រំ ផែនការយុទ្ធសាស្ត្រ ថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំ។ ឆ្នាំ២០២៣ នឹងមានការត្រួតពិនិត្យផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងការត្រួតពិនិត្យគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ពាក់កណ្តាលអាណត្តិ។ បន្ទាប់ពីការត្រួតពិនិត្យនេះ នឹងមានការបង្កើតផែនការ យុទ្ធសាស្ត្រវិស័យអប់រំថ្មីឆ្នាំ២០២៤-២០២៨ និងPartnership Compact។ ជាការសំខាន់ ដែលអង្គការសង្គមស៊ីវិលដែលធ្វើការលើវិស័យអប់រំ ត្រូវយល់ដឹងច្បាស់អំពីដំណើរការនេះ មានការត្រៀមលក្ខណៈសម្បត្តិ និងធ្វើការសម្របសម្រួលក្នុងចំណោមអង្គការស្ថាប័នទាំងនោះ ដើម្បីចូលរួមក្នុងដំណើរការនេះ សំដៅធានាថាសំឡេងពីថ្នាក់មូលដ្ឋានត្រូវបានគេស្តាប់នៅក្នុងដំណើរការពិគ្រោះយោបល់។ ភាពចាំបាច់គឺត្រូវមានការចូលរួមជាបន្តបន្ទាប់ជាមួយអង្គការសង្គមស៊ីវិល ដើម្បីនាំយកសំឡេងពីថ្នាក់មូលដ្ឋានតាមរយៈវេទិកាជាយុទ្ធសាស្ត្រដូចជា JTWG ESWG PJTWG និងPESWG។

ការធ្វើផែនទីអង្គការសង្គមស៊ីវិលដែលធ្វើការក្នុងវិស័យអប់រំនេះ មានគោលបំណងបង្កើនចំណេះដឹងរបស់តួអង្គអង្គការសង្គមស៊ីវិលខាងវិស័យអប់រំកាន់តែស៊ីជម្រៅនៅគ្រប់កម្រិត ដើម្បីបានយល់ច្បាស់អំពីក្របខណ្ឌគោលនយោបាយក្នុងវិស័យអប់រំរបស់រដ្ឋាភិបាល និងធ្វើការស្រាវជ្រាវក្នុងស្រុកក្នុងការចងក្រងទិន្នន័យទាំងលើគុណភាព និងបរិមាណនៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីបង្ហាញភស្តុតាងសម្រាប់កិច្ចសន្ទនាគោលនយោបាយប្រកបដោយប្រសិទ្ធភាពនៅគ្រប់កម្រិត។

NEP មានតួនាទីដ៏សំខាន់ក្នុងការសម្របសម្រួលកិច្ចសន្ទនាគោលនយោបាយ កិច្ចខិតខំប្រឹងប្រែងក្នុងការតស៊ូមតិ និងធ្វើជាតំណាងអង្គការសង្គមស៊ីវិលនៅកម្ពុជា។ អង្គការសង្គមស៊ីវិលខាងវិស័យអប់រំ និងក្រុមសន្ទនាគោលនយោបាយបាន និងកំពុងកំណត់បញ្ហាសំខាន់ៗ និងត្រូវការឆ្លើយតបតាមវិស័យក្រោមការសម្របសម្រួល។ តាមរយៈបណ្តាញ និងឥទ្ធិពលដែលចាក់ឫសគល់យ៉ាងជ្រៅរបស់ NEP ក្នុងចំណោមអង្គការសង្គមស៊ីវិលអាចបង្កើនសមត្ថភាពនៅថ្នាក់មូលដ្ឋាន និងសម្របសម្រួលកិច្ចសហប្រតិបត្តិការ ពង្រឹងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលក្នុងស្រុក និងបណ្តាញរបស់ខ្លួនផងដែរ។

## ២) គោលដៅ និងវិសាលភាព

នៅក្នុងក្របខណ្ឌគម្រោង EDUCATION OUT LOUD (EOL) ដែលផ្តល់មូលនិធិដោយ GPE តាមរយៈអង្គការ Oxfam Denmark ដើម្បីដោះស្រាយបញ្ហាដ៏សំខាន់នេះដែលបានរកឃើញនៅក្នុងការវិភាគស្ថានភាព NEPស្នើឡើងនូវគោលដៅទី១៖ ធានាបន្តនិរន្តរភាពក្នុងការនាំយកសំឡេងរបស់ថ្នាក់មូលដ្ឋាន និងសង្គមស៊ីវិលជាមួយនឹងតំណាងថ្នាក់ជាតិក្នុងការអភិវឌ្ឍន៍កម្មវិធី និងគោលនយោបាយអប់រំបរិយាបន្ន និងឆ្លើយតបនឹងយេនឌ័រ។ NEP រំពឹងថានឹងពង្រឹងសមត្ថភាពរបស់អង្គការសង្គមស៊ីវិល និងកែលម្អការគ្រប់គ្រងចំណេះដឹងតាមរយៈការបង្កើតផែនទីគម្លាតសមត្ថភាពរបស់អង្គការសង្គមស៊ីវិល លើកសំណើបណ្តុះបណ្តាល បើកដំណើរការធនាគារគោលនយោបាយ ដើម្បីរក្សាទុក និងចែករំលែកព័ត៌មាន។ លើសពីនេះទៀត NEP បាននិងកំពុងស្វែងរកការសហការរឹងមាំជាមួយសម្ព័ន្ធនៅ

កម្រិតតំបន់។ ពាក់ព័ន្ធនឹងការតស៊ូមតិ NEP ស្នើឡើងនូវគោលដៅទី២៖ បង្កើនការចូលរួមរបស់អង្គការសង្គមស៊ីវិល នៅក្នុងការរៀបចំគោលនយោបាយ និងកិច្ចខិតខំប្រឹងប្រែងតស៊ូមតិរួមគ្នា ដោយជានាការចូលរួមរបស់ NEP កាន់តែមានប្រសិទ្ធភាពនៅក្នុងការរៀបចំគោលនយោបាយអប់រំថ្នាក់ជាតិ និងការតស៊ូមតិ ក៏ដូចជាកិច្ចសន្ទនាគោលនយោបាយ តាមរយៈការកៀរគរអង្គការសង្គមស៊ីវិលដើម្បីផ្តល់ជាតុចូល ផលិតឯកសារវិភាគគោលនយោបាយ រៀបចំសន្និសីទថ្នាក់ជាតិ គាំទ្រការរៀបចំកិច្ចប្រជុំNGOsថ្នាក់ខេត្ត និងក្រុមពាក់ព័ន្ធ និងចូលរួមកិច្ចប្រជុំESWG និង JTWG។ លើសពីនេះទៀត NEP និងសមាជិក នឹងតាមដានយ៉ាងជិតដល់នូវការអនុវត្តផែនការវិស័យអប់រំ និង Partnership Compact ក៏ដូចជាផលិតរបាយការណ៍ឆ្លុះបញ្ចាំង។

NEP ធ្វើការសិក្សាអំពីអង្គការសង្គមស៊ីវិលនេះ ដើម្បីបង្កើតផែនទីកម្មវិធីឆ្នាំ ២០២៤-២០២៨ របស់ អង្គការសង្គមស៊ីវិលដែលកំពុងធ្វើការលើវិស័យអប់រំ។ NEP ចង់ដឹងថា តើអង្គការសង្គមស៊ីវិលមានគម្រោងអនុវត្តអ្វីខ្លះពីឆ្នាំ ២០២៤ ដល់ឆ្នាំ ២០២៨ ដើម្បីលើកកម្ពស់ការងារក្នុងវិស័យអប់រំកាន់តែប្រសើរឡើង ហើយក៏ចង់ដឹងពីធនធានមនុស្ស ធនធានហិរញ្ញវត្ថុ គម្លាតសមត្ថភាពរបស់បុគ្គលិកក្នុងវិស័យអប់រំ យេនឌ័រ និងការអប់រំបរិយាបន្ន។ លទ្ធផលនៃការសិក្សានេះនឹងផ្តល់អត្ថប្រយោជន៍ដល់ NEP ដៃគូរបស់ NEP និងអង្គការសង្គមស៊ីវិល ដើម្បីធ្វើការរួមគ្នាលើកកម្ពស់ការអប់រំនៅកម្ពុជាសម្រាប់ទាំងអស់គ្នា។

## ៣) វិធីសាស្ត្រ និងដែនកំណត់

### ក. វិធីសាស្ត្រ

ព័ត៌មាន និងទិន្នន័យនៅក្នុងរបាយការណ៍នេះ ត្រូវបានប្រមូលតាមរយៈឧបករណ៍អនឡាញ ពោលគឺឧបករណ៍ Kobo ។ ផ្នែកផ្សេងៗ និងកម្រងសំណួរបើក ត្រូវបានបញ្ចូលនៅក្នុងឧបករណ៍នេះ។ កម្រងសំណួរនេះត្រូវបានផ្ញើទៅកាន់អង្គការស្ថាប័នប្រមាណ ៧០ ទាំងអង្គការសមាជិករបស់ NEP និងមិនមែនជាសមាជិករបស់ NEP ហើយក៏បានផ្ញើទៅPESWG ផងដែរក្នុងកំឡុងសប្តាហ៍ទីមួយដល់សប្តាហ៍ទី៤ នៃខែមីនា ឆ្នាំ២០២៤ តាមរយៈអ៊ីម៉ែល និងតេឡេក្រាម។ ជាលទ្ធផល NGOs ចំនួន ៥២ បានចូលរួមក្នុងការធ្វើផែនទីនេះ។ ព័ត៌មាន និងទិន្នន័យដែលប្រមូលបាន ត្រូវបានបែងចែកជាច្រើនផ្នែក៖ អង្គការសង្គមស៊ីវិលដែលចូលរួម និងប្រភេទអង្គការស្ថាប័ន កិច្ចអន្តរាគមន៍ និងគោលដៅ PESWG កម្មវិធីអន្តរាគមន៍ និងគម្រោងថវិកាពីឆ្នាំ ២០២៤-២០២៨ ផែនការសកម្មភាពស្រាវជ្រាវ/សិក្សា ជំនាញឯកទេស និងគម្លាតសមត្ថភាព និងអនុសាសន៍ជាដើម។

### ខ. ដែនកំណត់

ដែនកំណត់នៃការបង្កើតផែនទីអង្គការសង្គមស៊ីវិលតាមប្រព័ន្ធអ៊ីនធឺណិតនេះ គ្របដណ្តប់លើ៖ ១. NGOs មួយចំនួនបានឈប់ដំណើរការ។ ពួកគេបានបង្វែរកម្មវិធីរបស់ខ្លួនទៅវិស័យមួយផ្សេងទៀតក្រៅពីការអប់រំ ហើយមិនអាចបំពេញការអង្កេតបាន។ ទោះយ៉ាងណា ព័ត៌មានទំនាក់ទំនងរបស់ពួកគេនៅតែមានក្នុងបញ្ជីសមាជិក NEP និង ២. NGOsមួយចំនួនមានការប្រឈមនឹងបញ្ហានៃការប្រើប្រាស់ឧបករណ៍អង្កេតអនឡាញ និងការចូលប្រើអ៊ីនធឺណិត ដូច្នេះពួកគេខកខានឱកាសក្នុងការបំពេញ និងបញ្ជូនការអង្កេតនេះ។

របាយការណ៍ផែនទីអង្គការសង្គមស៊ីវិលនេះ មានគោលបំណងបង្ហាញតែសកម្មភាពកម្មវិធីសំខាន់ៗវិស័យគោលដៅ និងក្រុមអ្នកទទួលផល គម្រោងថវិកាទូទៅសម្រាប់ការអនុវត្ត ជំនាញឯកទេស និងគម្លាតសមត្ថភាព និងផែនការ សកម្មភាពស្រាវជ្រាវ និងសិក្សាដែលជាព័ត៌មានសម្រាប់NGOនីមួយៗ ដើម្បីស្វែងរកកិច្ចសហការ ឬធ្វើការរួមគ្នា ប្រសិនបើមានភាពស៊ីសង្វាក់គ្នា ឬសង្គតិភាពជាមួយ អង្គការរបស់ខ្លួនប៉ុណ្ណោះ។ ដោយឡែក របាយការណ៍នេះ មិនតំណាងឱ្យប្រសិទ្ធភាព និងផលប៉ះពាល់នៃកិច្ចអន្តរាគមន៍របស់NGOដែលឆ្លើយតបនោះទេ។ វាក៏មិនតំណាងឱ្យ ប្រទេសជាតិទាំងមូល ឬក៏NGOsទាំងអស់ដែលធ្វើការក្នុងវិស័យអប់រំនៅកម្ពុជាដែរ។

# I. ព័ត៌មានអំពីអង្គការសង្គមស៊ីវិល

## ១) អង្គការសង្គមស៊ីវិលដែលឆ្លើយតប និងប្រភេទ

ក្នុងនាមជាអង្គការសមាជិកភាពក្នុងវិស័យអប់រំ យើងបានប្រមូលផ្តុំទាំងអង្គការជាសមាជិក និងស្ថាប័នដែលមិនមែន ជាសមាជិករបស់យើង ដើម្បីចូលរួមក្នុងការបំពេញការអង្កេតនេះ។ ជាលទ្ធផល មានអង្គការចំនួន ៥២ (ក្នុងនោះ ៣៦ មានមូលដ្ឋាននៅរាជធានីភ្នំពេញ) ដែលរួមមានអង្គការអន្តរជាតិចំនួន២៤ (៤៦.១៥%) អង្គការក្នុងស្រុក ចំនួន២៤ (៤៦.១៥%) សមាគមចំនួន០៣ (៥.៧៧%) និងសម្ព័ន្ធ/អង្គការសមាជិកភាពចំនួន០១ (១.៩២%)។ អង្គការចំនួន៤៧ ក្នុងចំណោម៥២ ជាសមាជិករបស់NEP។ អ្នកឆ្លើយសំណួរជានាយកប្រតិបត្តិ/នាយកប្រចាំប្រទេស (៣២.៦៩%) នាយករង(៥.៧៧%) ប្រធានកម្មវិធី/អ្នកសម្របសម្រួល(២៣.០៨%) ប្រធានគម្រោង(២៣.០៨%) អ្នកសម្របសម្រួលគម្រោង(៧.៦៩%) មន្ត្រីគម្រោង(១.៩២%) និងបុគ្គលិក(៥.៧៧%) ដែល៣៤.៦២% ជាស្ត្រី។

## ២) កម្មវិធីអង្គការសង្គមស៊ីវិល

### ក. ក្រុមការងារអប់រំ

តារាងបង្ហាញពីក្រុមការងារ/អនុវិស័យអប់រំ ដែលNGOsធ្វើការ។ ផ្អែកតាមតួលេខ មានNGOs ច្រើនជាងគេរហូតដល់ ៣២ ធ្វើការក្នុងវិស័យអប់រំបឋមសិក្សា ចំនួន ២២ លើការបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ១៩ លើការអប់រំក្រៅប្រព័ន្ធ ចំនួន ១៨ លើផ្នែកគាំពារ និងអភិវឌ្ឍន៍កុមារតូច(ECCD) ចំនួន ១៧ នៅផ្នែកកម្រិតមធ្យមសិក្សាបឋមភូមិ ចំនួន ១៤ នៅផ្នែកកម្រិតមធ្យមសិក្សាទុតិយភូមិ ចំនួន ១៣ លើផ្នែកការអប់រំពហុភាសា ចំនួន ១៣ លើផ្នែកការគាំទ្រ ស្តង់ដារសាលារៀនគំរូ ចំនួន ១០ លើផ្នែកបណ្តុះបណ្តាលគ្រូបង្រៀន ចំនួន ០៧ លើផ្នែកការអប់រំសម្រាប់ជនពិការ និងការអប់រំពិសេស ចំនួន ០៥ លើផ្នែកវិស័យយុវជន និងកីឡា ចំនួន ០៥ លើផ្នែកកម្រិតឧត្តមសិក្សា និងចំនួន ៧ លើផ្នែកផ្សេងទៀតនៃវិស័យអប់រំ ឧទាហរណ៍ ធ្វើការជាមួយសាលារៀន ធ្វើការជាមួយអ្នកថែទាំ/អាណាព្យាបាល សិស្ស ដើម្បីធានាថាកុមារទទួលបានការអប់រំមត្តេយ្យសិក្សា លើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្ននៃការ បង្រៀនសមាហរណកម្មបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) នៅក្នុងការសិក្សាភាសាអង់គ្លេស ផ្តល់កម្ម វិធីអប់រំSTEM ដល់សិស្ស ផ្តល់ថ្នាក់បំប៉នចាប់ពីថ្នាក់ទី១ ដល់ទី៦ ដើម្បីជួយដល់សិស្សរៀនយឺត ធ្វើសមាហរណកម្ម សិស្សទៅក្នុងប្រព័ន្ធសាលារដ្ឋវិញ និងបន្តជួយគាំទ្ររហូតដល់ពួកគេបញ្ចប់ថ្នាក់វិទ្យាល័យ និងអាចចូលរៀននៅ សាកលវិទ្យាល័យ សហការជាមួយមន្ទីរពេទ្យរដ្ឋ ដើម្បីផ្តល់សេវាថែទាំសុខភាព ការតម្រង់ទិសអាជីពការងារ ឱកាស សហគ្រាសសង្គម ជំនួយលើមធ្យោបាយធ្វើដំណើរ និងអាហារូបករណ៍ និងកសាងប្រព័ន្ធទឹកស្អាតនៅសាលារៀន។

## តារាងទី ១៖ ចំនួនNGOsដែលធ្វើការលើអនុវិស័យអប់រំនីមួយៗ




## ខ. អ្នកទទួលផល

ផ្អែកតាមការធ្វើផែនទីពីNGOsចំនួន ៥២នេះ មានអ្នកទទួលផលគោលដៅពីកិច្ចអន្តរាគមន៍ មានដូចជា៖ ចំនួន៣៦ អង្គការដែលធ្វើការជួយគាំទ្រកុមារក្រីក្រ ចំនួន២៩ ធ្វើការជួយកុមារទូទៅ ចំនួន២៣ ធ្វើការដើម្បីកុមារពិការ ចំនួន ២១ ធ្វើការដើម្បីយុវជនបោះបង់ការសិក្សា ចំនួន១៧ ធ្វើការដើម្បីកុមារបោះបង់ការសិក្សា ចំនួន១៧ ធ្វើការដើម្បីសិស្សបោះបង់ការសិក្សា ចំនួន១៦ ធ្វើការដើម្បីជនជាតិភាគតិច ចំនួន១៣ ធ្វើការដើម្បីកុមារដែលមានតម្រូវការពិសេស ចំនួន១៣ ធ្វើការដើម្បីកុមារចំណាកស្រុក ចំនួន១២ ធ្វើការគាំទ្រតែក្មេងស្រីប៉ុណ្ណោះ ចំនួន១១ ធ្វើការដើម្បីកុមារជនជាតិភាគតិច និងចំនួន០៥ ធ្វើការដើម្បីក្រុមកុមារផ្សេងទៀត រួមទាំងកុមារដល់អាយុចូលរៀនមត្តេយ្យសិក្សា ថ្នាក់សមាហរណកម្មស្ត្រីមានផ្ទៃពោះ និងអ្នកថែទាំកុមារអាយុក្រោម ០៥ ឆ្នាំ បណ្តុះបណ្តាលភាសាអង់គ្លេសដល់គ្រូបង្រៀន និងគ្រូបង្រៀនតាមសហគមន៍ ក្រុមអ្នកស្រឡាញ់ភេទ កុមារតាមរស់នៅ/រកស៊ីតាមចិញ្ចើមថ្នល់ ការអប់រំក្រៅប្រព័ន្ធ និងទណ្ឌិត។

## តារាងទី ២៖ អ្នកទទួលផលគោលដៅពីកិច្ចអន្តរាគមន៍



## គ. ខេត្តដែលអង្គការមិនមែនរដ្ឋាភិបាលធ្វើអន្តរាគមន៍

តាមរយៈNGOsដែលឆ្លើយសំណួរអង្កេតអង្គការទាំងនេះធ្វើប្រតិបត្តិការនៅតាមបណ្តាខេត្តនានា។ NGOsមានវត្តមានច្រើនជាងគេនៅរាជធានីភ្នំពេញ និងខេត្តសៀមរាប ដូចដែលយើងដឹងស្រាប់ហើយថាវាជាទីក្រុងធំ ហើយងាយស្រួលស្វែងរកជនជាន ហេដ្ឋារចនាសម្ព័ន្ធ ស្ថាប័នរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ហើយមានចំនួនតិចបំផុតនៅតាមខេត្តចំនួន ០៥ រួមមាន ខេត្តកោះកុង ឧត្តរមានជ័យ ព្រះសីហនុ កែប និងខេត្តប៉ៃលិន។

### តារាងទី ៣៖ ចំនួនNGOsដែលចូលរួមការអង្កេតសម្រាប់កិច្ចអន្តរាគមន៍តាមខេត្ត (លំអិតNGOក្នុងឧបសម្ព័ន្ធ១)




របាយនៃNGOsខាងវិស័យអប់រំនៅកម្ពុជា ទទួលរងឥទ្ធិពលពីកត្តានានាដូចជា ភាពងាយស្រួលខាងភូមិសាស្ត្រ អាទិភាពនៃការអភិវឌ្ឍន៍ ភាពជាដៃគូក្នុងស្រុកដែលមានស្រាប់ ឱកាសផ្តល់មូលនិធិ តម្រូវការ និងបទប្បញ្ញត្តិរបស់រដ្ឋាភិបាល។ ខេត្តនីមួយៗបង្ហាញពីឱកាស និងបញ្ហាប្រឈមពិសេសផ្សេងៗសម្រាប់NGOs ដែលព្យាយាមនាំមកនូវផលប៉ះពាល់ជាវិជ្ជមាននៅក្នុងប្រទេសកម្ពុជា។

## ឃ. កិច្ចអន្តរាគមន៍របស់ក្រុមការងារ/តាមអនុវិស័យ

គម្រោងកម្មវិធីរបស់NGOsដែលឆ្លើយសំណួរ បានអនុវត្តតាមអនុវិស័យរបស់ក្រសួងអ.យ.ក។ ទោះជាយ៉ាងណា ការបង្កើតផែនទីនេះបើកឱកាសដល់NGOsក្នុងការលើកឡើង និងផ្តល់កម្មវិធី និងសកម្មភាពអន្តរាគមន៍របស់ខ្លួនក្រៅពីអនុវិស័យដែលបានកំណត់ ដើម្បីស្វែងយល់បន្ថែមអំពីអ្វីដែលពួកគេកំពុងធ្វើដូចខាងក្រោម៖

| វិស័យ/ផ្នែកអន្តរាគមន៍ | កម្មវិធី/គម្រោង/សកម្មភាពអន្តរាគមន៍ |
|---|---|
| I. កម្មវិធីគាំពារ និងអភិវឌ្ឍន៍កុមារតូច (ECCD) | |
| កម្មវិធីសិក្សា និងការបណ្តុះបណ្តាល | - គាំទ្រក្រសួងអ.យ.ក ក្នុងការអភិវឌ្ឍន៍ និងអនុវត្តគោលការណ៍ណែនាំ ECCD និងកម្មវិធីសិក្សា<br>- អនុវត្តកម្មវិធីសិក្សាមត្តេយ្យជាតិ(KRKC)និងសម្ភារៈរៀន និងបង្រៀន (TLM) |

| | |
|---|---|
| | - អភិវឌ្ឍសៀវភៅណែនាំ និងគោលការណ៍ណែនាំ ECCD<br>- បណ្តុះបណ្តាល គរុសិស្ស គ្រូបង្រៀន និងគ្រូបង្រៀនសហគមន៍<br>- ពង្រឹងសមត្ថភាពអាណាព្យាបាល និងអ្នកថែទាំ<br>- ជ្រើសរើស និងបណ្តុះបណ្តាលសមាជិកសហគមន៍ជាគ្រូបង្រៀនរបស់ ECCE<br>- ពង្រឹងសមត្ថភាពគ្រូបង្រៀនECCE និងដៃគូ<br>- ពង្រឹងកម្មវិធីសិក្សាតាមកម្រិតថ្នាក់ (ក្នុងការចងក្រងកម្មវិធីសិក្សា)។ |
| ហេដ្ឋារចនាសម្ព័ន្ធ | - បង្កើត និងគាំទ្រសម្ភារបរិក្ខារ ECCE នៅតាមសហគមន៍មូលដ្ឋាន<br>- កសាង និងជួសជុលកែឆ្នៃសម្ភារបរិក្ខារ ECCE តាមសាលារៀន និងសហគមន៍<br>- ផ្តល់សួនកុមារសម្រាប់ការសម្របសម្រួលការចេញចូលECCE។ |
| សុខុមាលភាព និងការអភិវឌ្ឍន៍កុមារ | - ប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអភិវឌ្ឍន៍កុមារ។<br>- ផ្តល់អាហារបំប៉ន (អាហារពេលព្រឹក អាហារសម្រន់ និងទឹកដោះគោ)<br>- លើកកម្ពស់ការអនុវត្តផ្នែកអនាម័យឱ្យបានត្រឹមត្រូវ និងទម្លាប់នាំមកនូវសុខភាពល្អ។ |
| ការចូលរៀន និងសមធម៌ | - ផ្តល់កម្មវិធីសិក្សាពេញមួយថ្ងៃ (ព្រឹកដល់រសៀល)<br>- អភិវឌ្ឍន៍ និងចែកចាយសម្ភាររៀន និងបង្រៀន<br>- ផ្សារភ្ជាប់អាហារូបករណ៍សម្រាប់វត្តមាន ECCE<br>- លើកកម្ពស់សមភាពយេនឌ័រក្នុងការអនុវត្តផ្នែកថែទាំកុមារតាមរយៈការពង្រឹងអង្គភាពគាំពារកុមារខេត្ត និងការចូលរួមរបស់បុរស<br>- ផ្តល់សម្ភារអនាម័យ និងគាំទ្រកម្មវិធីផ្តល់អាហារតាមសាលារៀន<br>- លើកទឹកចិត្តដល់ភាពម្ចាស់ការរបស់សហគមន៍លើសម្ភារបរិក្ខារ ECCE។ |
| ការពិនិត្យតាមដាន និងកិច្ចសហការ | - សហការជាមួយNGOs លើការប្រតិបត្តិល្អៗក្នុងការអនុវត្ត និងពិនិត្យវិធីសាស្ត្របង្រៀនឆ្លើយតបនឹងយេនឌ័រ<br>- ចុះសួរសុខទុក្ខតាមផ្ទះ និងក្រុមគាំទ្រអាណាព្យាបាល<br>- អនុវត្តកម្មវិធីត្រួតពិនិត្យសម្ភារបរិក្ខារ ECCE (តាមដានសាលាមត្តេយ្យសហគមន៍ និងកម្មវិធីត្រួតពិនិត្យ)។ |
| ២. កម្មវិធីអប់រំបឋមសិក្សា | |
| ការបណ្តុះបណ្តាលគ្រូបង្រៀន និងការគ្រប់គ្រងសាលា | - ពង្រឹងសមត្ថភាពគ្រូបង្រៀនលើយុទ្ធសាស្ត្រអប់រំប្រកបដោយនវានុវត្តភាព ដើម្បីពង្រឹងការរៀនសូត្ររបស់កុមារ<br>- ពង្រឹងយន្តការត្រួតពិនិត្យបច្ចេកទេស ដើម្បីលើកកម្ពស់គុណភាពរៀន និងបង្រៀន (DTMT) នៅស្រុកទ្រាំង (២០សាលា)<br>- អនុវត្ត និងគាំទ្រកម្មវិធីប្រឹក្សាគរុកោសល្យរបស់ក្រសួងអ.យ.ក<br>- បណ្តុះបណ្តាលនាយកសាលា គ្រូបង្រៀន និងបណ្ណារក្ស<br>- បណ្តុះបណ្តាលគណៈកម្មការគ្រប់គ្រងសាលារៀន |

| | |
|---|---|
| | - គាំទ្រអធិការកិច្ចសាលា (DTMT)។ |
| ការអប់រំកម្រិតថ្នាក់ដំបូង | - អនុវត្ត និងផ្តល់ប្រឹក្សាគរុកោសល្យកម្មវិធីគណិតវិទ្យាកម្រិតថ្នាក់ដំបូង<br>- បណ្តុះបណ្តាលគ្រូបង្រៀនលើកញ្ចប់សិក្សាកម្រិតថ្នាក់ដំបូង<br>- បណ្តុះបណ្តាលថ្នាក់ដឹកនាំសាលា លើការគ្រប់គ្រងសាលារៀន<br>- អប់រំអ្នកថែទាំលើការរៀនកម្រិតថ្នាក់ដំបូងប្រកបដោយភាពជោគជ័យ<br>- អនុវត្តកម្មវិធី SMILE (២០២២-២០២៦) "ការពង្រឹងគណិតវិទ្យាកម្រិតថ្នាក់ដំបូងតាមរយៈ ការអប់រំបរិយាបន្ន កម្រិតដែលសមស្រប ការអបរំ" ("កម្មវិធី" គួរសរសេរជាអក្សរធំ ប្រសិនបើប្រើភាសាអង់គ្លេសបែបអាមេរិក)<br>- គាំទ្រក្រសួងអ.យ.ក អនុវត្តកញ្ចប់គណិតវិទ្យាកម្រិតថ្នាក់ដំបូង(ថ្នាក់ទី១-៣) នៅក្នុងខេត្តចំនួនបី៖ កែប កំពត និងកំពង់ធំ ដោយសហការជាមួយនាយកដ្ឋានបឋមសិក្សា នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រិតការ និងនាយកដ្ឋានធានាគុណភាពអប់រំ។ |
| ការអប់រំបរិយាបន្ន | - បង្កើតក្រុមការងារអប់រំបរិយាបន្ន និងកសាងសមត្ថភាព<br>- កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានលក្ខណៈងាយស្រួលនៅសាលាគោលដៅ<br>- បណ្តុះបណ្តាលគ្រូបង្រៀន និងរៀបចំសិក្ខាសាលាសម្រាប់សិស្សពិការ<br>- រៀបចំព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹងពីពិការភាពនៅក្នុងសហគមន៍<br>- ធ្វើការស្រាវជ្រាវអំពីស្ថានភាពកុមារពិការ និងផ្តល់ជំនួយតាមការចាំបាច់<br>- ចែករំលែកព័ត៌មាន និងបទពិសោធន៍ជាមួយថ្នាក់ស្រុក/ខេត្ត<br>- បណ្តុះបណ្តាលគ្រូអប់រំពិសេស និងគណៈកម្មាធិការគាំពារពិការភាពឃុំ/សង្កាត់<br>- កែលម្អលទ្ធភាពក្នុងការប្រើប្រាស់សាលារៀន (ផ្លូវសម្រាប់ជនពិការ បង្គន់អនាម័យ)<br>- បង្កើត និងគាំទ្រផែនការសមាហរណកម្មសាលារៀន<br>- បណ្តុះបណ្តាលគ្រូបង្រៀន និងអ្នកជំនាញផ្នែកអប់រំ លើការអប់រំបរិយាបន្ន<br>- កំណត់អត្តសញ្ញាណកុមារមានពិការ ដើម្បីធ្វើការបញ្ជូនទៅរកសេវា<br>- ផ្តល់ជំបូន្មានបច្ចេកទេស ដើម្បីកែលម្អលទ្ធភាពប្រើប្រាស់នានា<br>- ជួយដល់កុមារពិការតាមរយៈសម្ភារសិក្សា ឬឧបករណ៍ជំនួយ<br>- រៀបចំកិច្ចប្រជុំត្រួតពិនិត្យការអនុវត្តគោលនយោបាយ IE។ |
| ការកែលម្អសាលារៀន និងគាំទ្រសិស្ស | - សាងសង់អគារសិក្សា និងបង្គន់អនាម័យ (តាមតម្រូវការ)<br>- កែលម្អអគារសិក្សា ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន<br>- បំពាក់បរិក្ខារទឹកស្អាតនៅតាមសាលារៀន<br>- ផ្តល់សម្ភារបណ្ណាល័យ និងគាំទ្រសកម្មភាពបណ្ណាល័យ<br>- គាំទ្រការប្រើប្រាស់បច្ចេកវិទ្យា ICT សម្រាប់ការអប់រំ<br>- ផ្តល់អាហារូបករណ៍ដល់កុមារងាយរងគ្រោះ<br>- ផ្តល់សម្ភារសិក្សា សម្លៀកបំពាក់ និងរ៉ាប់រងថ្លៃសិក្សា (បើចាំបាច់) |

| | |
|---|---|
| | - កែលម្អអនាម័យសាលារៀន (ទឹកស្អាត និងអនាម័យ)<br>- លើកកម្ពស់ការយល់ដឹងអំពីការបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ និងអនុវត្តវិធានការ ៣ ចំណុច (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ កែច្នៃឡើងវិញ)<br>- អនុវត្តកម្មវិធីសួនបំណិនជីវិតតាមសាលា<br>- ផ្តល់អាហារថ្ងៃត្រង់ដល់សិស្សដែលខ្វះខាត<br>- ផ្តល់សម្ភារសិក្សា សម្ភារកីឡា និងឯកសណ្ឋានសិស្ស<br>- រៀបចំសកម្មភាពកីឡា<br>- ផ្តល់ជូនការលើកទឹកចិត្តជាសាច់ប្រាក់ប្រចាំខែសម្រាប់ការមករៀនទៀងទាត់។<br>- ផ្តល់ប្រាក់ឧបត្ថម្ភ និងមធ្យោបាយធ្វើដំណើរសម្រាប់សិស្សក្នុងឱកាសពិសេស<br>- អនុវត្តកម្មវិធីជំនួយការរៀនសូត្រសម្រាប់សិស្សដែលជួបការលំបាកក្នុងការរៀនសូត្រ<br>- បញ្ចូលសិស្សរៀនបំប៉នទៅក្នុងសាលារដ្ឋ និងបន្តជួយគាំទ្ររហូតដល់ពួកគេបញ្ចប់ថ្នាក់ទី១២ ហើយអាចមានលទ្ធភាពបន្តចូលរៀននៅសាកលវិទ្យាល័យ។ (ស្នើសុំប្តូរពីពាក្យ "បន្ត" ទៅជា "អាចមានលទ្ធភាពបន្ត")<br>- ថ្នាក់ភាសាអង់គ្លេស កុំព្យូទ័រ យូហ្គា របាំប្រពៃណីខ្មែរ បណ្ណាល័យ សិល្បៈ អប់រំកាយ<br>- ផ្តល់សេវាថែទាំសុខភាពនៅតាមសាលា ISF និងសហការជាមួយមន្ទីរពេទ្យរដ្ឋ។ |
| ការចូលរួមរបស់សហគមន៍ និងការសិក្សាពេញមួយជីវិត | - លើកកម្ពស់សិទ្ធិកុមារ ការថែទាំសុខភាព និងការការពារបរិស្ថានក្នុងចំណោមកុមារ អាណាព្យាបាល និងគ្រូបង្រៀន<br>- កសាងសមត្ថភាពគណៈកម្មការសាលារៀន និងគ្រូបង្រៀន<br>- គាំទ្របណ្ណាល័យ និងក្រុមប្រឹក្សា/ក្លឹបកុមារ<br>- ផ្តល់កម្មវិធីមត្តេយ្យសិក្សាកន្លះថ្ងៃបន្ថែមលើសាលារដ្ឋ<br>- ផ្តល់ការអប់រំបំណិនជីវិត បច្ចេកវិទ្យា ICT ភាសាអង់គ្លេស ហិរញ្ញវត្ថុផ្ទាល់ខ្លួន គណិតវិទ្យា ភាសាខ្មែរ កម្មវិធី STEM និងថ្នាក់សិល្បៈ<br>- ផ្តល់ការថែទាំសុខភាពជាប្រចាំដល់សិស្សានុសិស្ស<br>- រៀបចំសកម្មភាពក្រៅ ម៉ោងសិក្សា (ភាសាអង់គ្លេស កុំព្យូទ័រ យូហ្គា របាំប្រពៃណីខ្មែរ សិល្បៈ អប់រំកាយ)<br>- ជំរុញការចុះឈ្មោះចូលរៀន/ចូលរៀនឡើងវិញ តាមរយៈយុទ្ធនាការលើកកម្ពស់ការយល់ដឹង និងអាហារូបករណ៍<br>- គាំទ្រថ្នាក់ចូលរៀនឡើងវិញ ថ្នាក់សមមូល ថ្នាក់អប់រំពហុភាសា និងថ្នាក់ បំប៉នការសិក្សាសម្រាប់កុមារដែលមានអាយុច្រើន សិស្សបោះបង់ការសិក្សា និងកុមារជនជាតិដើមភាគតិច<br>- គាំទ្រកុមារជនជាតិភាគតិចវៀតណាមឱ្យចូលរួមក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធអប់រំ។ |

| | |
|---|---|
| អក្ខរកម្មផ្នែកហិរញ្ញវត្ថុសម្រាប់កុមារ | - ពង្រឹងជំនាញអក្ខរកម្មផ្នែកហិរញ្ញវត្ថុដល់កុមារចំនួន ២,៥០០ នាក់ (៧-១២ឆ្នាំ) នៅតាមសាលាបឋមសិក្សាចំនួន ១០ ក្នុងស្រុកទ្រាំង (ខេត្តតាកែវ)<br>- អនុវត្តកម្រងសកម្មភាពលើកកម្ពស់ការអប់រំអក្ខរកម្មមូលដ្ឋានផ្នែកហិរញ្ញវត្ថុ។(នេះអាចរាប់បញ្ចូលទាំងការបង្កើតសម្ភារអប់រំដូចបានលើកឡើងនៅកន្លែងផ្សេងទៀត)។ |
| ៣. កម្មវិធីអប់រំពិសេស | |
| ការកំណត់អត្តសញ្ញាណ និងការថែទាំកុមារ | - ការសម្រិតសម្រាំងកុមារដើម្បីកំណត់អត្តសញ្ញាណកុមារមានពិការភាព និងមានការអភិវឌ្ឍន៍យឺតយ៉ាវ<br>- ការសម្រិតសម្រាំង MUAC ដើម្បីកំណត់អត្តសញ្ញាណកុមារខ្វះអាហារូបត្ថម្ភ។<br>- ការបណ្តុះបណ្តាលអំពីការថែទាំបំប៉នសម្រាប់ក្រុមអ្នកថែទាំ។<br>- បញ្ជូនកុមារមានពិការភាពទៅទទួលការអប់រំពិសេសផ្អែកតាមតម្រូវការពួកគេ<br>- គាំទ្រកុមារផ្អែកតាមតម្រូវការរបស់ពួកគេ ដូចជាសេវាស្តារនីតិសម្បទា និងសម្ភារ។ |
| ការវាយតម្លៃ និងគាំទ្រការសិក្សា | - វាយតម្លៃ និងផ្តល់អនុសាសន៍លើការអនុវត្តផ្នែកអប់រំពិសេស ជូនក្រសួងអ.យ.ក<br>- បង្កើតបរិយាកាសសិក្សាបរិយាបន្នបន្ថែមទៀត ជួយគាំទ្រសិស្សមានពិការភាពនៅតាមសាលាអប់រំពិសេស និងសាលារៀនបរិយាបន្ន<br>- សហការជាមួយក្រសួងអ.យ.ក តាមរយៈ នាយកដ្ឋានអប់រំពិសេស និងវិទ្យាស្ថានជាតិអប់រំពិសេស ដើម្បីគាំទ្រការអនុវត្តកម្មវិធីនៅសាលាអប់រំពិសេស ដោយទទួលបានការបណ្តុះបណ្តាល ដើម្បីបំពេញតម្រូវការរបស់អ្នកសិក្សាមកពីមជ្ឈដ្ឋានចម្រុះរួមទាំងសិស្សមានពិការភាព និងជនជាននានា ដូចជាការវាយតម្លៃការសិក្សាសម្រាប់សិស្សគថ្លង់កម្រិតថ្នាក់ដំបូង<br>- ផ្តល់ការបណ្តុះបណ្តាលគរុកោសល្យដោយបញ្ចូលម៉ូឌុលណែនាំអំពីUDL (Universal Design for Learning) និងប្រើប្រាស់យុទ្ធសាស្ត្រសមស្របតាមតម្រូវការសិក្សាផ្សេងៗ<br>- ផ្តល់អាហាររូបករណ៍សម្រាប់សេវាបញ្ជូនទៅកាន់សេវាអប់រំ<br>- ធ្វើការជាមួយដៃគូសម្រាប់សិស្សដែលមានតម្រូវការពិសេស (សាលាទន្សាយ) ដើម្បីផ្តល់ការគាំទ្រដល់ពួកគេ។ (ប្តូរពាក្យ "សិស្ស" ទៅជា "ពួកគេ" ដើម្បីឱ្យមានលក្ខណៈកាន់តែរលូន)<br>- បើកដំណើរការថ្នាក់អប់រំពិសេសចំនួន ០៣ ផ្សេងគ្នានៅមជ្ឈមណ្ឌល Epic Arts ដែលផ្តល់ការអប់រំពិសេសដោយឥតគិតថ្លៃដល់កុមារ និងយុវជនដែលមានពិការភាពអាយុចាប់ពី ០៣ ឆ្នាំដល់ ៣៥ ឆ្នាំ។ (ប្តូរពីពាក្យ "បានផ្តល់" ទៅជា "ដែលផ្តល់" ដើម្បីប្រើជាទម្រង់ active voice)<br>- ធ្វើការជាមួយសាលាបឋមសិក្សារដ្ឋគោលដៅនៅក្នុងខេត្តកំពតដើម្បីធ្វើសមាហរណកម្មកុមារមានពិការភាព ទៅក្នុងថ្នាក់សមាហរណកម្ម ហើយក៏ធ្វើការជាមួយសាលារដ្ឋចំនួន០៣ ដែលបើកដំណើរការថ្នាក់អប់រំបរិយាបន្ន ចំនួន ០៣ នៅក្នុងខេត្តកំពត |

| | |
|---|---|
| | - គាំទ្រការរៀនភាសាខ្មែរសម្រាប់កុមារជនជាតិភាគតិចវៀតណាមមុនពួកគេចាប់ផ្តើមចូលរៀននៅសាលារដ្ឋ។ (ប្តូរ ពីពាក្យ "ដល់" ទៅជា "សម្រាប់" និង "ការចាប់ផ្តើម" ទៅជា "ចាប់ផ្តើម" ដើម្បីបង្ហាញពីទម្រង់បច្ចុប្បន្នកាល)<br>- លើកកម្ពស់ និងលើកទឹកចិត្តសិស្សឱ្យចូលរួមក្នុងកម្មវិធីអប់រំពិសេស ដែលអនុវត្តដោយការិយាល័យអប់រំក្រុង/ស្រុក<br>- សម្រាប់កម្មវិធីអប់រំពិសេស យើងរៀបចំកម្មវិធីសិក្សាចម្រុះ និងបើកដំណើរការបណ្ណាល័យទំនើប។ |
| ៤. កម្មវិធីអប់រំពហុភាសា | |
| ជំនួយគ្រូបង្រៀន | - អនុវត្តវគ្គបណ្តុះបណ្តាលគ្រូបង្រៀនឯកទេសផ្នែកអប់រំពហុភាសា និងចូលរួមគាំទ្រការបណ្តុះបណ្តាលគ្រូបង្រៀនពហុភាសា<br>- ពង្រឹងការបង្រៀនរបស់គ្រូបង្រៀន និងចូលរួមក្នុងសិក្ខាសាលាពាក់ព័ន្ធ។ |
| ការគាំទ្រដល់សិស្ស | - គាំទ្រថ្នាក់ចូលរៀនឡើងវិញ ថ្នាក់សមមូល ការអប់រំពហុភាសា និងថ្នាក់ពន្លឿនសម្រាប់កុមារដែលមានអាយុច្រើន កុមារបោះបង់ការសិក្សា និងកុមារជនជាតិដើមភាគតិច<br>- គាំទ្រការរៀនភាសាខ្មែរដល់កុមារជនជាតិ ភាគតិចវៀតណាម មុនពេលចាប់ផ្តើមចូលរៀននៅសាលារដ្ឋ<br>- ផ្តល់ការបង្រៀនភាសាអង់គ្លេសដោយឥតគិតថ្លៃដល់សិស្សប្រមាណ ៣០០ នាក់ក្នុងមួយឆ្នាំ សម្រាប់សិស្សចាប់ពីកម្រិតបឋម ដល់មធ្យមសិក្សាចំណោះទូទៅខ្មែរ និងជនជាតិដើមភាគតិចការ៉ែតនៅតំបន់ដាច់ស្រយាលក្នុងខេត្តរតនគិរី<br>- ផ្តល់ថ្នាក់ភាសាអង់គ្លេសដល់សិស្សចាប់ពីមតេយ្យសិក្សាដល់ថ្នាក់ទី១២<br>- ពង្រឹងសមត្ថភាពភាសាអង់គ្លេសរបស់សិស្សដោយធ្វើសមាហរណកម្មបច្ចេកវិទ្យា ICT ដូចជាការប្រើប្រាស់កម្មវិធី Literacy Planet បណ្ណាល័យសំឡេង ការធ្វើតេស្តតាមអនឡាញ ជាដើម<br>- ឧបត្ថម្ភថ្លៃសិក្សាសម្រាប់សិស្សរៀនភាសាអង់គ្លេស និងចិន។ |
| លើកកម្ពស់ការយល់ដឹងរបស់សហគមន៍ | - លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការអប់រំ ជាពិសេសការអប់រំពហុភាសាដល់គ្រប់ភាគីពាក់ព័ន្ធ។ |
| សម្ភារបរិក្ខារ | - ផ្តល់សម្ភារឧបករណ៍សម្រាប់ការអប់រំពហុភាសាទាំងក្នុង និងក្រៅប្រព័ន្ធ<br>- កសាងសមត្ថភាពអាជ្ញាធរនៅថ្នាក់ខេត្ត ស្រុក និងសាលារៀន លើការអប់រំពហុភាសា និងឆ្លើយតបយេនឌ័រក្នុងការបង្រៀន និងវិធីសាស្ត្រសិស្សមជ្ឈមណ្ឌលបែបបរិយាបន្នការសិក្សាសង្គម និងអារម្មណ៍/ផ្លូវចិត្តនៅកម្រិតបឋមសិក្សា<br>- សាងសង់អគារសិក្សាមត្តេយ្យសហគមន៍ បង្គន់អនាម័យ និងប្រព័ន្ធអនាម័យនៅតាមសាលារៀន |

| | |
|---|---|
| | - ផ្តួចផ្តើម និងគាំទ្របណ្ណាល័យចល័តនៅតាមសាលារៀន។ |
| ការត្រួតពិនិត្យ វាយតម្លៃ និងបង្កើតបណ្តាញ | - ត្រួតពិនិត្យ និងការវាយតម្លៃដំណើរការ<br>- ចូលរួម និងពង្រឹងបណ្តាញអប់រំ។ |
| ៥. កម្មវិធីអប់រំមធ្យមសិក្សាបឋមភូមិ | |
| ការកែលម្អលទ្ធភាពទទួលបានការអប់រំឱ្យកាន់តែប្រសើរឡើង | - ផ្តល់អាហាររូបករណ៍ កសាងសមត្ថភាពក្រុមប្រឹក្សាកុមារ និងលើកកម្ពស់ជំនាញភាពជាអ្នកដឹកនាំ និងគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់កុមារីងាយរងគ្រោះ និងសិស្សដែលមានតម្រូវការចាំបាច់<br>- ផ្តល់ឯកសណ្ឋាន សៀវភៅសិក្សា និងសម្ភារសិក្សា<br>- សាងសង់និងកែលម្អសាលារៀន បង្គន់អនាម័យ និងអនាម័យកាន់តែប្រសើរឡើង<br>- គាំទ្រកម្មវិធីចូលរៀនឡើងវិញ ថ្នាក់សមមូល និងការអប់រំពហុភាសាសម្រាប់ក្រុមដែលជួបការលំបាក រួមទាំងការបង្រៀនភាសាខ្មែរដល់កុមារជនជាតិភាគតិចវៀតណាមមុនពេលពួកគេចាប់ផ្តើមចូលរៀននៅសាលារដ្ឋ<br>- ផ្តល់ថ្នាក់បំប៉នចាប់ពីថ្នាក់ទី១ ដល់ទី៦ និងធ្វើសមាហរណកម្មសិស្សរៀនថ្នាក់បំប៉នទៅក្នុងប្រព័ន្ធសាលារដ្ឋ ជួយគាំទ្រដល់ពួកគេរហូតដល់បញ្ចប់ថ្នាក់ទី១២ និងអាចមានលទ្ធភាពបន្តចូលរៀននៅសាកលវិទ្យាល័យ<br>- ឧបត្ថម្ភថ្លៃសិក្សាសម្រាប់សិស្សរៀនភាសាអង់គ្លេស និងភាសាចិន<br>- ផ្តល់ជូនកម្មវិធីអាហារពេលល្ងាច និងផ្តល់ឱកាសដល់សិស្សានុសិស្សបានចូលរួមក្នុងការងារសហគមន៍<br>- ប្រើប្រាស់ឧបករណ៍ SDP, AOP និងឧបករណ៍វាយតម្លៃសាលារៀនសម្រាប់ធ្វើការបណ្តុះបណ្តាល ផ្តល់ការប្រឹក្សា/ការចុះជួយ និងតាមដាន<br>- អនុវត្តតាមកម្មវិធីសិក្សារបស់សាលារដ្ឋ ខណៈដែលផ្តល់ថ្នាក់បន្ថែមដូចជា ថ្នាក់ភាសាអង់គ្លេស ថ្នាក់កុំព្យូទ័រ ថ្នាក់តន្ត្រី និងថ្នាក់ថែទាំសុខភាព<br>- ធ្វើការដាក់បញ្ចូលការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ ការបណ្តុះបណ្តាលបំណិនជីវិត និងការអប់រំបរិយាបន្នក្នុងដំណើរការរៀបចំកម្មវិធីសិក្សា<br>- គាំទ្រសកម្មភាពក្រៅម៉ោងសិក្សា ដូចជាកីឡា សិល្បៈ ក្លឹបលើកកម្ពស់សិទ្ធិកុមារ ការថែទាំសុខភាព និងបរិស្ថាន។ |
| គុណភាពអប់រំ និងសុខុមាលភាព | - បណ្តុះបណ្តាលគ្រូបង្រៀនដែលកំពុងបង្រៀនស្រាប់ និងគរុសិស្ស លើវិធីសាស្ត្របង្រៀនប្រកបដោយប្រសិទ្ធភាព រួមទាំងវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល បរិយាបន្ន និងវិធីសាស្ត្រឆ្លើយតបនឹងយេនឌ័រ<br>- ពង្រឹងការចូលរួមបណ្តាញអប់រំ បណ្តុះបណ្តាលគណៈគ្រប់គ្រងសាលា និងធ្វើអធិការកិច្ចសាលាដោយមានការគាំទ្រពីក្រុមបណ្តុះបណ្តាលនិងត្រួតពិនិត្យថ្នាក់ស្រុក (DTMT) |

| | |
|---|---|
| | - ផ្ដល់អាហារថ្ងៃត្រង់ជាប្រភេទអាហារសុខភាព និងកម្មវិធីលើកទឹកចិត្តការមករៀនទៀងទាត់ ដូចជាការចែកអង្ករលើកទឹកចិត្តប្រចាំខែ<br>- ផ្ដល់ថ្នាក់ហាត់យូហ្គា របាំប្រពៃណីខ្មែរ ការអប់រំអំពីគុណតម្លៃនៃការរស់នៅ និងឱកាសចូលរួមក្នុងសកម្មភាពកីឡា<br>- លើកកម្ពស់គំនិតផ្ដួចផ្ដើមអប់រំដឹកនាំដោយសហគមន៍ រួមមានកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ និងការគ្រប់គ្រងអនាម័យពេលមករដូវ (MHM) ក្នុងភាពជាដៃគូជាមួយអាជ្ញាធរមូលដ្ឋាន ការបណ្ដុះបណ្ដាលអាណាព្យាបាល ការចូលរួមពីក្រុមប្រឹក្សាសិស្ស និងឱកាសសម្រាប់សិស្សធ្វើជាអ្នកប្រឹក្សាស្ម័គ្រចិត្តក្នុងថ្នាក់បំប៉នពេលល្ងាច<br>- ផ្ដល់សេវាថែទាំសុខភាពនៅតាមសាលា ISF និងសហការជាមួយមន្ទីរពេទ្យរដ្ឋ។ |
| កិច្ចការពារកុមារ និងបរិស្ថានសិក្សាដោយសុវត្ថិភាព | - ធ្វើយុទ្ធនាការប្រឆាំងអំពើហិង្សាលើកុមារ ការអប់រំអំពីសិទ្ធិកុមារសម្រាប់កុមារ អាណាព្យាបាល និងគ្រូបង្រៀន។<br>- សហការរៀបចំយុទ្ធនាការលើកកម្ពស់ការយល់ដឹងប្រឆាំងការរើសអើង និងលើកកម្ពស់បរិស្ថាននៃការអប់រំ សហការលើព្រឹត្តិការណ៍ពង្រឹងការអាន និងផ្សព្វផ្សាយព័ត៌មានអំពីសារៈសំខាន់នៃបរិស្ថាននៃការអប់រំ<br>- បណ្ដុះបណ្ដាលបុគ្គលិកសិក្សា អ្នកជំនាញផ្នែកច្បាប់ និង អ្នកដឹកនាំសាលា ស្ដីពីកិច្ចការពារកុមារ សមភាពយេនឌ័រ និងការចូលរួម។<br>- កសាងក្រុមគាំពារកុមារ លើកកម្ពស់ការអប់រំសុខភាពផ្លូវចិត្ត។ |
| និរន្តរភាព និងការត្រួតពិនិត្យ | - ការកៀរគរធនធាន៖ រៀបចំការបណ្ដុះបណ្ដាល ដើម្បីផ្ដល់សិទ្ធិអំណាចដល់សាលារៀន និងសហគមន៍<br>- ការត្រួតពិនិត្យ និងវាយតម្លៃ៖ វាយតម្លៃជាប្រចាំលើប្រសិទ្ធភាពនៃកម្មវិធី និងធានានិរន្តរភាពកម្មវិធី។ |
| ៦. កម្មវិធីអប់រំមធ្យមសិក្សាទុតិយភូមិ | |
| ភាពជាដៃគូ និងកិច្ចសហការ | - សហការជាមួយដៃគូ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីកិច្ចការពារកុមារ អំពើហិង្សាលើកុមារ ទប់ស្កាត់ការបោះបង់ការសិក្សា និងសមភាពយេនឌ័រក្នុងការអប់រំ (រួមទាំងសម្ភារបរិក្ខារទឹកស្អាត អនាម័យ និងគ្រប់គ្រងអនាម័យពេលមករដូវ នៅតំបន់ដាច់ស្រយាល)<br>- ជំរុញការចូលរួមរបស់តំណាងយុវជនដែលជួបការលំបាក ក្នុងកិច្ចសន្ទនាអំពីការអប់រំជាមួយអ្នកធ្វើគោលនយោបាយ និងអ្នកផ្ដល់សេវា<br>- ចែករំលែកសម្ភារអប់រំកុមារ និងយុវជនមេត្រីផ្អែកលើភស្តុតាងជាមូលដ្ឋាន ដើម្បីជំរុញដល់ការកែលម្អគោលនយោបាយ<br>- សហការរៀបចំយុទ្ធនាការប្រឆាំងការរើសអើង និងលើកកម្ពស់ការពង្រឹងសមត្ថភាពអាន និងបរិស្ថាននៃការអប់រំ។ |

| | |
|---|---|
| ការគាំទ្រកុមារ និងយុវជន | - គាំទ្រការចូលរៀនរបស់កុមារ និងយុវជននៅសាលារដ្ឋ រួមទាំងការផ្តល់អាហារូបករណ៍សម្រាប់សិស្សស្រីរៀនថ្នាក់វិទ្យាល័យ និងជំនួយហិរញ្ញវត្ថុលើអាហារពេលព្រឹក អាហារសម្រន់ និងបង់ថ្លៃសិក្សាឯកជនសម្រាប់សិស្សគោលដៅ<br>- ផ្តល់ជូនឯកសណ្ឋានសិក្សាដល់កុមារក្រីក្រ ជាពិសេសកុមារី។ |
| ការកែលម្អសាលារៀន | - គាំទ្រក្រសួងអ.យ.ក ក្នុងការបង្កើតវេទិកាសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងបង្កើនភាពពាក់ព័ន្ធនៃការអប់រំ និងបំណិនជីវិត (អក្ខរកម្មផ្នែកហិរញ្ញវត្ថុ ជំនាញឌីជីថល)<br>- បង្កើតក្រុមការពារកុមារនៅតាមសាលារៀន និងរៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាពសម្រាប់នាយកសាលា គ្រូបង្រៀន និងបណ្ណារក្ស<br>- បង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ (PLCs) សម្រាប់គ្រូបង្រៀនតាមកម្មវិធី STEM និងបណ្តុះបណ្តាលគ្រូបង្រៀនលើសុខភាពផ្លូវចិត្ត និងបរិស្ថាននៃការអប់រំ<br>- កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមិនមានឧបសគ្គនៅតាមសាលាគោលដៅ។ |
| កម្មវិធីហាត់ការ | - ផ្តល់ថ្នាក់រៀនភាសាអង់គ្លេស កុំព្យូទ័រ កីឡា ការថែទាំសុខភាព អាហារូបករណ៍ តន្ត្រី ថ្នាក់ភាពជាអ្នកដឹកនាំ និងកម្មវិធីក្រៅម៉ោងសិក្សា ជាមួយនឹងការជួយឧបត្ថម្ភអាហារ សកម្មភាពផ្សេងៗ និងជំនួយការសិក្សា<br>- ធ្វើសមាហរណកម្មឱកាសសិក្សាបែបគម្រោង និងលើកទឹកចិត្តឱ្យសិស្សចូលរួមនៅក្នុងការងារសហគមន៍តាមរយៈកម្មវិធីប្រឹក្សាយោបល់ស្ម័គ្រចិត្ត<br>- អនុវត្តថ្នាក់អប់រំអំពីគុណតម្លៃការរស់នៅ និងរៀបចំសិក្ខាសាលាតម្រង់ទិសមុខរបរវិជ្ជាជីវៈ។ |
| ការគាំទ្រសិស្ស | - ផ្គត់ផ្គង់សម្ភារ និងតាមដានវឌ្ឍនភាពនៃការសិក្សា គ្រប់គ្រងករណីគ្រួសារទាក់ទងនឹងការចូលរៀនរបស់សិស្ស និងអនុវត្តតាមកម្មវិធីសិក្សារបស់សាលារដ្ឋ<br>- ផ្តល់ថ្នាក់បំប៉នចាប់ពីថ្នាក់ទី១ ដល់ទី៦ ធ្វើសមាហរណកម្មសិស្សរៀនថ្នាក់បំប៉ន និងជួយគាំទ្រពួកគេរហូតដល់បញ្ចប់ការសិក្សា។ |
| សកម្មភាពក្រៅកម្មវិធីសិក្សា | - ផ្តល់សកម្មភាពក្រៅកម្មវិធីសិក្សា ដូចជាថ្នាក់ភាសាអង់គ្លេស កុំព្យូទ័រ យូហ្គា របាំប្រពៃណីខ្មែរ បណ្ណាល័យ សិល្បៈ អប់រំកាយ កីឡា សិល្បៈ និងថ្នាក់តន្ត្រី<br>- ឧបត្ថម្ភអង្ករប្រចាំខែដើម្បីលើកទឹកចិត្តការចូលរៀនទៀងទាត់ និងថ្នាក់ភាពជាអ្នកដឹកនាំ (ប្រចាំសប្តាហ៍)<br>- ឧបត្ថម្ភថ្លៃសិក្សាក្រៅកម្មវិធីសិក្សា ផ្តល់ការប្រឹក្សាអំពីការអប់រំ និងសម្ភារសិក្សា (ឯកសណ្ឋាន ស្បែកជើង កង់។ល។)។ |
| ៧. កម្មវិធីអប់រំក្រៅប្រព័ន្ធ | |
| កម្មវិធីអក្ខរកម្ម និងភាសា | - បើកដំណើរការថ្នាក់អក្ខរកម្មភាសាខ្មែរ និងជនជាតិដើមភាគតិចការ៉ែត សម្រាប់កុមារ និងយុវជន និងផ្តល់សម្ភាររៀន និងបង្រៀនសម្រាប់ថ្នាក់រៀន<br>- រៀបចំទិវាអក្ខរកម្ម |

| | |
|---|---|
| | - ផ្តួចផ្តើម និងផលិតសម្ភារៀន និងបង្រៀនពហុភាសា<br>- ផ្តល់ឧបករណ៍ (សូឡា) សម្រាប់ការអប់រំពហុភាសាក្រៅប្រព័ន្ធ<br>- ផ្តល់ និងបណ្តុះបណ្តាលគ្រូជាប់កិច្ចសន្យាសម្រាប់បង្រៀនអក្ខរកម្មក្រៅប្រព័ន្ធ។ |
| ការបណ្តុះបណ្តាល និងគាំទ្រគ្រូបង្រៀន | - អនុវត្តកម្មវិធីពង្រឹងសមត្ថភាពគ្រូបង្រៀន<br>- ឧបត្ថម្ភប្រាក់ប្រចាំខែដល់គ្រូបង្រៀន និងផ្តល់រង្វាន់លើកទឹកចិត្តដល់គ្រូថ្មីម<br>- ផ្តល់ការបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ គុណតម្លៃ និងបច្ចេកទេសបង្រៀន<br>- ផ្តល់សម្ភារបង្រៀនដល់គ្រូបង្រៀន។ |
| ការគាំទ្រសិស្ស | - ជួយដល់សិស្សរៀនថ្នាក់ត្រៀមមុនធ្វើសមាហរណកម្មទៅក្នុងសាលារដ្ឋ<br>- ផ្តល់កម្មវិធីសមមូលអប់រំមូលដ្ឋាន (BEEP) សម្រាប់សិស្សដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់<br>- ផ្តល់ការបង្រៀនបំប៉នបន្ថែមជាភាសាខ្មែរ គណិតវិទ្យា និងភាសាអង់គ្លេស<br>- ជួយដល់សិស្សអនុវត្តគម្រោងសេវាសហគមន៍<br>- ជួយដល់កុមារជនជាតិភាគតិចវៀតណាមដែលមិនមានលទ្ធភាពចុះឈ្មោះចូលរៀន។ |
| ការលើកកម្ពស់ការយល់ដឹង និងការអភិវឌ្ឍន៍សហគមន៍ | - អនុវត្តសកម្មភាពលើកកម្ពស់ការយល់ដឹងអំពីការថែទាំសុខភាព អនាម័យ បំណិនជីវិត ការអប់រំ និងសិទ្ធិកុមារដល់សហគមន៍ជនជាតិដើមភាគតិចការ៉ែត<br>- ពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិទាក់ទងនឹងវិស័យអប់រំ<br>- រៀបចំប្រជុំផ្សព្វផ្សាយ កិច្ចប្រជុំប្រចាំត្រីមាស វគ្គបណ្តុះបណ្តាល និងសិក្ខាសាលា<br>- ជួយសម្រួលដល់ការអភិវឌ្ឍន៍ និងលើកកម្ពស់បរិស្ថានភូមិ<br>- ជួបជាមួយអាណាព្យាបាល មន្ត្រីកម្មវិធី និងសហគមន៍ ដើម្បីពិភាក្សាអំពីសារៈសំខាន់នៃកម្មវិធីអប់រំ។ |
| កិច្ចការពារកុមារ | - ធ្វើការជាមួយដៃគូ ដើម្បីលើកកម្ពស់ការយល់ដឹងទាក់ទងនឹងកិច្ចការពារកុមារ និងទប់ស្កាត់ការបោះបង់ការសិក្សា<br>- អនុវត្តកម្មវិធីថែទាំបំប៉នអាហាររូបត្ថម្ភ |
| បច្ចេកវិទ្យា និងបំណិនជីវិត | - ផ្តល់ការបណ្តុះបណ្តាលជំនាញកុំព្យូទ័រ<br>- ផ្តល់កម្មវិធីបណ្តុះបណ្តាលជំនាញទន់ផ្តោតលើការចូលរួមរបស់យុវជន និងលើកកម្ពស់ការយល់ដឹងអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិត(OCSE)។ |
| ៨. កម្មវិធីអប់រំឧត្តមសិក្សា | |
| លើកកម្ពស់ការអប់រំឧត្តមសិក្សា | - លើកទឹកចិត្តយុវជនឱ្យបន្តការសិក្សាថ្នាក់ឧត្តមសិក្សា<br>- ផ្តល់អាហារូបករណ៍ដល់កម្មសិក្សាការីស្ម័គ្រចិត្ត និងនិស្សិតទៅតាមចំណាប់អារម្មណ៍ ទេពកោសល្យ និងតម្រូវការហិរញ្ញវត្ថុ<br>- ផ្តល់ការប្រឹក្សាវិជ្ជាជីវៈ ការណែនាំអំពីការបំពេញពាក្យចូលរៀននៅសាកលវិទ្យាល័យ និងឧបត្ថម្ភថ្លៃសិក្សានៅសាកលវិទ្យាល័យ |

| | |
|---|---|
| | - ផ្តល់កម្មវិធីអាហារូបករណ៍រយៈពេល ០៤ ឆ្នាំសម្រាប់និស្សិតស្រីជាមួយនឹងកន្លែងស្នាក់នៅ អាហារហូបចុក វគ្គសិក្សាកុំព្យូទ័រមូលដ្ឋាន សៀវភៅសិក្សា ថ្លៃសិក្សាភាសាអង់គ្លេស និងប្រាក់ឧបត្ថម្ភប្រចាំខែ<br>- រៀបចំដំណើរទស្សនកិច្ចសិក្សា សិក្ខាសាលា និងកម្មវិធីចែករំលែកចំណេះដឹងដើម្បីពង្រឹងការសិក្សា និងអភិវឌ្ឍន៍សិស្ស<br>- សម្របសម្រួលការប្រាស្រ័យទាក់ទង និងសាមគ្គីភាពរវាងអ្នកសិក្សាតាមរយៈសកម្មភាពកសាងក្រុម<br>- លើកទឹកចិត្តអ្នកសិក្សាឱ្យធ្វើកម្មសិក្សា និងធ្វើការស្ម័គ្រចិត្តជាមួយNGOs<br>- ផ្តល់ការប្រឹក្សាលក្ខណៈបុគ្គល<br>- ការចូលរួមសហគមន៍៖ រៀបចំព្រឹត្តិការណ៍ "ទិវាសងគុណ" សម្រាប់អ្នកសិក្សាដើម្បីរៃអង្គាសប្រាក់ និងជួយគាំទ្រសាលារៀននៅតំបន់ជនបទដាច់ស្រយាល។ |
| គាំទ្រការបណ្តុះបណ្តាលវិជ្ជាជីវៈ | - លើកកម្ពស់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់សិស្សដែលចាប់អារម្មណ៍លើជំនាញផ្សេងៗ<br>- រៀបចំសិក្ខាសាលាស្តីពីការត្រៀមខ្លួនសម្រាប់អាជីព (ការសរសេរប្រវត្តិរូបសង្ខេប CV ការសម្ភាសន៍ការងារ ច្បាប់ការងារ និងការស្វែងរកអាហារូបករណ៍)។ |
| ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការសិក្សា | - ជួយដល់សិស្សដែលមានពិការភាព៖ ជួយដល់យុវជនពិការភ្នែក គថ្លង់ ឬក្រីក្រ ដើម្បីបន្តការសិក្សាថ្នាក់ឧត្តមសិក្សា ដោយផ្គត់ផ្គង់សម្ភារសិក្សា និងថ្លៃសិក្សា<br>- ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ៖<br>● ផ្តល់អាហារូបករណ៍មួយផ្នែក ប្រាក់ឧបត្ថម្ភ និងការឧបត្ថម្ភជាអង្ករ<br>● បង់ថ្លៃសិក្សាភាសាអង់គ្លេស<br>- ផ្តល់ការគាំទ្រផ្នែកសិក្សា៖<br>● ផ្តល់ថ្នាក់ភាពជាអ្នកដឹកនាំ និងវគ្គសិក្សាកុំព្យូទ័រមូលដ្ឋាន<br>● តម្រូវឱ្យអ្នកសិក្សាធ្វើកំណត់ហេតុប្រចាំថ្ងៃជាភាសាអង់គ្លេស និងបង្ហាញអត្ថបទ ឬការស្រាវជ្រាវនៅក្នុងកិច្ចប្រជុំប្រចាំខែ។ |
| **៩. កម្មវិធីអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ** | |
| កម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍ជំនាញ | - ផ្តល់ការបណ្តុះបណ្តាលជំនាញកុំព្យូទ័រ ភាសាអង់គ្លេស ការគ្រប់គ្រងអាជីវកម្មខ្នាតតូច កែច្នៃចំណីអាហារ តម្បាញ និងវគ្គសិក្សាវិជ្ជាជីវៈផ្សេងៗ (មេកានិក កាត់សក់ កែសម្ផស្ស ផលិតភេសជ្ជៈ)<br>- ផ្តល់ការបណ្តុះបណ្តាលជំនាញកសិកម្មដល់យុវជនដែលបានបោះបង់ការសិក្សា<br>- ផ្តល់ការបណ្តុះបណ្តាលគ្រូបង្រៀនឯកទេសអប់រំពហុភាសា(រួមទាំងអនឡាញ)<br>- បណ្តុះបណ្តាលយុវជនលើជំនាញវិជ្ជាជីវៈដូចជា ជួសជុលម៉ូតូ អ៊ុតសក់ និងជំនាញជាច្រើនទៀត |

| | |
|---|---|
| | - គាំទ្រយុវជន និងអាណាព្យាបាលឱ្យចូលរៀនថ្នាក់អក្ខរកម្ម និងវិជ្ជាជីវៈ<br>- ជួយដល់សិស្សដែលចាប់អារម្មណ៍លើការបណ្តុះបណ្តាលវិជ្ជាជីវៈជាមួយនឹងការប្រឹក្សាអាជីព និងការងារ<br>- ជួយគាំទ្រមជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈលើការអភិវឌ្ឍន៍កម្មវិធីសិក្សាកសិ-កែច្នៃ និងបណ្តុះបណ្តាលគ្រូបង្គោលផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើជំនាញកសិ-កែច្នៃ<br>- ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជនពិការ (របាំ សិល្បៈ បដិសណ្ឋារកិច្ច អក្ខរកម្ម ភាសាអង់គ្លេស និងជំនាញកុំព្យូទ័រ) នៅមជ្ឈមណ្ឌល Epic Arts<br>- បញ្ជូនជនពិការទៅកាន់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈបន្ទាប់ពីសេវាស្តារនីតិសម្បទា<br>- ផ្សារភ្ជាប់សិស្សដែលប្រឡងជាប់ ឬធ្លាក់ថ្នាក់ទី១២ ឬបោះបង់ការសិក្សា ជាមួយនឹងឱកាសបណ្តុះបណ្តាលជំនាញ<br>- លើកកម្ពស់ការអនុវត្តជាវិជ្ជមានលើសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ (SRH) និងអាហារូបត្ថម្ភសម្រាប់សិស្ស និងសិក្ខាកាម<br>- ផ្តល់ការគាំទ្រក្រោយការបណ្តុះបណ្តាល ដូចជាកម្មសិក្សា<br>- ផ្តល់ជំនួយឥតសំណងខ្នាតតូចដល់សិក្ខាកាមបញ្ចប់ការសិក្សាផ្នែក TVET ដើម្បីបើកអាជីវកម្មធុនមីក្រូ តូច និងមធ្យម (MSMEs)<br>- ចាប់ដៃគូជាមួយសហគ្រាស និងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីចុះឈ្មោះយុវជន (អាយុចាប់ពី ១៥ ឆ្នាំ) សម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ផ្តល់កញ្ចប់បណ្តុះបណ្តាល និងឱកាសអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន<br>- សម្របសម្រួលកម្មវិធីចែករំលែកចំណេះដឹងជាប្រចាំ និងកិច្ចប្រជុំបច្ចេកទេសសម្រាប់គ្រូបង្រៀន។ |
| ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងតាមតម្រូវការ | - ឧបត្ថម្ភថ្លៃបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្លៃជីវភាព និងដើមទុនបើកអាជីវកម្មដំបូង<br>- ផ្តល់អាហារូបករណ៍ដល់សិស្សចូលរួមកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ឧបត្ថម្ភថ្លៃបណ្តុះបណ្តាលដល់យុវជនដែលជាសិក្ខាកាម<br>- ផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែដល់យុវជនសម្រាប់ចំណាយលើអាហារហូបចុក។ |
| ក្រុមគោលដៅ និងអភិក្រម (វិធីសាស្ត្រ) | - ផ្តោតលើយុវជនដែលជួបការលំបាក រួមទាំងអ្នកដែលមិនទទួលបានការអប់រំ ការងារ ឬការបណ្តុះបណ្តាល (NEET) ស្ត្រីវ័យក្មេង និងអ្នកគ្មានការងារធ្វើ/គ្មានជំនាញ ទាំងនៅតំបន់ជនបទ និងទីក្រុង<br>- ផ្តល់អាទិភាពដល់ការអភិវឌ្ឍន៍ជំនាញ លើជំនាញបច្ចេកទេស ជំនាញទន់ សហគ្រិនភាព និងការត្រៀមខ្លួនសម្រាប់អាជីពការងារ<br>- ដោះស្រាយបញ្ហាជំនឿតៗគ្នាអំពីយេនឌ័រដោយលើកកម្ពស់ការងារដែលមិនមែនបែបប្រពៃណីសម្រាប់ស្ត្រីវ័យក្មេង |

| | |
|---|---|
| | - ធ្វើការជាមួយភាគីពាក់ព័ន្ធនានា (យុវជន អាណាព្យាបាល រដ្ឋាភិបាល និងវិស័យឯកជន) ដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំ និងឱកាសការងារពាក់ព័ន្ធ ជាពិសេសសម្រាប់ស្ត្រីវ័យក្មេង<br>- កសាងសមត្ថភាពរបស់គ្រឹះស្ថានបណ្តុះបណ្តាល ដើម្បីផ្តល់ការបណ្តុះបណ្តាលយុវជនមេត្រី និងឆ្លើយតបនឹងយេនឌ័រ<br>- តស៊ូមតិដើម្បីកែលម្អគោលនយោបាយ និងគោលការណ៍ណែនាំស្តីពី TVET ។ |
| ១០. កម្មវិធីអប់រំសាលាគំរូ | |
| ការគាំទ្រសាលាគំរូ | - ការបណ្តុះបណ្តាលគ្រូបង្រៀន និងថ្នាក់ដឹកនាំ៖<br>● ពង្រឹងជំនាញបង្រៀនតាមរយៈកញ្ចប់បណ្តុះបណ្តាលកម្រិតថ្នាក់ដំបូង<br>●បំប៉នសមត្ថភាពថ្នាក់ដឹកនាំសាលាលើការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព<br>- ការចូលរួមរបស់អាណាព្យាបាល៖<br>●អប់រំអ្នកថែទាំអំពីការគាំទ្រសម្រាប់ភាពជោគជ័យនៃការអប់រំកម្រិតថ្នាក់ដំបូង<br>- ការកែលម្អសាលារៀន៖<br>● ផ្តល់សម្ភារសម្រាប់ជួសជុលកែលម្អសាលារៀន និងអភិវឌ្ឍបណ្ណាល័យ។<br>● ធ្វើសមាហរណកម្មបច្ចេកវិទ្យា ICT (បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍) ដើម្បីពង្រឹងការរៀនសូត្រ<br>- ការគ្រប់គ្រងបណ្ណាល័យ៖ បំពាក់បរិក្ខារបណ្ណាល័យ និងបណ្តុះបណ្តាលបណ្ណារក្សអំពីសេវា ជំនួយបច្ចេកទេស និងរដ្ឋបាល<br>- ការអប់រំ STEM៖ ផ្តល់សិទ្ធិអំណាចដល់គ្រូបង្រៀន STEM តាមរយៈ៖<br>● ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងមន្ទីរពិសោធន៍វិទ្យាសាស្ត្រ<br>● ការប្រើប្រាស់ឧបករណ៍ពិសោធន៍ជាក់ស្តែងប្រកបដោយប្រសិទ្ធភាព<br>● ការធ្វើសមាហរណកម្មវិធីសាស្ត្ររៀន និងបង្រៀនតាមបែប STEM<br>● ការលើកកម្ពស់ការចូលរួមរបស់សិស្សតាមរយៈការសិក្សាបែបគម្រោង<br>● ការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ(PLC) សម្រាប់អ្នកអប់រំតាមកម្មវិធី STEM<br>- ការពិនិត្យ និងវាយតម្លៃ៖<br>● ធ្វើការវាយតម្លៃលើអំណាន និងគណិតវិទ្យាកម្រិតថ្នាក់ដំបូង<br>● គាំទ្រដល់បណ្ណាល័យ នាយកសាលា និងគ្រូបង្រៀន ដើម្បីកសាងសមត្ថភាព<br>- ពង្រឹងគណនេយ្យភាពសង្គម តម្លាភាព និងការចូលរួមសហគមន៍តាមរយៈកម្មវិធីសាលាគំរូ<br>- សហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីផ្តល់ការបណ្តុះបណ្តាល និងគាំទ្រដល់ការអនុវត្តប្រកបដោយជោគជ័យ។ |

| | |
|---|---|
| ការអប់រំអក្ខរកម្មផ្នែកហិរញ្ញវត្ថុ និងការផ្តល់សិទ្ធិអំណាច | - បង្កើត និងផ្តល់កម្មវិធី ឆា-ឈីង (Cha-Ching) ដោយផ្តោតលើគោលគំនិតស្នូលផ្នែកហិរញ្ញវត្ថុ<br>- ពង្រឹងតួនាទី និងមុខងាររបស់គណៈកម្មាធិការក្រុមប្រឹក្សាសិស្ស<br>- បណ្តុះបណ្តាលគ្រូបង្រៀន និងសិស្ស លើការអនុវត្តផ្នែក WASH (ទឹកស្អាត និងអនាម័យ) និងជំនាញទន់<br>- សហការជាមួយអាជ្ញាធរអប់រំ ដើម្បីធានាការអនុវត្តកម្មវិធីសាលាគំរូដោយជោគជ័យ។ |
| និរន្តរភាព និងការអភិវឌ្ឍន៍ | - ធ្វើការស្រាវជ្រាវ និងត្រួតពិនិត្យគុណភាពនៃការអនុវត្តកម្មវិធី<br>- ចាប់ដៃគូជាមួយគណៈគ្រប់គ្រងសាលារៀន ដើម្បីកែលម្អបរិយាកាសសិក្សា ហេដ្ឋារចនាសម្ព័ន្ធ និងអនាម័យ<br>- ជំរុញការចូលរួមរបស់អាណាព្យាបាលតាមរយៈគំនិតផ្តួចផ្តើមក្នុងការរៀបចំសួនសាលារៀន<br>- ធ្វើការវាយតម្លៃជាប្រចាំ រៀបចំផែនការកែលម្អសាលារៀន និងវិនិយោគលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាលារៀន។ |
| ១១. សកម្មភាពផ្សេងៗ (ដែលមិនបានបញ្ជាក់ច្បាស់លាស់) | |
| មិនបានបញ្ជាក់ច្បាស់លាស់ | - កម្មវិធីបណ្តុះបណ្តាលៈ វិធីសាស្រ្តបង្រៀន និងបណ្តុះបណ្តាលគ្រូបង្រៀនភាសាអង់គ្លេសសម្រាប់អ្នកសិក្សាភាសាអង់គ្លេស”)<br>- សកម្មភាពយុទ្ធសាស្រ្តៈ ការគ្រប់គ្រងធនធានធម្មជាតិ កសិកម្ម និងមុខរបរចិញ្ចឹមជីវិត សិទ្ធិកុមារនិងការអប់រំ និងជីវៈចម្រុះ និងការអភិរក្ស<br>- ការបណ្តុះបណ្តាលបំណិនជីវិត និងជំនាញទន់សម្រាប់យុវជន<br>- ប្រមូលផ្តុំយុវជនមកពីមជ្ឈដ្ឋានខុសៗគ្នា ដើម្បីបង្កើតគម្រោងខ្នាតតូចសម្រាប់សហគមន៍មូលដ្ឋាន<br>- គាំទ្រកុមារ និងយុវជនក្នុងការលើកកម្ពស់ការអប់រំៈ យុទ្ធនាការដឹកនាំដោយកុមារ និងយុវជន លើកកម្ពស់ការយល់ដឹង កិច្ចសន្ទនា និងការស្រាវជ្រាវដោយផ្អែកលើសកម្មភាពអនុវត្ត<br>- គាំទ្រក្រសួងអ.យ.ក ក្នុងការបង្កើតវេទិកាសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់ CPD<br>- លាបថ្នាំអគារ និងជួសជុលសាលារៀន<br>- បញ្ជ្រាបការឆ្លើយតបនឹងយេនឌ័រដើម្បីកាត់បន្ថយអំពើហិង្សាទាក់ទងនឹងយេនឌ័រ<br>- គម្រោងសាកល្បងៈ ប្រើប្រាស់បច្ចេកវិទ្យា ICT ដើម្បីធ្វើឱ្យប្រសើរឡើងនូវការរៀនសូត្រនៅកម្រិតថ្នាក់ដំបូង និងការគាំទ្របណ្ណាល័យឌីជីថលៈ ស្មាតជីវី និងថេប្លេត..<br>- បណ្តុះបណ្តាលគ្រូបង្រៀនលើការប្រើប្រាស់បច្ចេកវិទ្យា<br>- សម្របសម្រួលកម្មវិធី ឬការអភិវឌ្ឍន៍វេទិកាសិក្សា<br>- ផ្លាស់ប្តូរធនធានអាហារូបត្ថម្ភ និងសុខភាពសាធារណៈ |

| | |
|---|---|
| | - គាំទ្រការកសាងសមត្ថភាពបុគ្គលិករបស់ក្រសួងអ.យ.កក្នុងការកសាងផែនការអប់រំផ្អែកលើភស្តុតាងជាមូលដ្ឋាន (ថ្នាក់ខេត្ត ស្រុក និងសាលា)<br>- គាំទ្រការចូលរួមរបស់យុវជន និងការអភិវឌ្ឍន៍តាមគោលការណ៍ស្ម័គ្រចិត្ត<br>- អនុវត្តកម្មវិធី៖ សុខភាព និងអាហារូបត្ថម្ភ ទឹកស្អាត និងអនាម័យ គ្រោះមហន្តរាយ និងកសិកម្ម ការអភិវឌ្ឍន៍កុមារ<br>- កិច្ចការពារកុមារ៖ អាហារូបត្ថម្ភ ការគ្រប់គ្រងគ្រោះមហន្តរាយ<br>- ការបណ្តុះបណ្តាលគរុសិស្ស៖<br>● ក្រសួងអ.យ.ក បានសហការជាមួយគម្រោង IPEA ក្នុងការបង្កើតកម្មវិធីសិក្សាសម្រាប់ការបង្រៀន អាន និងសរសេរភាសាខ្មែរដល់គ្រូបឋមសិក្សា<br>● គាំទ្រការបង្កើតកម្មវិធីសិក្សា និងសម្ភារឧបទ្ទេសសម្រាប់ថ្នាក់បរិញ្ញាបត្រ (១២+៤ ឆ្នាំ) និងកម្មវិធីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្ត - PTTC (១២+២ ឆ្នាំ)។ កម្មវិធីសិក្សាទាំងនេះផ្តោតលើវិធីសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការបង្រៀនភាសាខ្មែរនៅបឋមសិក្សា<br>- កម្មវិធីអភិបាលកិច្ចល្អ (AYRG)<br>- បណ្តុះបណ្តាលបុគ្គលិកមណ្ឌលសុខភាព<br>- គាំទ្រលទ្ធភាពទទួលបានសេវាសម្រាប់កុមារដែលមានតម្រូវការពិសេស<br>- បណ្តុះបណ្តាលវិជ្ជាជីវៈ និងគាំទ្រមុខរបរចិញ្ចឹមជីវិត<br>- ការបណ្តុះបណ្តាលគ្រូបង្រៀន និងអភិវឌ្ឍកម្មវិធីសិក្សា<br>- លើកកម្ពស់ការយល់ដឹង និងការតស៊ូមតិ<br>- សេវាថែទាំសុខភាព និងមាត់ធ្មេញ សេវាស្តារនីតិសម្បទា<br>- កម្មវិធីការងារ៖ ថ្នាក់អក្ខរកម្មសម្រាប់មនុស្សពេញវ័យ ថ្នាក់បណ្តុះបណ្តាលផ្នែកកាត់ដេរ ការបោះពុម្ពសៀវភៅ<br>- សកម្មភាពសិស្ស៖ ការធ្វើដំណើរបោះជំរុំប្រចាំឆ្នាំ និងព្រឹត្តិការណ៍ភាពជាអ្នកដឹកនាំ៖ កិច្ចពិភាក្សាយុវជនប្រចាំឆ្នាំ និងព្រឹត្តិការណ៍ភាពជាអ្នកដឹកនាំយុវជនប្រចាំឆ្នាំ<br>- សហគ្រាសសង្គម៖ Epic Arts Café និង Epic Arts Dance Group<br>- ការគាំទ្រសម្រាប់សិស្សស្រី៖ ផ្តល់កង់សម្រាប់សិស្សដែលរស់នៅឆ្ងាយពីសាលារៀន ការឧបត្ថម្ភស្បៀងជាអង្ករសម្រាប់សិស្សអាហារូបករណ៍ ធ្វើការជាដៃគូជាមួយNGOs ក្នុងស្រុក ដើម្បីផ្តល់អាហារូបករណ៍ (ថ្នាក់ទី១០-១២) នៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងពោធិ៍សាត់<br>- ភាពជាដៃ៖ អង្គការក្នុងស្រុក (អង្គការសន្តិសេនា) លើគម្រោងអភិវឌ្ឍន៍ជនបទសមាហរណកម្មក្នុងខេត្តស្វាយរៀង និង PNC ដើម្បីជួយដល់ក្មេងស្រីដែលកំពុងសិក្សាកម្មវិធីថ្នាក់បរិញ្ញាបត្ររងផ្នែកបង្កើតកម្មវិធីគេហទំព័រនៅរាជធានីភ្នំពេញ។ |

| | |
|---|---|
| | - លើកកម្ពស់គុណភាពអប់រំ និងលទ្ធភាពទទួលបានសេវាដោយសមធម៌សម្រាប់ កុមារ<br>- ជួយដល់ក្មេងស្រីដែលប្រឈមហានិភ័យនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិត (OCSE)៖ យុទ្ធនាការលើកកម្ពស់ការយល់ដឹង និងផ្សព្វផ្សាយសហគមន៍ ការគាំទ្រខ្សែត្រៀមសេរីភាព កិច្ចពិភាក្សា និងការអនុវត្តឧបករណ៍វាយតម្លៃ ហានិភ័យ និង Chatbot ការបណ្តុះបណ្តាលគម្រោងបណ្តុះយុទ្ធនាការ និងសហគមន៍ និងគំនិតផ្តួចផ្តើមភូមិឃុំមិនមានការកេងប្រវ័ញ្ច<br>- បណ្តុះបណ្តាលអ្នកស្រាវជ្រាវប្រជាពលរដ្ឋ អ្នកសារព័ត៌មាន មិត្តណែនាំមិត្ត និងភ្នាក់ងារដើម្បីការផ្លាស់ប្តូរ<br>- កម្មវិធីអប់រំយុវជនសាកលៈ វេទិកាបណ្តាញសម្រាប់សិស្សវិទ្យាល័យ ដើម្បីចែករំលែកទស្សនៈ<br>- កម្មវិធីទឹកស្អាត និងអនាម័យតាមសាលារៀន៖ ការដំឡើងប្រព័ន្ធចម្រោះទឹក ការដំឡើងឡដុតសំរាមសាលា (គប្បីពិចារណា "ប្រព័ន្ធចាក់សំរាម" ជំនួសវិញ) ឡាបូលាងដៃ និងសាងសង់បង្គន់អនាម័យ និងត្រួតពិនិត្យប្រចាំខែ ការប្រើប្រាស់ និងថែទាំគ្រឿងបរិក្ខារ<br>- កម្មវិធីសុខុមាលភាពកុមារ៖ ពិនិត្យព្យាបាល និងអប់រំសុខភាពមាត់ធ្មេញ<br>- ការអប់រំអោណាព្យាបាល៖ អប់រំកុមារជាវិជ្ជមាន សិទ្ធិកុមារ គុណតម្លៃរបស់កុមារ គ្រប់ទម្រង់នៃកិច្ចការពារកុមារ និងការគាំទ្រស្ត្រី និងកុមារដែលរងគ្រោះពីអំពើហិង្សា |

## II. លទ្ធផលរកឃើញ

### ១) ការប៉ាន់ប្រមាណគម្រោងថវិកា

ផ្អែកតាមព័ត៌មានដែលNGOs បានផ្តល់បង្ហាញថា ការធ្វើផែនការ/គម្រោងថវិកា គឺមានភាពខុសៗគ្នាពីមួយឆ្នាំទៅមួយឆ្នាំ និងអាស្រ័យលើប្រភេទអង្គការ ។ ផែនការ/គម្រោងថវិកាអប់រំត្រូវបានប៉ាន់ប្រមាណដូចបង្ហាញខាងក្រោម។

តារាងទី ៤៖ តារាងផែនការ (ឬគម្រោង) ថវិកា ដែលបានមកពីការធ្វើផែនទីNGOsដែលឆ្លើយសំណួរ-ឧបសម្ព័ន្ធ២




| | Under 50000 | 50001-100000 | 100001-200000 | 200001-500000 | 500001-1000000 | 1000001-1200000 | 1200001-1500000 | 1500001-2000000 | Over 2000000 |
|---|---|---|---|---|---|---|---|---|---|
| 2024 | 16 | 8 | 5 | 11 | 5 | 1 | 4 | 1 | 0 |
| 2025 | 21 | 6 | 5 | 9 | 5 | 1 | 1 | 3 | 0 |
| 2026 | 24 | 5 | 5 | 7 | 5 | 0 | 2 | 2 | 1 |
| 2027 | 25 | 5 | 5 | 7 | 4 | 0 | 2 | 2 | 1 |
| 2028 | 27 | 4 | 4 | 6 | 5 | 0 | 2 | 3 | 0 |

- នៅឆ្នាំ២០២៤ អង្គការចំនួន ១៦ មានផែនការ/គម្រោងថវិកាក្រោម ៥០,០០០ ដុល្លារ។ ទោះយ៉ាងណា ចំនួនអង្គការនឹងកើនឡើងដល់ ២៧ នៅឆ្នាំ២០២៨។ ដូច្នេះ យើងឃើញថានឹងមានការកើនឡើងនូវគំនិតផ្តួចផ្តើម និងអង្គការតូចៗនៅកម្រិតមូលដ្ឋាន។ លើសពីនេះ ក៏មានការបង្ហាញដែរថាការផ្តល់មូលនិធិធំៗនឹងធ្លាក់ចុះ។
- NGOs កម្រិតមធ្យម (៥០,០០០ - ៥០០,០០០ ដុល្លារ)៖ ការថយចុះថវិកាកម្រិតមធ្យម (ពី ៣២ ទៅ ២៤ អង្គការ) បង្ហាញពីលទ្ធភាពនៃការរួមបញ្ចូលគ្នា ឬការលំបាកក្នុងការធានាបានមូលនិធិនៅកម្រិតនេះ។
- ថវិកាចាប់ពី ១,២០០,០០០ដុល្លារ៖ មានតែNGOsធំៗទេដែលមានសមត្ថភាពគ្រប់គ្រងមូលនិធិនេះ។ ផ្នែកនេះបង្ហាញពីការផ្លាស់ប្តូរជាសក្តានុពលឆ្ពោះទៅរកអង្គការធំៗ។ គេរំពឹងថា ថវិកាចន្លោះពី ១,៥០០,០០០ ដុល្លារ ទៅ ២,០០០,០០០ដុល្លារ និងចាប់ពី ២,០០០,០០០ដុល្លារ នឹងមានការកើនឡើង ដែលជានិន្នាការមួយឆ្ពោះទៅបង្កើតNGOsធំៗដែលនឹងទទួលបានមូលនិធិយ៉ាងច្រើន។

យោងតាមតារាងផែនការ/គម្រោងថវិកា ការប្រែប្រួលថវិកាអាចបណ្តាលមកពីមូលហេតុដូចជា ការប្រកួតប្រជែងផ្នែកមូលនិធិ៖ ការប្រកួតប្រជែងផ្នែកមូលនិធិអាចជំរុញឱ្យអង្គការតូចៗរួមបញ្ចូលគ្នា ឬបង្រួមវិសាលភាពការងារ និង អាទិភាពរបស់ម្ចាស់ជំនួយ៖ ម្ចាស់ជំនួយអាចនឹងផ្តល់អាទិភាពដល់អង្គការធំៗដែលមានបទពិសោធន៍ ឬផ្តោតលើវិស័យជាក់លាក់ដែលត្រូវការថវិកាច្រើន (ឧ. គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ)។

**ដែនកំណត់៖** គួរកត់សម្គាល់ថា ប្រភពទិន្នន័យនៃតារាងនេះ គ្រាន់តែតំណាងឱ្យអង្គការដែលឆ្លើយតបក្នុងការធ្វើផែនទីនេះប៉ុណ្ណោះ។ NGOsមួយចំនួន មិនបានផ្តល់ព័ត៌មានលម្អិតអំពីថវិកាទេ ដោយសារតែមិនមានការយល់ព្រមបញ្ហាប្រឈមនៃការប្រែប្រួលថវិកា និងថវិកាដែលមិនបានរាយការណ៍។ ប្រការសំខាន់ដែលត្រូវពិចារណា គឺថា NGOs មួយចំនួនមិនបានរាយការណ៍អំពីថវិការបស់ខ្លួនទេ ដោយសារតែការយល់ដឹងនៅមានកម្រិត ឬមានការព្រួយបារម្ភអំពីការរក្សាការសម្ងាត់។

## ២) ការស្រាវជ្រាវ/សិក្សា និងសកម្មភាពបណ្តុះបណ្តាលជាក់លាក់

ក្នុងចំណោមNGOsដែលឆ្លើយសំណួរ មានអង្គការចំនួន៣០ ដែលមានថវិកា និងផែនការច្បាស់លាស់សម្រាប់ការសិក្សាស្រាវជ្រាវដូចខាងក្រោម៖

| **វិស័យ ឬការស្រាវជ្រាវ/សិក្សា** | **ប្រធានបទ** |
|---|---|
| ការសិក្សា និងលទ្ធផលសិក្សារបស់សិស្ស | • វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ការអភិវឌ្ឍន៍ជំនាញ និងលទ្ធភាពទទួលបានការងារធ្វើនៅពេលបញ្ចប់ការសិក្សានៅគ្រឹះស្ថានឧត្តមសិក្សា<br>• ពិនិត្យមើលការបន្សុីគ្នារវាងកម្មវិធីសិក្សា និងតម្រូវការទីផ្សារការងារ ក៏ដូចជាប្រសិទ្ធភាពនៃការណែនាំពីការងារ និងសេវាស្វែងរកការងារធ្វើ ដែលបង្កភាពងាយស្រួលក្នុងការតម្រង់ទិសនិស្សិតបញ្ចប់ការសិក្សាទៅកាន់កម្លាំងពលកម្ម<br>• គុណភាពសិក្សារបស់សិស្ស និងអត្រាបោះបង់ការសិក្សា |

| | |
|---|---|
| | • បច្ចេកវិទ្យាសម្រាប់ការសិក្សារបស់សិស្ស<br>• សិក្សាអំពីអត្រាបោះបង់ការសិក្សា និងបញ្ហាប្រឈម<br>• សិក្សាលើគុណភាពនៃការអប់រំ បទដ្ឋានជាតិ និងការអប់រំក្រៅប្រព័ន្ធ<br>• គុណភាពនៃការអប់រំសម្រាប់កុមារពិការនៅកម្ពុជា<br>• វាយតម្លៃអំណាននៅម្រិតថ្នាក់ដំបូង<br>• ដាក់បញ្ចូលវិធីសាស្ត្របង្រៀនកម្រិតថ្នាក់ដំបូងក្នុងការបណ្តុះបណ្តាលគរុសិស្ស<br>• ការបង្រៀនគណិតវិទ្យាកម្រិតថ្នាក់ដំបូង និងការប្រឹក្សាគរុកោសល្យ<br>• គម្រោងដើមគ្រា និងចុងគ្រាដើម្បីវាយតម្លៃសមត្ថភាពអានរបស់សិស្ស។ |
| ការបណ្តុះបណ្តាលគ្រូបង្រៀន និងការអភិវឌ្ឍន៍ | • ការកសាងសមត្ថភាពគ្រូបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស<br>• ការស្រាវជ្រាវបែបសកម្មភាព<br>• ការប្រឹក្សាគរុកោសល្យ<br>• ធ្វើការវាយតម្លៃតម្រូវការ និងអភិវឌ្ឍន៍គម្រោង<br>• ការវាយតម្លៃសាលាគំរូក្នុងខេត្តស្ទឹងត្រែង<br>• ការអនុវត្តគោលនយោបាយអប់រំ និងសាលារដ្ឋ<br>• គុណភាពនៃការរៀន និងបង្រៀន (រួមទាំងថ្នាក់បំប៉នបន្ថែម)។ |
| ការអភិវឌ្ឍន៍ និងគ្រប់គ្រងសាលារៀន | • ការអប់រំមេត្តេយ្យ និងយេនឌ័រនៅសាលាបឋមសិក្សាគោលដៅ<br>• អាហារតាមសាលា<br>• ការចូលរួមរបស់សហគមន៍ឆ្ពោះទៅរកការរៀនសូត្ររបស់កុមារ<br>• ការបែងចែកធនធាន ដើម្បីអនុវត្តសាលាគំរូ និងគុណភាពនៃការសិក្សា<br>• សាលារៀនគំរូ<br>• តើមានសាលាប៉ុន្មានដែលមានសមត្ថភាព និងត្រូវការអនុវត្តសាលាជំនាន់ថ្មី?<br>• ការបែងចែកថវិកាសម្រាប់សកម្មភាពតាមដាន វាយតម្លៃ និងការរៀនសូត្រៈ ពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពលើការអភិវឌ្ឍន៍សាលារៀន កុមារដែលមានហានិភ័យនៃការបោះបង់ការសិក្សា និងការចូលរួមរបស់សហគមន៍<br>• ការផ្ទេរមុខងារទៅថ្នាក់ស្រុកៈ បញ្ហាប្រឈម និងផលប៉ះពាល់។ |
| បញ្ហាសង្គមក្នុងការអប់រំ | • ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិត<br>• ការអប់រំកុមារី និងការប្រែប្រួលអាកាសធាតុ<br>• ការស្រាវជ្រាវស៊ីជម្រៅអំពីលទ្ធភាពរបស់កុមារ និងយុវជនដែលមានពិការភាពក្នុងការចូលរៀន<br>• បញ្ហាប្រឈមជនជាតិភាគតិចវៀតណាមក្នុងវិស័យអប់រំ និងកែលម្អការអប់រំ<br>• អ្នកស្រឡាញ់ភេទដូចគ្នា លើការអប់រំ និងក្រោយការបណ្តុះបណ្តាល។<br>• ស្រាវជ្រាវអន្តរកម្ម និងបញ្ហាប្រឈមរបស់ជនជាតិដើមភាគតិចខេត្តរតនគិរី |

| | |
|---|---|
| | • ការអប់រំផ្លាស់ប្តូរយេនឌ័រនៅសាលាបឋមសិក្សា និងអនុវិទ្យាល័យ។ |
| ភាសា និងវប្បធម៌ | • សិក្សាអំពីភាសាជនជាតិដើមភាគតិច និងវប្បធម៌ប្រពៃណីរបស់ពួកគេ<br>• កម្មវិធីអប់រំពហុភាសា |
| ការវាយតម្លៃគម្រោង | • ស្រាវជ្រាវលើគម្រោងចុងគ្រាដើម្បីវាយតម្លៃពីផលប៉ះពាល់នៃការអនុវត្ត<br>• ការវាយតម្លៃគម្រោង។ |

***សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីប្រធានបទស្រាវជ្រាវទាំងនេះ NGOs និងថវិកា សូមមើល៖***

***ឧបសម្ព័ន្ធទី ២៖ ការអនុវត្តថវិកាជាក់លាក់សម្រាប់ការស្រាវជ្រាវ/សិក្សា និងបណ្តុះបណ្តាល***

## ៣) ជំនាញឯកទេស

ទាក់ទងនឹងជំនាញរបស់បុគ្គលិកមកពីNGOsដែលឆ្លើយសំណួរ គឺដូចខាងក្រោម៖

| ផ្នែកជំនាញ | ចំនួនអង្គការ | ឈ្មោះអង្គការ (ពាក្យកាត់) |
|---|---|---|
| ការអប់រំថែទាំកុមារតូច | ២១ | SCI, PE&D, RTI, COCD, CCAFO, VVOB, FH-Cambodia, BK, KrY, RSO, HI, អង្គការមិត្តសំឡាញ់, ISF, SIPAR, CCF, PLAN, IIC, GNC, OEC, KNGO, CORDE |
| ការអប់រំបឋមសិក្សា | ២៨ | SCI, TDSO, CRF, OCCO, AREDOC, WE, COCD, SCO, CARE, VVOB, FH-Cambodia, SP, BK, WVI, RTI-IPEA, CTOD, HI, CRFO, RtR, អង្គការមិត្តសំឡាញ់, ISF, SIPAR, CCF, PLAN, KCD, ICC, OEC, KNGO |
| ការអប់រំមធ្យមសិក្សា | ២០ | TDSO, CRF, WE, COCD, SCO, CARE, VVOB, FH-Cambodia, SP, VSO, BK, CTOD, AARJ, EYC, RtR, TLC, ISF, SIPEAR, CCF, MCC |
| ការអប់រំបរិយាបន្ន | ១៦ | CRF, NTFP, RTI, SVC, WE, CARE, BK, RTI-IPEA, CTOD, AARJ, RSO, HI, EA, RAO, UWS, ICC |
| ការបណ្តុះបណ្តាលគ្រូបង្រៀន | ២៤ | TDSO, CRF, NTFP, RTI, WE, SCO, CARE, VVOB, FH-Cambodia, VSO, BK, WVI, RTI-IPEA, AARJ, RSO, EYC, TLC, អង្គការមិត្តសំឡាញ់, SIPEAR, CCF, EA, KCD, ICC, CORDE |
| យេនឌ័រ | ២៥ | SCI, CRF, NTFP, PE&D, RTI, KYA, SVC, WE, SCO, CARE, VVOB, FH-Cambodia, SP, BK, CTOD, CRF, TLC, អង្គការមិត្តសំឡាញ់, ISF, PLAN, KCD, UWS, ICC , BLCP, OEC |
| ការតស៊ូមតិ | ១៩ | SCI, CRC-Cambodia, KYA, SVC, COCD, CARE, BK, WVI, RTI-IPEA, CTOD, អង្គការមិត្តសំឡាញ់, EA, PLAN, RAO, UWS, ICC, AusCam, BLCP, OEC |
| ការស្រាវជ្រាវ | ២៥ | SCI, CRF, CRC-Cambodia, RTI, KYA, SVC, WE, CARE, VVOB, FH-Cambodia, SP, VSO, BK, RTI-IPEA, CTOD, HI, CRF, អង្គការមិត្តសំឡាញ់, SIPAR, CCF, PLAN, ICC, GNC, BLCP, OEC |
| ការអប់រំពិសេស | ៧ | SCI, BK, RTI-IPEA, RSO, SIPAR, EA, KCD |
| ការងារសង្គមកិច្ច | ២ | PE&D, KT |
| ការសិក្សា និងអប់រំសម្រាប់មនុស្សពេញវ័យ | ១ | DVVI |
| វិន័យបែបវិជ្ជមាន | ១ | COCD |
| ភាសាអង់គ្លេស | ១ | CCAFO |

| | | |
|---|---|---|
| ប្រឹក្សាគរុកោសល្យ, STEM, ការរៀនកម្រិតថ្នាក់ដំបូង ការបង្ហាត់បង្រៀន ការរៀន/វិធីសាស្ត្ររួមបញ្ចូល | ១ | VVOB |
| ការគ្រប់គ្រងតាមសាលារៀន | ១ | RTI-IPEA |
| សុខភាពមាតា និងទារក និងទឹកស្អាត-អនាម័យ | ១ | HI |
| ធុរកិច្ចសង្គមខាងរបាំសហសម័យ | ១ | EA |
| ការអប់រំឧត្តមសិក្សា | ១ | LOC |
| ការអភិវឌ្ឍន៍សហគមន៍ | ១ | MCC |
| ការគ្រប់គ្រងករណី ការប្រឹក្សាអាជីព ការអភិវឌ្ឍន៍អ្នកស្រាវជ្រាវកុមារ | ១ | AusCam |
| ទឹកស្អាតអនាម័យ សុខភាពមាត់ធ្មេញ ការអភិវឌ្ឍន៍សាលារៀន | ១ | BLCP |

## ៤) បញ្ហាប្រឈមរបស់NGOsក្នុងការធ្វើផែនទី

ផ្អែកតាមលទ្ធផលនៃការធ្វើផែនទី NGOs បានរាយការណ៍ពីបញ្ហាប្រឈមដែលបានជួបប្រទះដូចជា៖

តារាងទី ៦៖ បញ្ហាប្រឈមរបស់NGOsដែលឆ្លើយសំណួរក្នុងការបង្កើតផែនទី



**១. ឧបសគ្គផ្នែកហិរញ្ញវត្ថុ៖** ត្រូវបានរាយការណ៍ដោយអង្គការចំនួន៤៥។ បញ្ហានេះនៅតែជាឧបសគ្គដ៏ចម្បងបំផុតទាំងចំពោះរដ្ឋាភិបាល និងNGOs។ ថវិកាអប់រំរបស់រដ្ឋាភិបាលនៅមានកម្រិត៖ បើតាមការប្រៀបធៀប កម្ពុជាចំណាយតិចជាងប្រទេសជិតខាងទៅលើសិស្សម្នាក់ៗ។ មួយភាគធំនៃថវិកានេះគឺសម្រាប់ចំណាយលើប្រាក់បៀវត្សរ៍គ្រូបង្រៀន ដែលនៅសល់ធនធានតិចតួចសម្រាប់កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈ។ រដ្ឋាភិបាលអាចនឹងមានការពិបាកក្នុងការបែងចែកថវិកាគ្រប់គ្រាន់លើគំនិតផ្តួចផ្តើម បណ្តុះបណ្តាលទ្រង់ទ្រាយធំ ឬផ្តល់ការគាំទ្របន្តលើការអភិវឌ្ឍន៍គ្រូបង្រៀន។ ការផ្តល់មូលនិធិសម្រាប់NGOs៖ អង្គការជាច្រើនពឹងផ្អែកយ៉ាងខ្លាំងលើការផ្តល់មូលនិធិពីម្ចាស់ជំនួយដើម្បីជួយទ្រទ្រង់ពួកគេ។ បញ្ហានេះអាចនាំឱ្យមានភាពមិនប្រាកដប្រជា និងមិនស៊ីសង្វាក់គ្នាក្នុងការផ្តល់មូលនិធិដែលបង្កការលំបាកចំពោះអង្គការ ក្នុងការរៀបចំផែនការរយៈពេលវែង និងផ្តល់កម្មវិធីប្រកបដោយនិរន្តរភាព។

**អនុសាសន៍៖**

- បង្កើនការវិនិយោគរបស់រដ្ឋាភិបាល៖ ធ្វើការតស៊ូមតិ ដើម្បីបង្កើនការបែងចែកថវិការបស់រដ្ឋាភិបាលលើកម្មវិធីអប់រំ
- ការធ្វើពិពិធកម្មប្រភពមូលនិធិ៖ NGOs អាចស្វែងរកប្រភពមូលនិធិជំនួសក្រៅពីម្ចាស់ជំនួយបែបប្រពៃណី ដូចជាភាពជាដៃគូរវាងរដ្ឋ និងឯកជន ឬយន្តការហិរញ្ញប្បទានប្រកបដោយនវានុវត្តភាព
- គំរូបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាពថ្លៃដើម៖ ការបង្កើត និងអនុវត្តគំរូបណ្តុះបណ្តាលដែលមានប្រសិទ្ធភាពថ្លៃដើម សម្រាប់ការអភិវឌ្ឍន៍វិជ្ជាជីវៈប្រកបដោយគុណភាពខ្ពស់ក្នុងកម្រិតថវិកា
- ផ្តោតលើនិរន្តរភាព៖ ការរៀបចំកម្មវិធីដែលមាននិរន្តរភាពរយៈពេលវែង ជាសក្តានុពលតាមរយៈការរួមបញ្ចូលគ្នានៃប្រភពមូលនិធិ ឬការកសាងសមត្ថភាពរបស់ស្ថាប័នក្នុងស្រុក។

**២. ឧបសគ្គខាងគោលនយោបាយ និងបទប្បញ្ញត្តិ៖** ជាបញ្ហាប្រឈមរបស់NGOsចំនួន១៣ ។ គោលនយោបាយ និងបទប្បញ្ញត្តិរបស់រដ្ឋាភិបាល អាចជាឧបសគ្គរាំងNGOs ដូចជាការស្នើសុំការអនុញ្ញាតពីក្រសួង ឬថ្នាក់លើ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល៖ ដំណើរការចុះឈ្មោះដែលអូសបន្លាយពេលយូរ អាចរាំងដល់NGOsថ្មីដែលផ្តោតលើការអប់រំ ក្នុងការបង្កើតអង្គការ និងចាប់ផ្តើមធ្វើការបានឆាប់រហ័ស។ ប្រការនេះអាចនាំឱ្យមានការយឺតយ៉ាវក្នុងការផ្តួចផ្តើមកម្មវិធីអប់រំសំខាន់ៗសម្រាប់សិស្សដែលខ្វះខាតមុនពេលផ្តល់កម្មវិធី និងអនុវត្តដែលអាចប៉ះពាល់ដល់ប្រតិបត្តិការរបស់អង្គការ និងបង្រួមការអនុវត្តកម្មវិធី។ លើសពីនេះ ដែនកំណត់នៃភាពបត់បែន គោលនយោបាយ និងបទប្បញ្ញត្តិមួយចំនួន អាចបង្រួមការច្នៃប្រឌិត និងនវានុវត្តភាពដែលNGOsអាចមានក្នុងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈរបស់ខ្លួន។ ម្យ៉ាងវិញទៀត កង្វះគោលការណ៍ណែនាំច្បាស់លាស់៖ គោលការណ៍ណែនាំរបស់រដ្ឋាភិបាលដែលមិនមានភាពច្បាស់លាស់ ឬមិនស៊ីសង្វាក់គ្នា អាចធ្វើឱ្យNGOsមានការលំបាកក្នុងការស្វែងយល់ និងអនុវត្តតាមការគ្រោងទុក ជាហេតុនាំឱ្យមានការយឺតយ៉ាវ ឬអប្រសិទ្ធភាព។

**អនុសាសន៍៖**

- សម្រួលដំណើរការផ្តល់ការអនុម័ត៖ សហការជាមួយរដ្ឋាភិបាល ដើម្បីសម្រួលដល់ដំណើរការអនុម័តលើកម្មវិធីNGOs

- បង្កើនកិច្ចសន្ទនា និងកិច្ចសហការ៖ ការប្រាស្រ័យទាក់ទង និងការសហការជាទៀងទាត់រវាង NGOs និងក្រសួងស្ថាប័ន ដើម្បីធានាថាគោលនយោបាយ និងបទប្បញ្ញត្តិនឹងគាំទ្រដល់គំនិតផ្តួចផ្តើមអភិវឌ្ឍន៍វិជ្ជាជីវៈប្រកបដោយប្រសិទ្ធភាព
- ការតស៊ូមតិដើម្បីឱ្យមានភាពបត់បែន៖ NGOsដែលធ្វើការតស៊ូមតិលើគោលនយោបាយឱ្យមានភាពបត់បែនកាន់តែច្រើនថែមទៀត ដើម្បីអនុញ្ញាតឱ្យមានការច្នៃប្រឌិត និងការសម្របសម្រួលផ្អែកតាមតម្រូវការ និងបរិបទជាក់លាក់។

**៣. ដែនកំណត់នៃលទ្ធភាពអាចទៅដល់សម្រាប់សហគមន៍ជនបទដាច់ស្រយាល ឬសហគមន៍បាត់បង់ ឱកាសក្នុងសង្គម៖** មានNGOs ចំនួន២៣ បានរាយការណ៍ថា ពួកគេមានប្រឈមក្នុងការចុះទៅកាន់សហគមន៍ជនបទដាច់ស្រយាល ឬសហគមន៍បាត់បង់ឱកាសក្នុងសង្គម។ ការចុះទៅកាន់តំបន់ជនបទដាច់ស្រយាលអាចមានការលំបាកដោយសារតែកង្វះហេដ្ឋារចនាសម្ព័ន្ធ និងជម្រើសនៃមធ្យោបាយធ្វើដំណើរ។ បញ្ហានេះបង្កើនការចំណាយលើការអនុវត្តកម្មវិធីអប់រំនៅក្នុងសហគមន៍ទាំងនេះ។ លើសពីនេះ ការចំណាយបន្ថែមទាក់ទងនឹងការចុះទៅកាន់តំបន់ដាច់ស្រយាល អាចធ្វើឱ្យប៉ះពាល់ដល់ថវិកាដ៏ស្ដួចស្ដើងរួចជាស្រាប់របស់NGOs។ ម្យ៉ាងវិញទៀត បទដ្ឋានខាងវប្បធម៌ និងទំនៀមទំលាប់នៅក្នុងសហគមន៍ដែលបាត់បង់ឱកាសមួយចំនួន អាចទាមទារឱ្យមានវិធីសាស្ត្រខុសៗគ្នាក្នុងការរៀបចំ និងអនុវត្តកម្មវិធី។

**អនុសាសន៍៖**

- សហការជាមួយNGOsក្នុងស្រុក ឬអង្គការសហគមន៍ដែលមានការយល់ដឹងច្បាស់អំពីតម្រូវការ និងបរិបទជាក់លាក់នៃសហគមន៍ជនបទដាច់ស្រយាល
- ស្វែងយល់ពីការប្រើប្រាស់ដំណោះស្រាយសម្រាប់ការបណ្តុះបណ្តាលដោយប្រើបច្ចេកវិទ្យា ដូចជាម៉ូឌុលអនឡាញ ឬសន្និសីទវីដេអូ ដើម្បីផ្សព្វផ្សាយទៅដល់ទីតាំងដាច់ស្រយាល
- បង្កើតកម្មវិធីដែលគិតគូរអំពីវប្បធម៌ និងដោះស្រាយបញ្ហាប្រឈម និងឱកាសពិសេសដែលប្រឈមមុខដោយសហគមន៍ជនបទដាច់ស្រយាល ឬសហគមន៍បាត់បង់ឱកាសក្នុងសង្គម។

**៤. កង្វះហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់៖** ត្រូវបានរាយការណ៍ដោយNGOsចំនួន ១៧។ កង្វះសម្ភារបរិក្ខារ និងធនធានមូលដ្ឋាននៅតាមសាលារៀនដូចជា កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំងស្លាយ និងបណ្តាញអ៊ីនធឺណិតជាឧបសគ្គរារាំងដល់ការដាក់ពង្រាយកម្មវិធីដែលត្រូវការបច្ចេកវិទ្យា ឬធនធានឯកទេសផ្សេងទៀត។ បញ្ហានេះអាចកម្រិតលើវិធីសាស្ត្រដែលអង្គការអាចប្រើ និងអាចកាត់បន្ថយប្រសិទ្ធភាពរបស់កម្មវិធី។ ទន្ទឹមនឹងនោះ ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ អាចមានការថែទាំមិនបានល្អ ឬចាស់មិនទាន់សម័យ ដែលរារាំងដល់ការអនុវត្តកម្មវិធីបណ្តុះបណ្តាលបន្ថែមទៀត។ កំហូចបរិក្ខារ ឬការតភ្ជាប់អ៊ីនធឺណិតមិនទៀងទាត់ អាចបង្កការរំខានដល់កម្មវិធីបណ្តុះបណ្តាល និងមិនមានការសារទរពីសិក្ខាកាម។

**អនុសាសន៍៖**

- NGOsអាចធ្វើការជាមួយរដ្ឋាភិបាល ម្ចាស់ជំនួយ ឬវិស័យឯកជន ដើម្បីទទួលបានមូលនិធិសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងការចែកចាយសម្ភារ និងធនធានដែលត្រូវការជាចាំបាច់

- បង្កើតកម្មវិធីដែលមិនសូវពឹងផ្អែកលើបច្ចេកវិទ្យា ហើយអាចដំណើរការដោយប្រសិទ្ធភាពជាមួយនឹងធនធានតិចតួច។ ប្រការនេះអាចពាក់ព័ន្ធនឹងការប្រើប្រាស់វិធីសាស្ត្របែបប្រពៃណីជាច្រើនទៀតដូចជា បាឋកថា ការពិភាក្សាជាក្រុម និងសកម្មភាពអនុវត្តជាក់ស្តែងដែលប្រើប្រាស់សម្ភារដែលងាយស្រួលរក
- តាមដែលអាចធ្វើទៅបាន NGOsអាចផ្តល់ការងារបន្ថែមលើដំណើរការធ្វើសមាហរណកម្មបច្ចេកវិទ្យានៅតាមសាលារៀនប្រកបដោយប្រសិទ្ធភាព ទោះបីជាធនធាននៅមានកម្រិតក៏ដោយ។ ការធ្វើបែបនេះអាចជួយទាញយកប្រយោជន៍យ៉ាងច្រើនពីបច្ចេកវិទ្យាដែលមាន និងរៀបចំអនាគតជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធកាន់តែប្រសើរឡើង។

**៥. កង្វះគ្រូបង្រៀន និងការព្រួយបារម្ភអំពីគុណភាព៖** ត្រូវបានរាយការណ៍ដោយNGOs ចំនួន២៤។ កង្វះគ្រូបង្រៀនជាពិសេសនៅតំបន់ជនបទ គឺជាបញ្ហាប្រឈមមួយចំពោះNGOs ក្នុងការស្វែងរកអ្នកចូលរួមកម្មវិធីឱ្យបានគ្រប់គ្រាន់។ បញ្ហានេះដាក់កម្រិតលើការគ្របដណ្តប់ និងផលប៉ះពាល់ជារួមនៃគំនិតផ្តួចផ្តើមទាំងនេះ។ លើសពីនេះទៀត ការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ គឺជាមូលដ្ឋានគ្រឹះនៃការពង្រឹង កែលម្អចំណេះដឹង និងជំនាញរបស់គ្រូបង្រៀនដែលអាចនាំឱ្យពួកគេទទួលបានការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ ក្នុងការអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗប្រកបដោយប្រសិទ្ធភាពតាមរយៈកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈ និងគំនិតផ្តួចផ្តើមថ្មីៗពីក្រសួង។

**អនុសាសន៍៖**

- សហការជាមួយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន លើការកែលម្អកម្មវិធីបណ្តុះបណ្តាលសម្រាប់គ្រូដែលកំពុងបង្រៀន និងគរុសិស្ស និងធានាថាពួកគេត្រូវបានបំពាក់បំប៉ននូវជំនាញ និងចំណេះដឹងដែលត្រូវការជាចាំបាច់
- ផ្តល់អាទិភាពលើការបណ្តុះបណ្តាលគ្រូបង្រៀននៅតំបន់ជនបទ ដើម្បីដោះស្រាយតម្រូវការរបស់គ្រូបង្រៀននៅតាមជនបទ ឬអ្នកដែលទទួលបានការបណ្តុះបណ្តាលតិចតួច
- ផ្តល់ការលើកទឹកចិត្តដូចជា ប្រាក់ឧបត្ថម្ភ ឬការទទួលស្គាល់វិជ្ជាជីវៈ (អត្តសញ្ញាណគ្រូបង្រៀន និងស្ថានភាពសង្គម) ដើម្បីលើកទឹកចិត្តឱ្យគ្រូបង្រៀនចូលរួមនៅក្នុងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈ ជាពិសេសនៅក្នុងតំបន់ដែលខ្វះខាត។ យុទ្ធនាការលើកកម្ពស់អត្តសញ្ញាណគ្រូបង្រៀនគប្បីធ្វើឡើងរួមគ្នារវាងក្រសួងអ.យ.ក និងNGOsពាក់ព័ន្ធ។

**៦. កត្តាសង្គម-វប្បធម៌៖** ត្រូវបានរាយការណ៍ដោយNGOsចំនួន១៨។ វិធីសាស្ត្របង្រៀនបែបប្រពៃណី៖ បទដ្ឋានវប្បធម៌ដែលបានចាក់ឫសគល់យ៉ាងជ្រៅ និងការរំពឹងទុកជុំវិញវិធីសាស្ត្របង្រៀន អាចរារាំងដល់ការប្រកាន់យកវិធីសាស្ត្រថ្មីដែលបានដាក់ចេញតាមរយៈកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈ។ ឧបសគ្គខាងភាសាក៏អាចរារាំងដល់ការប្រាស្រ័យទាក់ទង និងការយល់ដឹងរវាងNGOs គ្រូបង្រៀន និងសិស្សផងដែរ ជាពិសេសនៅក្នុងបរិបទពហុភាសា។

**អនុសាសន៍៖**

- ពិចារណារៀបចំកម្មវិធីដែលគិតគូរពីវប្បធម៌ប្រពៃណីក្នុងស្រុកតាមករណីសមស្រប
- រៀនសូត្រពីករណីសិក្សា ដោយប្រើឧទាហរណ៍ និងករណីសិក្សាដែលពាក់ព័ន្ធនឹងបរិបទ និងដោះស្រាយបញ្ហាប្រឈម និងឱកាសជាក់លាក់

- ផ្តល់កម្មវិធីជាភាសាក្នុងស្រុកតាមដែលអាចធ្វើទៅបាន ដើម្បីជម្នះលើឧបសគ្គខាងភាសា និងជួយសម្រួលដល់ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។

**៧. ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃមិនគ្រប់គ្រាន់៖** ត្រូវបានរាយការណ៍ដោយNGOsចំនួន២០ ។ ពួកគេខ្វះធនធាន ឬជំនាញក្នុងការអភិវឌ្ឍន៍ និងអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ (M&E) ដ៏រឹងមាំសម្រាប់កម្មវិធី។ ការប្រមូល និងវិភាគទិន្នន័យមិនគ្រប់គ្រាន់ ធ្វើឱ្យមានការលំបាកក្នុងការវាស់វែងផលប៉ះពាល់នៃកម្មវិធី និងកំណត់ផ្នែកដែលត្រូវធ្វើការកែលម្អ។

**អនុសាសន៍៖**

- កសាងសមត្ថភាពក្នុងការត្រួតពិនិត្យ និងវាយតម្លៃ (M&E)៖ ផ្តល់ការបណ្តុះបណ្តាល និង គាំទ្រដល់NGOs ក្នុងការអភិវឌ្ឍន៍ និងអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់កម្មវិធីអភិវឌ្ឍន៍
- សហការជាដៃគូជាមួយស្ថាប័នស្រាវជ្រាវ ដើម្បីធ្វើការវាយតម្លៃល្អិតល្អន់បន្ថែមទៀតលើប្រសិទ្ធភាពនៃកម្មវិធីបណ្តុះបណ្តាលដែលដឹកនាំដោយNGOs
- បង្កើតក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃស្របតាមបទដ្ឋានបរិបទជាក់លាក់នៃប្រទេសកម្ពុជាដើម្បីសម្រួលដល់ការប្រមូល និងវិភាគទិន្នន័យ។ ក្របខណ្ឌនេះអាចត្រូវបានប្រើនៅទូទាំងបណ្តាញ
- បង្កើតប្រព័ន្ធត្រួតពិនិត្យការអប់រំចម្រុះរួម ដើម្បីទាញយកសមិទ្ធផលរបស់NGOsដែលធ្វើការលើវិស័យអប់រំ។

**៨. វិសមភាព និងភាពខុសគ្នា៖** បញ្ហាប្រឈមនេះត្រូវបានរាយការណ៍ដោយNGOsចំនួន០៦ ។ សិស្សកម្ពុជាជាច្រើនមិនមានឱកាសស្មើគ្នាក្នុងការរៀនសូត្រ ដោយសារតែគម្លាតផ្នែកធនធានដូចជា កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំងស្លាយ និងបណ្ណាល័យជាដើម។ វាក៏អាចបណ្តាលមកពីបទពិសោធន៍ និងសមត្ថភាពរបស់គ្រូបង្រៀនផងដែរ។ គម្លាតរវាងតំបន់ទីក្រុង និងជនបទ៖ សាលារៀននៅតាមទីក្រុង ជារឿយៗមានលទ្ធភាពទទួលបានកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈសម្រាប់គ្រូបង្រៀនច្រើនជាងសាលានៅតាមជនបទ។ សិស្សរៀននៅសាលា/តំបន់ដែលជួបការលំបាក អាចមានឱកាសតិចតួចក្នុងការរៀនសូត្រប្រកបដោយប្រសិទ្ធភាព ដោយសារតែកង្វះខាតគ្រូបង្រៀនដែលមានការបណ្តុះបណ្តាលល្អ និងធនធានតិចតួច។ មានគម្លាតកាន់តែធំលើគុណភាពនៃការអប់រំរវាងសាលាដែលមានគុណប្រយោជន៍ និងសាលាដែលជួបការលំបាក ធ្វើឱ្យមានវដ្តនៃវិសមភាព។ ភាពមិនស្មើគ្នាក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពដាក់កម្រិតលើឱកាសនាពេលអនាគតរបស់សិស្ស ធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការទទួលបានការអប់រំឧត្តមសិក្សា ឬការងារល្អប្រសើរ។

**អនុសាសន៍៖**

- ផ្តល់អាទិភាពលើកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈសម្រាប់គ្រូបង្រៀននៅតាមសាលារៀនដែលជួបការលំបាក និងតំបន់ជនបទ សម្រាប់ការបណ្តុះបណ្តាលបន្ថែម សិក្ខាសាលា ឬឱកាសសិក្សាតាមអ៊ីនធឺណិត
- តស៊ូមតិគោលនយោបាយ ដើម្បីលើកកម្ពស់ការចែកចាយធនធានកាន់តែប្រកបដោយសមធម៌នៅទូទាំងប្រព័ន្ធអប់រំ រួមទាំងការបង្កើនមូលនិធិរបស់រដ្ឋាភិបាលសម្រាប់សាលារៀននៅក្នុងតំបន់ដែលខ្វះខាត ឬគំនិតផ្តួចផ្តើមនានា ដើម្បីធានាថាសាលារៀនទាំងអស់មានលទ្ធភាពទទួលបានធនធានមូលដ្ឋានចាំបាច់សម្រាប់ការរៀនសូត្រប្រកបដោយប្រសិទ្ធភាព

- បង្កើតកម្មវិធីអាហារូបករណ៍ និងលើកទឹកចិត្ត ដើម្បីទាក់ទាញនិងរក្សាទុកគ្រូបង្រៀនដែលមានសមត្ថភាពនៅសាលាដែលជួបការលំបាក ដោយរួមបញ្ចូលទាំងការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ប្រាក់ឧបត្ថម្ភកន្លែងស្នាក់នៅ ឬឱកាសសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ និងការរីកចម្រើនអាជីព
- សហការជាដៃគូជាមួយNGOsក្នុងស្រុក ឬអង្គការសហគមន៍ដែលមានការយល់ដឹងស៊ីជម្រៅអំពីតម្រូវការជាក់លាក់របស់សាលារៀននៅក្នុងមូលដ្ឋានរបស់ខ្លួន និងស្វែងរកឱកាសផ្តល់មូលនិធិគាំទ្រសាលារៀនដែលជួបការលំបាក
- ស្វែងយល់ពីការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីភ្ជាប់គម្លាតរវាងសាលារៀននៅទីក្រុង និងសាលារៀននៅជនបទ។ ករណីនេះអាចពាក់ព័ន្ធនឹងម៉ូឌុលបណ្តុះបណ្តាលតាមអនឡាញ សន្និសីទ វីដេអូសម្រាប់កម្មវិធីពីចម្ងាយ ឬការផ្តល់ឧបករណ៍ចល័តដែលមានផ្ទុកធនធានបង្រៀនរួចជាស្រាប់ដល់សាលានៅតាមជនបទ។

**៩. បញ្ហាប្រឈមនៃការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ៖** មានNGOsចំនួន ១២ បានរាយការណ៍ថាបានជួបប្រទះប្រឈមនឹងការសម្របសម្រួល និងការសហការ។ វិស័យអប់រំនៅកម្ពុជា មានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើនដែលមានអាទិភាព និងវិធីសាស្ត្រផ្សេងៗគ្នា។ ប្រការនេះអាចបង្កការលំបាកដល់NGOs ក្នុងការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងជៀសវាងការអនុវត្តត្រួតគ្នា។ ការទំនាក់ទំនង និងចែករំលែកព័ត៌មានមិនគ្រប់គ្រាន់រវាងNGOs រដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងទៀត អាចរារាំងដល់កិច្ចសហការ និងធ្វើឱ្យខកខានឱកាសសម្រាប់ការផ្តួចផ្តើមគំនិតរួមគ្នា។

**អនុសាសន៍៖**

- ថ្នាល និងវេទិកាអ្នកពាក់ព័ន្ធ៖ ការពង្រឹងវេទិកាដែលមានស្រាប់សម្រាប់កិច្ចសន្ទនា និងកិច្ចសហការជាប្រចាំក្នុងចំណោមNGOs រដ្ឋាភិបាល ស្ថាប័ន និងភាគីពាក់ព័ន្ធផ្សេងៗនៅក្នុងវិស័យអប់រំ។ PESWG គួរតែដើរតួនាទីជាវេទិកាមួយសម្រាប់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅតាមបណ្តាខេត្ត ដើម្បីពិភាក្សាអំពីការសម្របសម្រួល និងកិច្ចសហការ
- ធ្វើការវាយតម្លៃរួមគ្នាលើតម្រូវការរបស់សាលា និងបង្កើតកម្មវិធីសហការដើម្បីធានាដោះស្រាយបញ្ហាអាទិភាពសំខាន់ៗនៅក្នុងប្រព័ន្ធអប់រំ
- បង្កើតយន្តការផ្តល់ចំណេះដឹង និងការអនុវត្តល្អៗ និងចែករំលែកក្នុងចំណោមភាគីពាក់ព័ន្ធដែលកំពុងធ្វើការក្នុងវិស័យអប់រំ។ ការកសាងវប្បធម៌សិក្សាក្នុងចំណោមភាគីពាក់ព័ន្ធ គឺជាការចាំបាច់ណាស់។ NEP គួរតែដឹកនាំការបង្កើតក្របខណ្ឌសិក្សា និងកៀរគរភាគីពាក់ព័ន្ធនានាដើម្បីឆ្លុះបញ្ចាំងការងាររបស់ខ្លួន ខណៈដែលសន្និសីទជាតិរបស់ NEP គឺជាវេទិកាសន្ទនាគោលនយោបាយមួយដែលភាគីពាក់ព័ន្ធអាចចែករំលែកលទ្ធផលដែលខ្លួនបានរកឃើញ។

**១០. ការផ្លាស់ប្តូរបរិបទនយោបាយ៖** NGOsចំនួន ០៧ បានរាយការណ៍ថា អស្ថិរភាពនយោបាយ និងជម្លោះខាងនយោបាយ អាចរំខានដល់គំនិតផ្តួចផ្តើមក្នុងវិស័យអប់រំ និងបង្កការលំបាកដល់អង្គការក្នុងការធ្វើប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពក្នុងវិស័យមួយចំនួន។

**អនុសាសន៍៖**

- រៀបចំកម្មវិធីដែលមានភាពបត់បែន និងអាចសម្របទៅនឹងការប្រែប្រួលបរិបទ ហើយអាចអនុវត្តបានទោះបីជាមានការប្រឈមមុខនឹងការរំខានក៏ដោយ
- សហការជាមួយអង្គការក្នុងស្រុកដែលយល់ដឹងច្បាស់អំពីស្ថានភាពសន្តិសុខជាក់លាក់ និងអាចជួយតម្រង់ទិសបញ្ហាប្រឈមនៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយជម្លោះ។

**១១. ការចូលរួមរបស់ភាគីពាក់ព័ន្ធ៖** តាមរយៈការបង្កើតផែនទី NGOsចំនួន ២៤ បានប្រឈមមុខនឹងបញ្ហានៃការចូលរួមតិចតួចពីសំណាក់ភាគីពាក់ព័ន្ធ។ ការចូលរួមមិនគ្រប់គ្រាន់ពីសំណាក់ភាគីពាក់ព័ន្ធសំខាន់ៗដូចជា អាណាព្យាបាល សមាជិកសហគមន៍ សាលារៀន និងអាជ្ញាធរ អាចបង្រួមប្រសិទ្ធភាព និងនិរន្តរភាពនៃការអនុវត្តកម្មវិធី។

**អនុសាសន៍៖**

- NEP និងPESWG ដឹកនាំបង្កើតយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយដើម្បីជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធ ដើម្បីធានាថាមានការចូលរួមពីគ្រប់តួអង្គសំខាន់ៗនៅក្នុងការរៀបចំ អនុវត្ត និង វាយតម្លៃ
- ស្វែងរកវិធីសាស្ត្រសម្រាប់អនុវត្តនៅតាមសហគមន៍មូលដ្ឋាន ដែលលើកកម្ពស់ចំណេះដឹង និងធនធានរបស់សហគមន៍មូលដ្ឋាន ដើម្បីគាំទ្រដល់ការអនុវត្ត
- ផ្តល់ឱកាសក្នុងការកសាងសមត្ថភាពសម្រាប់ភាគីពាក់ព័ន្ធដូចជា ថ្នាក់ដឹកនាំសាលា និងអាណាព្យាបាល ដើម្បីបំប៉នជំនាញ និងចំណេះដឹងរបស់ពួកគេសម្រាប់គាំទ្រកម្មវិធីផ្តួចផ្តើមនានា។

### ៥) ការបណ្តុះបណ្តាលដែលមានស្រាប់តាមរយៈNGOs

ផ្អែកតាមតារាង មានការបណ្តុះបណ្តាលជាច្រើនដែលនឹងត្រូវផ្តល់ជូនក្រុមការងារនៅក្នុងរង្វង់NGOs ហើយក៏នឹងផ្តល់ជូនដៃគូ និងក្រុមគោលដៅរបស់ខ្លួនផងដែរ។ ប្រធានបទនៃការអប់រំបណ្តុះ បណ្តាលមានដូចខាងក្រោម៖

តារាងទី ៧៖ ការបណ្តុះបណ្តាលនឹងធ្វើឡើងដោយNGOsដែលឆ្លើយសំណួរ



១. **ផ្នែកគរុកោសល្យ** (NGOs ១៧)៖ ការបណ្តុះបណ្តាលប្រភេទនេះគ្របដណ្តប់លើវិធីសាស្ត្របង្រៀន និងយុទ្ធសាស្ត្រជាច្រើនដែលអាចដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សា។

២. **មុខជំនាញជាក់លាក់** (NGOs ២០)៖ សំដៅលើការបណ្តុះបណ្តាលលើមុខជំនាញជាក់លាក់ណាមួយ ដូចជាភាសាខ្មែរ គណិតវិទ្យា សិក្សាសង្គម វប្បធម៌ វិទ្យាសាស្ត្រ និងផ្សេងៗ។

៣. **សមាហរណកម្មបច្ចេកវិទ្យា** (NGOs ១៧)៖ ការបណ្តុះបណ្តាលនេះនឹង ផ្តោតលើការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាពសម្រាប់ការរៀន និងបង្រៀនដោយប្រើបច្ចេកវិទ្យា ICT និងវេទិកាបច្ចេកវិទ្យាផ្សេងទៀត។

៤. **ការអប់រំបរិយាបន្ន** (NGOs ២០)៖ គ្របដណ្តប់លើវិធីសាស្ត្របង្កើតបរិយាកាសសិក្សាបរិយាបន្នសម្រាប់សិស្សដែលមានពិការភាព និងមានតម្រូវការពិសេស។

៥. **ការពិនិត្យ និងវាយតម្លៃ** (NGOs ១៩)៖ ការបណ្តុះបណ្តាលលើការពិនិត្យ និងវាយតម្លៃគ្របដណ្តប់លើវិធីសាស្ត្រវាយតម្លៃការសិក្សា និងវឌ្ឍនភាពរបស់សិស្ស ការពិនិត្យ/វាយតម្លៃគម្រោង និងគោលបំណងផ្សេងៗ។

៦. **ការគ្រប់គ្រងថ្នាក់រៀន** (NGOs ១៧)៖ ការបណ្តុះបណ្តាលប្រភេទនេះទាក់ទងនឹងយុទ្ធសាស្ត្ររក្សាឱ្យមានបរិយាកាសសិក្សាប្រកបដោយភាពវិជ្ជមាន និងផលិតភាពក្នុងថ្នាក់រៀន ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងថ្នាក់សម្រាប់សិស្ស ដោយទទួលបានលទ្ធផលល្អ និងបង្កើនលទ្ធផលសិក្សា។

៧. **ការអភិវឌ្ឍន៍វិជ្ជាជីវៈ និងភាពជាអ្នកដឹកនាំ** (NGOs ២៩)៖ ផ្តោតលើការអភិវឌ្ឍន៍ជំនាញភាពជាអ្នកដឹកនាំសម្រាប់អ្នកអប់រំ និងផ្តល់ការគាំទ្រដល់គ្រូបង្រៀន។

៨. **ការសិក្សាពីសង្គម និងអារម្មណ៍ (SEL)** (NGOs ១០)៖ មានគោលបំណងកសាងជំនាញអ្នកអប់រំដើម្បីគ្រប់គ្រងអារម្មណ៍ផ្ទាល់ខ្លួន និងបង្កើតបរិយាកាសសិក្សាជាវិជ្ជមានសម្រាប់សិស្ស និងអ្នកទទួលផលគោលដៅផ្សេងទៀត។

៩. **ការសិក្សាផ្អែកលើវប្បធម៌ និងសង្គម** (NGOs ០៨)៖ ការបណ្តុះបណ្តាលប្រភេទនេះនឹងត្រូវបានផ្តល់ដើម្បីស្វែងយល់ពីរបៀបបញ្ចូលបរិបទវប្បធម៌ និងសង្គមទៅក្នុងកម្មវិធីសិក្សា និងការរៀន និងបង្រៀន។

១០. **ការចូលរួមរបស់អាណាព្យាបាល និងសហគមន៍** (NGOs ២៤)៖ តាមរយៈនេះនឹងបង្រៀនពីយុទ្ធសាស្ត្រជំរុញការចូលរួមរបស់អាណាព្យាបាល និងសហគមន៍នៅក្នុងដំណើរការអប់រំ ការប្រមូលធនធានការពាក់ព័ន្ធ និងចូលរួមរបស់សហគមន៍។

១១. **ការគ្រប់គ្រងតាមសាលារៀន** (NGOs ១១)៖ ផ្នែកនេះគ្របដណ្តប់លើជំនាញ និងចំណេះដឹងដែលត្រូវការជាចាំបាច់ក្នុងការគ្រប់គ្រងរដ្ឋបាលសាលារៀន ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ការចូលរួមរបស់សហគមន៍ ការកៀរគរធនធាន និងផ្សេងៗ។

១២. **ការប្រឹក្សាគរុកោសល្យ** (NGOs ១០)៖ ផ្នែកនេះផ្តល់ការគាំទ្រដល់គ្រូបង្រៀនតាមរយៈកម្មវិធីប្រឹក្សាគរុកោសល្យ។

១៣. **ការបណ្តុះបណ្តាលគ្រូបង្គោល/បណ្តុះបណ្តាលដល់គ្រូបង្គោលស្នូល** (NGOs ២៩)៖ ផ្តោតលើការបណ្តុះបណ្តាលអ្នកអប់រំឱ្យក្លាយជាគ្រូបង្គោលដោយផ្ទាល់។

១៤. **ការអប់រំពិសេស** (NGOs ០៧)៖ ការបណ្តុះបណ្តាលប្រភេទនេះនឹង ផ្តោតលើការដោះស្រាយតម្រូវការជាក់លាក់របស់សិស្ស ដែលមានពិការភាព និងតម្រូវការពិសេស។

១៥. **ផ្សេងៗ** (NGOs ០៦)៖ ប្រធានបទបណ្តុះបណ្តាលផ្សេងៗជាច្រើនដែលមិនមានក្នុងតារាង រួមមានដូចជា៖ សិទ្ធិកុមារ និងការចូលរួមរបស់កុមារ គោលការណ៍ណែនាំស្តីពីកិច្ចការពារកុមារ ការថតរូប ការថតវីដេអូ និងការផលិតវីដេអូ ការសិក្សាអប់រំសម្រាប់មនុស្សពេញវ័យ ការគ្រប់គ្រងការអនុវត្តគម្រោង គាំទ្របុគ្គលិកឱ្យរៀនធ្វើការឆ្លុះបញ្ចាំង និងការអញ្ជើញអង្គការខាងក្រៅ អ្នកឯកទេសអន្តរជាតិផ្នែកអប់រំ ដើម្បីបណ្តុះបណ្តាលគ្រូបង្រៀន។

## ៦) ភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការ

អង្គការចំនួន ៤៤ ក្នុងចំណោម ៥២ បានចាប់ដៃគូសហការជាមួយអង្គការផ្សេងទៀត។ ៤០ ក្នុងចំណោម ៥២ អង្គការ គឺជាសមាជិក PESWG ។ នៅក្នុងតារាងបង្ហាញថា NGOs ដែលឆ្លើយសំណួរនៅក្នុងការធ្វើផែនទីនេះ គឺជាសមាជិកPESWG (នៅក្នុងខេត្តនីមួយៗ ចំនួនPESWG អាចមានច្រើនជាងនេះ ដោយសារចំនួននេះរាប់បញ្ចូលតែអង្គការដែលបំពេញផែនទីអង្គការសង្គមស៊ីវិលតែប៉ុណ្ណោះ)។

ចំពោះNGOs ចំនួន ០៨ ផ្សេងទៀត ដែលមិនអាចចូលរួម ឬអាចភ្ជាប់ទំនាក់ទំនងជាមួយPESWG បានរាយការណ៍ពីបញ្ហាប្រឈមមួយចំនួនក្នុងការចូលរួមក្នុងកិច្ចប្រជុំESWG ដូចជា៖ ១.មានការលំបាកក្នុងការធ្វើដំណើរ ឬផ្លូវឆ្ងាយ ២.មិនមានពេលវេលា ឬធនធានមនុស្សគ្រប់គ្រាន់ដើម្បីចូលរួម ៣.ក្រុមការងារមិនទាន់មានសកម្មភាពនៅឡើយ ៤.មិនជាប់ពាក់ព័ន្ធជាមួយនឹងគម្រោងរបស់ពួកគេ ៥.ការផ្តោតជាក់លាក់លើការអប់រំរបស់កុមារបាត់បង់ឱកាសក្នុងសង្គម ឬឧត្តមសិក្សា អាចបង្ហាញពីភាពមិនស៊ីគ្នាជាមួយនឹងវិសាលភាពរបស់PESWG និង៦.ពួកគេបានរាយការណ៍ថាមិនមានកិច្ចប្រជុំណាមួយនៅក្នុងខេត្តនោះទេ។ តាមរយៈកត្តាផ្សេងៗដូចបានគូសបញ្ជាក់ ចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនង ដោះស្រាយឧបសគ្គផ្នែកដឹកជញ្ជូន និងធានាថាគោលដៅPESWG ស្របតាមផលប្រយោជន៍របស់NGOsទាំងអស់។ អនុសាសន៍មួយចំនួន ដើម្បីពង្រឹងការចូលរួម និងសកម្មភាពរបស់PESWG៖

### ១. ការទំនាក់ទំនង និងផ្សព្វផ្សាយ៖

- កំណត់គោលដៅជាក់លាក់របស់PESWG និងផ្សព្វផ្សាយទៅកាន់NGOsដែលធ្វើការលើវិស័យទាំងនោះពាក់ព័ន្ធជាមួយនឹងគោលដៅយុទ្ធនាការតាមអ៊ីម៉ែល ការហៅទូរសព្ទ ឬបទបង្ហាញនៅក្នុងកម្មវិធី NGOs ដែលពាក់ព័ន្ធ
- **ការប្រាស្រ័យទាក់ទងច្បាស់លាស់៖** ត្រូវប្រាកដថារបៀបវារៈកិច្ចប្រជុំ គោលដៅ និងលទ្ធផលរំពឹងទុកត្រូវបានប្រាស្រ័យទាក់ទងយ៉ាងច្បាស់ទៅកាន់អ្នកចូលរួមដែលមានសក្តានុពល។ តាមរយៈនេះនឹងជួយឱ្យ NGOs វាយតម្លៃថាតើPESWGមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការងាររបស់ពួកគេឬអត់ ដោយប្រើប្រាស់បណ្តាញទំនាក់ទំនងផ្សេងៗ។

### ២. ដោះស្រាយឧបសគ្គផ្នែកធ្វើដំណើរ៖

- ផ្តល់ជម្រើសនៃកិច្ចប្រជុំអនឡាញ រួមជាមួយនឹងកិច្ចប្រជុំដោយផ្ទាល់ ដើម្បីជួយសម្រួលដល់បញ្ហាក្នុងការធ្វើដំណើរ ឬពេលវេលា
- រៀបចំកិច្ចប្រជុំនៅកន្លែងផ្សេងៗ ដើម្បីបង្កភាពងាយស្រួលដល់NGOsមកពីតំបន់ភូមិសាស្ត្រខុសៗគ្នា។

**៣. ការលើកកម្ពស់សកម្មភាពរបស់PESWG៖**

- ចែករំលែកភាពជោគជ័យ និងសមិទ្ធផលរបស់PESWG ដើម្បីបង្ហាញពីគុណតម្លៃ និងលើកទឹកចិត្តឱ្យមានការចូលរួម
- អញ្ជើញវាគ្មិនដែលមានជំនាញពាក់ព័ន្ធនឹងគោលដៅរបស់PESWG ដើម្បីបំផុសការចាប់អារម្មណ៍ និងកិច្ចពិភាក្សា
- បង្កើតមាត្រដ្ឋានច្បាស់លាស់ ដើម្បីតាមដានវឌ្ឍនភាពរបស់PESWG និងបង្ហាញពីគុណតម្លៃទៅដល់ភាគីពាក់ព័ន្ធ។

**៤. ដោះស្រាយបញ្ហាកង្វល់ពាក់ព័ន្ធ៖**

- ពិនិត្យគោលដៅរបស់PESWG ជាទៀងទាត់ ដើម្បីធានាថាវានៅតែផ្សារភ្ជាប់ជាមួយនឹងតម្រូវការជាក់ស្តែងរបស់NGOs
- ធ្វើការវាយតម្លៃតម្រូវការក្នុងចំណោមNGOs ដើម្បីស្វែងយល់ពីអាទិភាព និងកែសម្រួលការងាររបស់PESWGឱ្យបានសមស្រប
- គប្បីរៀបចំយន្តការផ្តល់មតិកែលម្អដើម្បីប្រមូលផ្តុំធាតុចូលពីNGOsលើការបង្កើនប្រសិទ្ធភាពនៃPESWG។

តារាងទី៧៖ ចំនួនNGOsជាសមាជិកPESWG តាមខេត្ត(ពីការធ្វើផែនទី)។ ព័ត៌មានលម្អិតនៅក្នុងឧបសម្ព័ន្ធ៣




## ៧) យេនឌ័រ និងបរិយាបន្ន

ផ្អែកតាមការអង្កេតNGOsដែលចូលរួមលើយេនឌ័រ និងបរិយាបន្នក្នុងវិស័យអប់រំបានផ្តល់រូបភាពវិជ្ជមានជាទូទៅ ដោយអង្គការភាគច្រើនបង្ហាញពីការប្តេជ្ញាចិត្តចំពោះយេនឌ័រនិងបរិយាបន្ន។ លទ្ធផលសំខាន់ៗដែលបានរកឃើញ៖

- **គោលនយោបាយ និងការប្តេជ្ញាចិត្តដ៏រឹងមាំ៖** ជាង ៨០% នៃអង្គការមានគោលនយោបាយ ឬគំនិតផ្តួចផ្តើមសម្រាប់ការអប់រំបរិយាបន្ន (៦៥.៣៨%) និងសមភាពយេនឌ័រ (៨២.៦៩%) ។ លើសពីនេះ អង្គការស្ទើរតែទាំងអស់ (៩២.៣១%) ប្តេជ្ញាលើកកម្ពស់ឱកាសស្មើគ្នា និងមិនរើសអើងក្នុងការជ្រើសរើស និងដំឡើងឋានៈបុគ្គលិក។ ប្រការនេះបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងច្បាស់ចំពោះគោលការណ៍ទាំងនេះនៅកម្រិតអង្គការ។
- **បរិយាកាសគាំទ្រ៖** អង្គការមួយភាគធំ (៦៩.២៣%) មានកម្មវិធីជាក់លាក់លើសមភាពយេនឌ័រ និងបរិយាបន្ន ហើយអង្គការភាគច្រើនអះអាងថា បុគ្គលិករបស់ខ្លួនយល់ដឹងពីបញ្ហាទាំងនេះ (៩២.៣១%)។ នេះបង្ហាញពីបរិយាកាសគាំទ្រ ដែលក្នុងនោះបញ្ហាទាំងនេះត្រូវបានដោះស្រាយ។
- **ការផ្តោតលើសិស្សដែលមានពិការភាព៖** យោងតាមលទ្ធផលដែលបានរកឃើញ បានបង្ហាញជាវិជ្ជមានថាជាងបីភាគបួននៃអង្គការ (៧៦.៩២%) បានផ្តល់កន្លែងស្នាក់នៅ ឬជំនួយសម្រាប់សិស្សដែលមានពិការភាព។ នេះជាការធានាថាសិស្សទាំងនេះមានឱកាសស្មើគ្នាក្នុងការទទួលបានជោគជ័យក្នុងការអប់រំ។
- **កិច្ចសហការដើម្បីសមភាពយេនឌ័រ៖** កិច្ចសហការគឺជាគន្លឹះមួយដើម្បីសម្រេចបានសមភាពយេនឌ័រ។ ត្រង់ចំណុចនេះ សញ្ញាជាវិជ្ជមាន គឺថាមានអត្រាខ្ពស់នៃការសហការជាមួយអង្គការផ្សេងទៀត (៦៩.២៣%) ដើម្បីលើកកម្ពស់គោលដៅទាំងនេះ។

## ចំណុចដែលត្រូវធ្វើឱ្យកាន់តែប្រសើរឡើង

ទោះបីជាមានលទ្ធផលប្រកបដោយផ្លែផ្កាយ៉ាងក៏ដោយ ចាំបាច់ត្រូវមានការកែលម្អលើចំណុចខ្លះៗ ដើម្បីធានាបរិយាកាសអប់រំប្រកបដោយបរិយាបន្ន និងសមធម៌ពិតប្រាកដ។

- **ការអនុវត្តកម្មវិធី៖** ទោះបីជាអង្គការមួយចំនួនមានគោលនយោបាយ និងគំនិតផ្តួចផ្តើមនៅនឹងកន្លែងក៏ដោយ ការដាក់ឱ្យអនុវត្តជាក់ស្តែងដែលមានភាពស៊ីសង្វាក់គ្នា ទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀត។ ជាឧទាហរណ៍ មានតែពីរភាគបី (៦៩.២៣%) ប៉ុណ្ណោះ ដែលមានកម្មវិធីជាក់លាក់លើសមភាពយេនឌ័រ និងបរិយាបន្ន ហើយខ្លះទៀត (៤៤.២៣%) មិនទាន់បានផ្តល់ការបណ្តុះបណ្តាលលើប្រធានបទទាំងនេះនៅឡើយទេ។
- **ការប្រើប្រាស់ទិន្នន័យ៖** ទិន្នន័យគឺមានសារៈសំខាន់ណាស់ សម្រាប់ធ្វើការសម្រេចបានត្រឹមត្រូវ។ នៅទីនេះមានអង្គការតែពាក់កណ្តាលប៉ុណ្ណោះ ដែលប្រមូលទិន្នន័យតាមយេនឌ័រ (៥៥.៧៧%) និងប្រើទិន្នន័យសម្រាប់ជាព័ត៌មាន ក្នុងការធ្វើសេចក្តីសម្រេចលើសមភាពយេនឌ័រ នៅក្នុងកម្មវិធីអប់រំ (៤៨.០៨%)។ ការពង្រឹងសមត្ថភាពក្នុងការប្រមូល និងប្រើប្រាស់ទិន្នន័យ គឺជាការចាំបាច់ណាស់។
- **ការធ្វើជាក់បញ្ចូលយេនឌ័រ និងបរិយាបន្ន៖** ត្រូវមានកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើពិចារណាអំពីការដាក់បញ្ចូលយេនឌ័រ និងបរិយាបន្ននៅទូទាំងវដ្តកម្មវិធីទាំងមូល។ មានតែ ៤០.៣៨% ប៉ុណ្ណោះដែលមានយុទ្ធសាស្ត្រជាក់លាក់ដើម្បីដាក់បញ្ចូលនៅក្នុងការអភិវឌ្ឍន៍កម្មវិធី ការអនុវត្ត និងត្រួតពិនិត្យការអនុវត្តកម្មវិធី។
- **ការបន្សីគ្នាជាមួយដៃគូ៖** កិច្ចសហការគឺមានសារៈសំខាន់ណាស់ ប៉ុន្តែការធានាឱ្យដៃគូមានការប្តេជ្ញាចិត្តរួមគឺកាន់តែមានសារៈសំខាន់។ នៅទីនេះ ទោះបីជាមានអង្គការជាច្រើនបានសហការជាមួយអង្គការផ្សេង

ទៀតក៏ដោយ ប៉ុន្តែមិនដល់ពាក់កណ្តាលនៃពួកគេ (៤៦.១៥%) ធានាថាដៃគូរបស់ខ្លួនមានការប្តេជ្ញាចិត្តរួមចំពោះសមភាពយេនឌ័រ និងការអប់រំបរិយាបន្ន។

**អនុសាសន៍លើចំណុចដែលត្រូវធ្វើឱ្យកាន់តែប្រសើរឡើង**

ផ្អែកតាមចំណុចដែលបានរកឃើញដើម្បីធ្វើការកែលម្អ នេះជាអនុសាសន៍មួយចំនួន ដើម្បីពង្រឹងការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះសមភាពយេនឌ័រ និងការអប់រំបរិយាបន្ន។

**i. ប្រែក្លាយគោលនយោបាយទៅជាការអនុវត្តជាក់ស្តែង៖**

ក. កសាងផែនការសកម្មភាព៖ ប្រែក្លាយគោលនយោបាយទូលំទូលាយទៅជាផែនការសកម្មភាពជាក់លាក់ដែលមានគោលដៅច្បាស់លាស់ មានពេលវេលាកំណត់ និងភាគីទទួលខុសត្រូវ។

ខ. ការកសាងសមត្ថភាព៖ ផ្តល់ការបណ្តុះបណ្តាលជាទៀងទាត់សម្រាប់បុគ្គលិក លើសមភាពយេនឌ័រ និងការអនុវត្តល្អៗទាក់ទងនឹងការអប់រំបរិយាបន្ន។ ការធ្វើបែបនេះជួយឱ្យពួកគេអនុវត្តគោលការណ៍ទាំងនេះប្រកបដោយប្រសិទ្ធភាព។

គ. ការបែងចែកធនធាន៖ បែងចែកធនធានឱ្យបានគ្រប់គ្រាន់ ទាំងធនធានមនុស្ស និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការអនុវត្តផ្នែកសមភាពយេនឌ័រ និងគំនិតផ្តួចផ្តើមបរិយាបន្ន។

I **ii. ការធ្វើសេចក្តីសម្រេចផ្អែកតាមទិន្នន័យ៖**

ក. ពង្រឹងការប្រមូលទិន្នន័យ៖ ពង្រីកការប្រមូលទិន្នន័យ ដោយដាក់បញ្ចូលសូចនាករព័ត៌មានផ្សេងៗ ដូចជា យេនឌ័រ ពិការភាព និងសាវតាសេដ្ឋកិច្ចសង្គម។

ខ. ការវិភាគ និងប្រើប្រាស់ទិន្នន័យ៖ វិនិយោគលើការពង្រឹងសមត្ថភាពក្នុងការវិភាគទិន្នន័យ ដើម្បីកំណត់និន្នាការ និងធ្វើការសម្រេចផ្អែកតាមទិន្នន័យលើការកែលម្អកម្មវិធី។

គ. ការរាយការណ៍ និងតម្លាភាព៖ បង្កើតយន្តការរាយការណ៍ជាប្រចាំ អំពីវឌ្ឍនភាពឆ្ពោះទៅសម្រេចសមភាពយេនឌ័រ និងគោលដៅអប់រំបរិយាបន្ន។

**iii. ការធ្វើសមាហរណកម្មជាប្រព័ន្ធ៖**

ក. ធ្វើសមាហរណកម្មការពិចារណាអំពីបញ្ហាយេនឌ័រ និងបរិយាបន្ន៖ បង្កើតគោលការណ៍ណែនាំ និងក្របខណ្ឌច្បាស់លាស់ ដើម្បីធ្វើសមាហរណកម្មគោលការណ៍ទាំងនេះនៅក្នុងវដ្តកម្មវិធីទាំងមូល ចាប់ពីការរៀបចំគម្រោង និងធ្វើផែនការរហូតដល់ការអនុវត្ត និងការពិនិត្យតាមដានការអនុវត្តកម្មវិធី។

ខ. សវនកម្មលើភាពចម្រុះ និងបរិយាបន្ន៖ ធ្វើសវនកម្មកម្មវិធីជាទៀងទាត់ ដើម្បីវាយតម្លៃលើប្រសិទ្ធភាពកម្មវិធីក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្ន។

គ. ការចែករំលែកនវានុវត្តភាព និងការអនុវត្តល្អៗ៖ លើកទឹកចិត្តឱ្យមាននវានុវត្តភាពនៅក្នុងការអភិវឌ្ឍន៍ និងអនុវត្តយុទ្ធសាស្ត្រអប់រំបរិយាបន្ន។ ចែករំលែកការអនុវត្តល្អៗក្នុងចំណោមស្ថាប័នតាមរយៈសិក្ខាសាលា ឬវេទិកាអនឡាញ។

**iv. ការបន្ស៊ីគ្នាជាមួយដៃគូ៖**

ក. ការជ្រើសរើសដៃគូ៖ បង្កើតលក្ខណៈវិនិច្ឆ័យដែលផ្តល់អាទិភាពលើកិច្ចសហប្រតិបត្តិការជាមួយដៃគូដែលមានការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះសមភាពយេនឌ័រ និងការអប់រំបរិយាបន្ន។

ខ. ការកសាងសមត្ថភាពដៃគូ៖ សហការជាមួយដៃគូ ដើម្បីកសាងសមត្ថភាពរបស់ពួកគេលើបញ្ហាទាំងនេះ ជំរុញការយល់ដឹង និងវិធីសាស្ត្ររួមគ្នា។

គ. បង្កើតអនុស្សរណៈនៃការយោគយល់គ្នា (MOUs)៖ បង្កើតភាពជាដៃគូជាផ្លូវការតាម MOUs ដែលក្នុងនោះបង្ហាញយ៉ាងច្បាស់នូវគោលដៅ និងការរំពឹងទុករួមគ្នាទាក់ទងនឹងបញ្ហាសមភាពយេនឌ័រ និងការអប់រំបរិយាបន្ន។

ឃ. ការចូលរួមរបស់សហគមន៍៖ ធ្វើសកម្មភាពជំរុញការចូលរួមរបស់សហគមន៍ រួមទាំងក្រុមដែលងាយរងគ្រោះដើម្បីស្វែងយល់ពីតម្រូវការ និងទស្សនៈពួកគេលើសមភាពយេនឌ័រ និងការអប់រំបរិយាបន្ន។

## ៨) យុទ្ធសាស្ត្រតស៊ូមតិរបស់NGOsដែលចូលរួមក្នុងការធ្វើផែនទី

តារាងខាងក្រោមបង្ហាញពីរបាយរបស់NGOs និងយុទ្ធសាស្ត្រតស៊ូមតិផ្នែកអប់រំដែលមានលក្ខណៈផ្សេងៗ រួមមាន៖




ក) **យុទ្ធនាការលើកកម្ពស់ការយល់ដឹង (NGOs ៣២)៖** ជាយុទ្ធសាស្ត្រដ៏ពេញនិយមបំផុត ដែលបង្ហាញពីការ ផ្តោតយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីបញ្ហាអប់រំ។

ខ) **ការកៀរគរសហគមន៍ (NGOs ៣១)៖** តួលេខនេះបង្ហាញពីអាទិភាពនៃកិច្ចខិតខំប្រឹងប្រែងក្នុងការកៀរគរធនធាននៅថ្នាក់មូលដ្ឋាន ដើម្បីប្រមូលផ្តុំការគាំទ្រសហគមន៍សម្រាប់ធ្វើការតស៊ូមតិផ្នែកអប់រំ។

គ) **យុទ្ធសាស្ត្រភាពជាដៃគូ (NGOs ៣១)៖** កិច្ចសហការជាប្រធានបទសំខាន់ ដោយNGOs ជាច្រើនបានទទួលស្គាល់តម្លៃនៃភាពជាដៃគូជាមួយអង្គការផ្សេងទៀត ដើម្បីពង្រីកកិច្ចខិតខំប្រឹងប្រែងតស៊ូមតិ។

ឃ) **ការបណ្តុះបណ្តាល និងកសាងសមត្ថភាព (NGOs ២៣)៖** ការវិនិយោគលើការបំពាក់បំប៉នជំនាញ និងចំណេះ ដឹងរបស់អ្នកអប់រំ និងអ្នកតស៊ូមតិតាមតម្រូវការពួកគេ គឺជាជំហានដ៏សំខាន់ក្នុងការនាំមកនូវផលប៉ះពាល់រយៈពេលវែង។

ង) **ការវិភាគគោលនយោបាយ និងធ្វើផែនការយុទ្ធសាស្រ្ត (NGOs ១២)៖** នេះបង្ហាញពីសារៈសំខាន់នៃការស្រាវជ្រាវ និងផែនការយុទ្ធសាស្រ្តក្នុងកិច្ចខិតខំប្រឹងប្រែងតស៊ូមតិនៅកម្រិតមូលដ្ឋានដោយផ្អែកលើភស្តុតាង និងផែនទីបង្ហាញផ្លូវច្បាស់លាស់។

ច) **ការកសាងសម្ព័ន្ធ ឬសមាជិកភាព(NGOs ១៨)៖** ស្រដៀងនឹងភាពជាដៃគូយុទ្ធសាស្រ្ត ផ្នែកនេះសង្កត់ធ្ងន់លើកិច្ចសហការការក្នុងការកសាងសម្ព័ន្ធ/សមាជិក ដើម្បីឱ្យមានសំឡេងសមូហភាពកាន់តែខ្លាំង។

ឆ) **ការតស៊ូមតិផ្នែកច្បាប់កម្រិតមូលដ្ឋាន (៧ NGOs)៖** នេះបង្ហាញពីចន្លោះប្រហោងនៃកិច្ចខិតខំប្រឹងប្រែងក្នុងការតស៊ូមតិផ្នែកច្បាប់ ដែលមានសារៈសំខាន់ក្នុងការដោះស្រាយបញ្ហាជាប្រព័ន្ធក្នុងវិស័យអប់រំ។

ជ) **ការបញ្ចុះបញ្ចូល (NGOs ២៣)៖** យុទ្ធសាស្រ្តតស៊ូមតិនេះត្រូវបានប្រើដោយNGOs មួយចំនួនតូច ដែលអាចបង្ហាញពីអាទិភាពសម្រាប់ថ្នាក់មូលដ្ឋាន ឬវិធីសាស្រ្តសហការ។

ឈ) **ការស្រាវជ្រាវ និងបោះពុម្ពផ្សាយ (NGOs ២២)៖** ការស្រាវជ្រាវមានតួនាទីមួយ ប៉ុន្តែមានការផ្តោត យកចិត្តទុកដាក់យ៉ាងខ្លាំងលើការលើកកម្ពស់ការយល់ដឹង និងការកៀរគរសហគមន៍។

ញ) **ការចូលរួមពីសារព័ត៌មានចម្រុះ (NGOs ១៦)៖** នេះបង្ហាញថា ទោះបីជាអង្គការមួយចំនួនកំពុងប្រើប្រាស់ឧបករណ៍បណ្តុំសារព័ត៌មាន ក៏មិនទាន់មានយុទ្ធសាស្រ្តទូលំទូលាយនៅឡើយ។

## III. សេចក្តីសន្និដ្ឋាន

របាយការណ៍ផែនទីអង្គការសង្គមស៊ីវិលដែលធ្វើការលើវិស័យអប់រំនេះ មិនគ្របដណ្តប់គ្រប់រូបភាពនៃវិស័យអប់រំនៅកម្ពុជាទេ។ ទោះបីជាយ៉ាងណា វាផ្តល់ទិន្នន័យ និងព័ត៌មានអំពីវិស័យអប់រំកម្ពុជាដែលបានមកពីអង្គការសង្គមស៊ីវិលខាងវិស័យអប់រំដោយសង្កត់ធ្ងន់លើតួនាទីដ៏សំខាន់ ក្នុងការដោះស្រាយបញ្ហាប្រឈមដែលមានស្រាប់ និងជំរុញប្រទេសឆ្ពោះទៅសម្រេចបានសមធម៌នៃការអប់រំ។ ផ្អែកតាមទិន្នន័យ និងព័ត៌មានដែលយើងប្រមូលបាន យើងអាចឃើញចំណុចសំខាន់ៗដូចជា៖

- **ឱកាសមិនស្មើភាពគ្នា៖** មានភាពខុសគ្នាយ៉ាងខ្លាំងគួរឱ្យកត់សម្គាល់លើគុណភាពអប់រំរវាងតំបន់ទីក្រុង និងតំបន់ជនបទ ដោយសារតែភាពមិនស្មើភាពនៃការរកបានគ្រូបង្រៀនដែលមានសមត្ថភាព បច្ចេកវិទ្យា និងធនធានសិក្សា។ បញ្ហានេះនាំឱ្យកើតមានជាបន្តនូវវដ្តនៃការបាត់បង់ប្រយោជន៍សម្រាប់សិស្សនៅក្នុងសហគមន៍ដែលជួបការលំបាក។
- **កិច្ចសហការ គឺជាផ្នែកដ៏សំខាន់បំផុត៖** ដំណោះស្រាយដែលមានប្រសិទ្ធភាពទាមទារឱ្យមានកិច្ចសហការក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ ពោលគឺ NGOs ទីភ្នាក់ងាររដ្ឋាភិបាល សាលារៀន សហគមន៍ និងអាណាព្យាបាល។ ការចូលរួមយ៉ាងច្រើនពីសំណាក់ NGOs នៅក្នុង PESWGs គឺជាជំហានវិជ្ជមានឆ្ពោះទៅរកកិច្ចខិតខំប្រឹងប្រែងក្នុងការសម្របសម្រួល។
- **ការវិនិយោគលើធនធានមនុស្ស៖** ទោះបីជាការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាកត្តាដ៏មានសារៈសំខាន់យ៉ាងណា ការវិនិយោគលើធនធានមនុស្សតាមរយៈកម្មវិធីបណ្តុះបណ្តាលសម្រាប់គ្រូបង្រៀននៅក្នុងតំបន់ដែលខ្វះខាត គឺមានសារៈសំខាន់ណាស់។ កម្មវិធីទាំងនេះគួរផ្តោតលើគរុកោសល្យ ចំណេះដឹងលើមុខជំនាញជាក់លាក់ និងការធ្វើសមាហរណកម្មបច្ចេកវិទ្យាដើម្បីបង្កើនប្រសិទ្ធភាពនៃការបង្រៀន។

- **ការជំរុញការអប់រំបរិយាបន្ន៖** ការអនុវត្តផ្នែកអប់រំបរិយាបន្នដែលបំពេញតម្រូវការសិក្សាចម្រុះ គឺជាការចាំបាច់ណាស់។ កម្មវិធីបណ្តុះបណ្តាលបំពាក់បំប៉នជំនាញ និងចំណេះដឹងរបស់គ្រូបង្រៀន ដើម្បីបង្កើតបរិយាកាសសិក្សាដែលគាំទ្រសិស្សដែលមានពិការភាព ឬតម្រូវការពិសេស។
- **ការកសាងមូលដ្ឋានគ្រឹះរឹងមាំ៖** ការចូលរួមរបស់អាណាព្យាបាល និងសហគមន៍ គឺមានសារៈសំខាន់ណាស់។ NGOs ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រដែលមានការចូលរួមពីភាគីពាក់ព័ន្ធទាំងនេះ និងធានាថាសំឡេងរបស់ពួកគេត្រូវបានគេស្តាប់។
- **លទ្ធភាពសម្របនឹងពេលវេលាមិនប្រាកដប្រជា៖** អស្ថិរភាពខាងនយោបាយបង្ហាញពីបញ្ហាប្រឈមចំពោះ NGOs ដែលធ្វើប្រតិបត្តិការនៅក្នុងវិស័យមួយចំនួន។ ការបង្កើតកម្មវិធីដែលមានភាពបត់បែនអាចសម្របសម្រួល និងបន្តធ្វើប្រតិបត្តិបានទោះបីជាមានការប្រែប្រួលកាលៈទេសៈក៏ដោយ គឺជារឿងដ៏សំខាន់។ កិច្ចសហការជាមួយអង្គការក្នុងស្រុក អាចផ្តល់នូវការឆ្លុះបញ្ចាំងដ៏មានតម្លៃសម្រាប់ការតម្រង់ទិសស្ថានភាពបែបនេះប្រកបដោយប្រសិទ្ធភាព។

ការបង្កើតផែនទីអង្គការសង្គមស៊ីវិលនេះ អាចជួយកំណត់គម្លាត និងវិស័យដែលអង្គការសង្គមស៊ីវិលអាចចូលរួមចំណែកប្រកបដោយប្រសិទ្ធភាពបំផុត ដើម្បីធានាថាកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេបន្សីគ្នាជាមួយនឹងអាទិភាពនៃការអប់រំថ្នាក់ជាតិ។ វាក៏ជួយសម្រួលដល់ការសហការគ្នាក្នុងចំណោមអង្គការសង្គមស៊ីវិល ដែលបញ្ចៀសនូវកិច្ចប្រឹងប្រែងត្រួតគ្នា និងបង្កើនផលប៉ះពាល់នៃធនធានរបស់ពួកគេ ហើយតាមរយៈការផ្តល់ទិន្នន័យស្តីពីសកម្មភាពរបស់អង្គការសង្គមស៊ីវិល កិច្ចអន្តរាគមន៍ និងការចុះទៅដល់ភូមិសាស្ត្រ របាយការណ៍នេះជាព័ត៌មានមួយក្នុងការធ្វើសេចក្តីសម្រេចរបស់រដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិលដោយផ្ទាល់។

**ការអំពាវនាវឱ្យចូលរួមសកម្មភាព៖**

ស្មារតីលះបង់ និងសហការរបស់អង្គការសង្គមស៊ីវិលខាងវិស័យអប់រំដែលមានស្រាប់ ផ្តល់នូវទស្សនវិស័យដ៏ត្រចះត្រចង់សម្រាប់ការអប់រំនៅកម្ពុជា។ ទោះជាយ៉ាងណា ការសម្រេចបានសមធម៌អប់រំទាមទារឱ្យមានការខិតខំប្រឹងប្រែងរួមគ្នា។ របាយការណ៍នេះមានតួនាទីអំពាវនាវឱ្យអង្គការសង្គមស៊ីវិលដទៃទៀតចូលរួមក្នុងចលនានេះ៖

- **ចូលរួមចំណែកក្នុងការប្រមូលទិន្នន័យ៖** ការចូលរួមក្នុងគំនិតផ្តួចផ្តើមធ្វើផែនទីអប់រំនាពេលអនាគតនឹងផ្តល់នូវរូបភាពកាន់តែទូលំទូលាយនៃវិស័យនេះ និងផ្តល់ជាព័ត៌មានសម្រាប់កិច្ចអន្តរាគមន៍។
- **កំណត់ឱកាសសហការ៖** ប្រើប្រាស់ទិន្នន័យ ដើម្បីកំណត់ពីវិស័យដែលត្រូវសហការជាមួយ NGOs ដែលមានស្រាប់ ដើម្បីបង្កើនផលប៉ះពាល់ជារួម។
- **ការតស៊ូមតិដើម្បីឱ្យមានការផ្លាស់ប្តូរ៖** ចាប់ដៃគូជាមួយអង្គការសង្គមស៊ីវិលដទៃទៀត ដើម្បីតស៊ូមតិឱ្យអនុវត្តគោលនយោបាយលើកកម្ពស់ការចែកចាយធនធានប្រកបដោយសមធម៌ និងលើកកម្ពស់លទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាពសម្រាប់កុមារកម្ពុជា។

តាមរយៈការធ្វើការរួមគ្នា ចែករំលែកចំណេះដឹង និងការតស៊ូមតិដើម្បីឱ្យមានការផ្លាស់ប្តូរ អង្គការសង្គមស៊ីវិលខាងវិស័យអប់រំអាចដើរតួនាទីដើម្បីនាំមកនូវការផ្លាស់ប្តូរដែលធានានូវអនាគតដ៏ត្រចះត្រចង់សម្រាប់ការអប់រំនៅកម្ពុជា។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១៖ ចំនួនNGOsដែលចូលរួមការអង្កេតសម្រាប់កិច្ចអន្តរាគមន៍តាមខេត្ត

| ល.រ | ខេត្ត | NGOs ដែលបានចូលរួមក្នុងការអង្កេត |
|---|---|---|
| ១ | បន្ទាយមានជ័យ | PE&D, KK, KrY, WVI, RtR, SIPAR, GNC |
| ២ | បាត់ដំបង | OCCO, KYA, KT, VSO, WVI, CTOD, SIPAR, GNC, OEC, KNGR, CORDE |
| ៣ | កំពង់ចាម | SCI, CRF, PE&D, DVVI, KT, KrY, HI, SIPAR, AusCam |
| ៤ | កំពង់ឆ្នាំង | SCI, CRC-Cambodia, DVVI, WE, CCAFO, VSO, WVI, RTI-IPEA, SIPAR, KCD |
| ៥ | កំពង់ស្ពឺ | CRF, PE&D, CRC-Cambodia, KT, CCAFO, BK, WVI, RSO, SIPAR |
| ៦ | កំពង់ធំ | NTFP, RTI, DVVI, WE, VVOB, VSO, WVI, SIPAR, CORDE |
| ៧ | កំពត | CRF, PE&D, CRC-Cambodia, DVVI, KT, COCD, CCAFO, VVOB, SIPAR, EA, BLCP |
| ៨ | កណ្ដាល | CRF, CRC-Cambodia, DVVI, KT, WVI, AARJ, RSO, Mith Samlanh, SIPAR, KCD |
| ៩ | កែប | VVOB, SIPAR |
| ១០ | ក្រចេះ | CARE, KYA, WVI, SIPAR, MCC, UWS, GNC |
| ១១ | មណ្ឌលគិរី | CARE, SIPAR, UWS, GNC |
| ១២ | ឧត្តរមានជ័យ | FH-Cambodia, SIPAE, UWS |
| ១៣ | ប៉ៃលិន | SIPAR, KT |
| ១៤ | រាជធានីភ្នំពេញ | CCF, PE&D, KYA, KT, SCO, VSO, BK, RSO, EYC, CRF, MS, ISF, SIPAR, LOC, PLAN, AusCam, GNC |
| ១៥ | ព្រះវិហារ | NTFP, RTI, DVVI, KT, CARE, KrY, WVI, SIPAR, UWS |
| ១៦ | ពោធិ៍សាត់ | CRC-Cambodia, DVVI, COCD, VSO, BK, SIPAR, LOC |
| ១៧ | ព្រៃវែង | CRC-Cambodia, KT, WE, SCO, RTI-IPEA, SIPAR, MCC |
| ១៨ | រតនៈគិរី | CRF, NTFP, CRC-Cambodia, KYA, DVVI, SVC, CARE, KrY, BK, SIPAR, PLAN, UWS, ICC |
| ១៩ | សៀមរាប | TDSO, CRF, CRC-Cambodia, RTI, KYA, KT, WE, FH-Cambodia, KrY, BK, WVI, RSO, TLC, SIPAR, LOC, PLAN |
| ២០ | ព្រះសីហនុ | BK, SIPAR, OEC |
| ២១ | ស្ទឹងត្រែង | CRF, NTFP, KYA, DVVI, SP, KrY, SIPAR, PLAN, UWS |
| ២២ | ស្វាយរៀង | KT, WE, RTI-IPEA, SIPAR, RAO |
| ២៣ | តាកែវ | AREDOC, DVVI, KT, CCAFO, WVI, SIPAR |
| ២៤ | ត្បូងឃ្មុំ | KT, KrY, HI, SIPAR |
| ២៥ | កោះកុង | SCI, SIPAR, UWS |

## ឧបសម្ព័ន្ធទី ២៖ ការអនុវត្តថវិកាជាក់លាក់សម្រាប់ការស្រាវជ្រាវ/សិក្សា និងបណ្តុះបណ្តាល

| ឈ្មោះអង្គការ/ស្ថាប័ន | តើស្ថាប័នរបស់អ្នកមានថវិកាប៉ុន្មានសម្រាប់អនុវត្តកម្មវិធីខាងក្រោមនេះ? (ជាដុល្លា) | | | | | | |
|---|---|---|---|---|---|---|---|
| | ថវិកាសម្រាប់ការសិក្សា/ស្រាវជ្រាវ | ថវិកាសម្រាប់ការបណ្តុះបណ្តាលការតស៊ូមតិ | ថវិកាសម្រាប់ការបណ្តុះបណ្តាលគ្រូ | ថវិកាសម្រាប់ការបណ្តុះបណ្តាលយេនឌ័រ | ថវិកាសម្រាប់ការបណ្តុះបណ្តាលការអប់រំបរិយាបន្ន/ការអប់រំពិសេស | ផ្សេងៗ | ប្រសិនជាមានថវិកាសម្រាប់ការសិក្សា/ស្រាវជ្រាវ តើអ្នកនឹងសិក្សា/ស្រាវជ្រាវលើប្រធានបទ/ផ្នែកអ្វី? |
| អង្គការសេកម្មភាពដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជនបទកម្ពុជា (អារីដុក) | 2500 | | 4000 | | | | ថ្នាក់មត្តេយ្យ និងការអប់រំយេនឌ័រ នៅសាលាបឋមសិក្សាគោលដៅ |
| សមាគមសម្រាប់ជំនួយ និងសង្គ្រោះនៃប្រទេសជប៉ុន | | | | | | | |
| អង្គការសេរីភាពកម្ពុជាអូស្ត្រាលី | 20,000 | 100000 | | | | | ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ |
| សមាគមន៍បណ្តុះកុមារ | 2000 | 20000 | 100000 | 20000 | 10000 | កសាងសង់ និងកែលំអរហេដ្ឋារចនាសម្ព័ន្ធដោយបំពាក់ប្រព័ន្ធទឹកស្អាត និងសម្ភារអនាម័យ (៣៣០០០$) | គុណភាពសិក្សារបស់សិស្ស |
| អង្គការគម្រោងពុទ្ធិកបណ្ណាល័យកម្ពុជា | | | | | | | |
| អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា | | | 5000 | | | | អាហារតាមសាលរៀន |
| អង្គការ មូលនិធិសិទ្ធិកុមារ (ម.ស.ក.) | | | 42400 | | | | |
| អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ | | 20000 | 10000 | | | 50000$ ដើម្បីរៀបចំការផ្សព្វផ្សាយការដាក់ពិន័យបែបវិជ្ជមាន | |
| អង្គការកម្ពុជា ដើម្បីស្រាវជ្រាវ អភិវឌ្ឍន៍ និងអប់រំ | | | 17000 | | | | |
| អង្គការយេរ | 5000 | | 30000 | | | | កម្មវិធីអប់រំពហុភាសា |
| អង្គការមូលនិធិសិទ្ធិកុមារ (ម.ស.ក.) | | | | | | | ការស្រាវជ្រាវបែបអនុវត្តសកម្មភាព |
| អង្គការបណ្តុះបណ្តាលសហគមន៍ដើម្បីអភិវឌ្ឍន៍ | | | | | | | |
| អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា | 1000 | 2000 | | 1000 | | | ការអប់រំកុមារី និងការប្រែប្រួលអាកាសធាតុ |
| អង្គការឌីវីរីអន្តរជាតិ | | | | | | | |
| អង្គការពង្រឹងយុវជនកម្ពុជា | | | 200 | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| អង្គការអេពិកអាត | | 5000 | | | 30000 | | ការសិក្សាស៊ីជម្រៅអំពីកុមារ និងយុវជនមានពិការភាពទទួលបានការអប់រំ |
| អង្គការអាហារសម្រាប់ជនស្រេកឃ្លានកម្ពុជា | | | 40000 | | | | - ការកសាងសមត្ថភាពគ្រូបង្រៀននិងលទ្ធផលសិក្សារបស់សិស្ស<br>- បច្ចេកវិទ្យា ICT សម្រាប់ការអប់រំ<br>- ការចូលរួមរបស់សហគមន៍ឆ្ពោះទៅការរៀនសូត្ររបស់កុមារ |
| អង្គការហ្វូដណេបឺសកម្ពុជា | 90000 | | | | 20000 | | សម្រាប់ការស្រាវជ្រាវ យើងមានថវិកាសម្រាប់តែការប៉ាន់ប្រមាណ និងវាយតម្លៃប៉ុណ្ណោះ |
| អង្គការជនពិការអន្តរជាតិ | 28000 | | | 3,000 | 21,400 | | ស្រាវជ្រាវលើការវាយតម្លៃពីផលប៉ះពាល់នៃការអនុវត្តគម្រោង |
| អង្គការសហការគ្រប់ជ្រុងជ្រោយដើម្បីកម្ពុជា | 10000 | 2500 | 15000 | 5000 | 3000 | ថវិកាមានភាពបត់បែនតាមសកម្មភាពជាក់ស្តែងសម្រាប់ការបំប៉នសមត្ថភាពគ្រូ និងសកម្មភាពតស៊ូមតិ | សិក្សាពីភាសាជនជាតិដើមភាគតិច និងវប្បធម៌របស់ពួកគេ |
| អង្គការផ្កាយសមុទ្រកម្ពុជា | | | 12000 | | | | មិនមាន |
| អង្គការខេមរអភិវឌ្ឍន៍សហគមន៍ | សូមមិនឆ្លើយតប | សូមមិនឆ្លើយតប | សូមមិនឆ្លើយតប | សូមមិនឆ្លើយតប | សូមមិនឆ្លើយតប | សូមមិនឆ្លើយតប | បញ្ហាប្រឈមក្រុមជនជាតិភាគតិចវៀតណាមក្នុងការអប់រំ និងកែលំអរការអប់រំ |
| អង្គការខ្មែរជំនាន់ថ្មី | | | 500 | | | | អត្រាបោះបង់ការសិក្សា |
| សមាគមយុវជនខ្មែរ | 15000 | 20000 | | 24000 | | | LGBTQI ក្នុងការសិក្សា និងក្រោយការបណ្តុះបណ្តាល |
| អង្គការគ្រួសារថ្មី | | | | | 30000 | | គុណភាពនៃការអប់រំរបស់កុមារមានពិការពនៅក្នុងប្រទេសកម្ពុជា |
| សមាគមគ្រួសារយើង | 10000 | | 30000 | | | | កាវាយតម្លៃគម្រោង |

| | | | | | | | |
|---|---|---|---|---|---|---|---|
| អង្គការឡូធឺសអៅរីចខេមបូឌា | | | | | | | *ការវាយតម្លៃលទ្ធផលសិក្សាសិស្សការអភិវឌ្ឍន៍ជំនាញ និងលទ្ធភាពបញ្ចប់ការសិក្សានៅឧត្តមសិក្សា<br>*សិក្សាពីការបន្សីគ្នា/ផ្សាភ្ជាប់គ្នារវាងកម្មវិធីសិក្សា និងតម្រូវការទីផ្សា ក៏ដូចជាប្រសិទ្ធភាពនៃការតម្រង់ទិសការងារ កម្មសិក្សា និងការសម្របសម្រួលការបញ្ចប់ការសិក្សាជាមួយនឹងកន្លែងការងារ |
| Mennonite Central Committee | | | | | | | មិនមាន |
| អង្គការមិត្តសំឡាញ់ | | | | | | | បច្ចេកវិទ្យាសម្រាប់ការរៀន តើសាលា ដែលអាចអនុវត្តសាលាជំនាន់ថ្មីមានប៉ុន្មាន? |
| អង្គការអនុផលព្រៃឈើ | | | 60000 | | | | 1. អត្រាបោះបង់ និងបញ្ហាប្រឈម<br>2. សិក្សាពីគុណភាពនៃការអប់រំ ស្តង់ដារជាតិ និងការអប់រំក្រៅប្រព័ន្ធ<br>3. ស្រាវជ្រាវពីអនក្ខរម្ម និងបញ្ហាប្រឈមកុមារជនជាតិដើមភាពតិចនៅរតនគិរី |
| អង្គការប្រតិបត្តការកុមារកម្ពុជា | | | 2500 | | | | |
| អង្គការភ្លែនអន្តរជាតិអន្តរជាតិកម្ពុជា | 50000 | 20000 | 20000-30000 | 50000-100000 | Not specific. | | 1. ការបម្រែបម្រួលលេយន័រនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា<br>2. ការផ្តល់ធនធានសម្រាប់ការអនុវត្តសាលាគំរូ និងគុណភាពនៃសាលាគំរូ |
| អង្គការPE&D | | | | | | | |
| អង្គការសាលារៀនទន្សាយ | | 10000 | 10000 | | 5000 | | |
| វិទ្យាស្ថានស្រាវជ្រាវត្រីកោណ | | | | | | | |
| វិទ្យាស្ថានស្រាវជ្រាវត្រីកោណ (IPEA Project) | 100000 | | | | | | -អំណានកម្រិតថ្នាក់ដំបូង, ការវាយតម្លៃ<br>-ដាក់បញ្ចូលការបង្រៀនកម្រិតថ្នាក់ដំបូង |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | | -វិធីសាស្ត្រសម្រាប់គរុសិស្ស<br>-សាលាគំរូ -ការប្រឹក្សាគរុកោសល្យ |
| អង្គការរូមធូរីដកម្ពុជា | | | 56231 | 56703 | | | |
| អង្គការជំនួយជនបទ | | 2000 | | 1500 | 1000 | | |
| អង្គការសង្គ្រោះកុមារកម្ពុជា | | | | | | | |
| អង្គការសង្គ្រោះជនងាយរងគ្រោះកម្ពុជា | | | | | | | គុណភាពនៃការអប់រំ |
| អង្គការស៊ីប៉ា | 10000 | | | | | | ប៉ាន់ប្រមាណតម្រូវការ និងការអភិវឌ្ឍន៍គម្រោង |
| អង្គការសុវណ្ណភូមិ | | | មាន | មាន | មាន | | ការវាយតម្លៃសាលាគំរូក្នុងខេត្តស្ទឹងត្រែង |
| អង្គការពន្លឺកម្ពុជា | | 1500 | 2500 | 1500 | 800-1000 | 1000 | |
| អង្គការគាំទ្រការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន | | | 313903.1 | | | 71407.98 | |
| អង្គការមណ្ឌលកុមារកំព្រាសំរាប់ក្មេងកម្ពុជា | | | | | | | |
| អង្គការជីវិតនៅកម្ពុជា | | | | | | | ការអនុវត្តគោលនយោបាយអប់រំ និងគុណភាពនៃការរៀន និងបង្រៀននៅសាលារដ្ឋ (រួមបញ្ចូលទាំងថ្នាក់បំប៉ន) |
| អង្គការ UWS កម្ពុជា | 40000 | 20000 | 30000 | បញ្ចូលជាមួយថវិកាបណ្តុះបណ្តាលគ្រូ | | | បែងចែកថវិកាសម្រាប់ការតាមដាន វាយតម្លៃ និងការរៀនសូត្រពីសកម្មភាពដែលពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពការអភិវឌ្ឍន៍សាលារៀន កុមារប្រឈមការបោះបង់ និងការចូលរួមរបស់សហគមន៍ |
| អង្គការអ្នកស្ម័គ្រចិត្តបំរើការងារនៅបរទេស | | | 50000 | | | | |
| អង្គការវីអ៊ូប៊ី | 150000 | 3000 | មិនទាន់ច្បាស់ | មិនទាន់ច្បាស់ | | | ការបង្រៀន និងការប្រឹក្សាគរុកោសល្យគណិតវិទ្យាថ្នាក់ដំបូង |
| អង្គការអប់រំពិភពលោក | 27887.14 | | 448598. 52 | | | | គម្រោងដើមគ្រា/ចុងគ្រាដើម្បីវាយតម្លៃការផ្លាស់ប្តូរសមត្ថភាពអំណានសិស្ស |
| អង្គការទស្សនៈពិភពលោក | | 5000 | មិនប្រាកដ | | | | ការផ្ទេរមុខងារអប់រំទៅថ្នាក់ស្រុកៈ ការប្រឈម និងផលប៉ះពាល់ |

## ឧបសម្ព័ន្ធ៣៖ ចំនួនNGOsជាសមាជិកPESWG តាមខេត្ត( ពីការធ្វើផែនទី )

| ខេត្ត | ឈ្មោះអង្គការ |
|---|---|
| បាត់ដំបង | អង្គការមណ្ឌលកុមារកំព្រាសំរាប់ក្មេងកម្ពុជា |
| | អង្គការទស្សនៈពិភពលោក |
| | អង្គការបណ្តុះបណ្តាលសហគមន៍ដើម្បីអភិវឌ្ឍន៍ |
| | អង្គការហ្វូដណេបឹីសកម្ពុជា |
| | អង្គការខ្មែរជំនាន់ថ្មី |
| | អង្គការកម្ពុជា ដើម្បីស្រាវជ្រាវ អភិវឌ្ឍន៍ និងអប់រំ |
| កំពង់ចាម | អង្គការសង្គ្រោះកុមារកម្ពុជា |
| | អង្គការមូលនិធិសិទ្ធិកុមារ |
| | អង្គការជនពិការអន្តរជាតិ |
| កំពង់ឆ្នាំង | អង្គការអប់រំពិភពលោក |
| | វិទ្យាស្ថានស្រាវជ្រាវត្រីកោណ ( IPEA Project ) |
| | អង្គការស៊ីប៉ា |
| កំពង់ស្ពឺ | អង្គការមូលនិធិសិទ្ធិកុមារ |
| | សមាគមន៍បណ្តុះកុមារ |
| | អង្គការសាលារៀនទន្សាយ |
| កំពង់ធំ | អង្គការអប់រំពិភពលោក |
| កំពត | អង្គការមូលនិធិសិទ្ធិកុមារ |
| | អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ |
| | អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា |
| | អង្គការអេពិកអាត |
| | អង្គការគម្រោងពុទ្ធិកបណ្ណាល័យកម្ពុជា |
| កណ្តាល | អង្គការមូលនិធិសិទ្ធិកុមារ |
| | អង្គការទស្សនៈពិភពលោក |
| | សមាគមសម្រាប់ជំនួយ និងសង្គ្រោះនៃប្រទេសជប៉ុន |
| | អង្គការសាលារៀនទន្សាយ |
| កែប | អង្គការអេពិកអាត |
| កោះកុង | អង្គការ UWS កម្ពុជា |
| ក្រចេះ | សមាគមគ្រួសារយើង |
| | អង្គការហ្វូដណេបឹីសកម្ពុជា |
| មណ្ឌលគិរី | អង្គការឃែរ |
| | អង្គការហ្វូដណេបឹីសកម្ពុជា |

| | |
|---|---|
| រាជធានីភ្នំពេញ | អង្គការមណ្ឌលកុមារកំព្រាសំរាប់ក្មេងកម្ពុជា |
| | អង្គការពន្លឺកម្ពុជា |
| | អង្គការវីវីអូប៊ី |
| | សមាគមន៍បណ្ដុះកុមារ |
| | អង្គការពង្រឹងយុវជនកម្ពុជា |
| | អង្គការមូលនិធិសិទ្ធិកុមារ |
| | អង្គការមិត្តសំឡាញ់ |
| | អង្គការមូលនិធិកុមារកម្ពុជា |
| | អង្គការហ្វូដណេប៊ីសកម្ពុជា |
| ព្រះវិហារ | អង្គការឌីវីវីអន្តរជាតិ |
| ពោធិ៍សាត់ | អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ |
| | សមាគមន៍បណ្ដុះកុមារ |
| ព្រៃវែង | អង្គការអប់រំពិភពលោក |
| | អង្គការពន្លឺកម្ពុជា |
| | Mennonite Central Committee ( MCC ) |
| រតនគិរី | អង្គការមូលនិធិសិទ្ធិកុមារ |
| | អង្គការអនុផលព្រៃឈើ |
| | អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា |
| | អង្គការសង្គ្រោះជនងាយរងគ្រោះកម្ពុជា |
| | អង្គការឃែរ |
| | សមាគមន៍បណ្ដុះកុមារ |
| | អង្គការស៊ីប៉ា |
| | អង្គការភ្លែនអន្តរជាតិអន្តរជាតិកម្ពុជា |
| | អង្គការ UWS កម្ពុជា |
| | អង្គការសហការគ្រប់ជ្រុងជ្រោយដើម្បីកម្ពុជា |
| សៀមរាប | អង្គការគាំទ្រការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន |
| | អង្គការមូលនិធិសិទ្ធិកុមារ (ម.ស.ក.) |
| | អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា |
| | អង្គការអប់រំពិភពលោក |
| | អង្គការអាហារសម្រាប់ជនស្រេកឃ្លានកម្ពុជា |
| | សមាគមគ្រួសារយើង |
| | សមាគមន៍បណ្ដុះកុមារ |
| | អង្គការទស្សនៈពិភពលោក |
| | អង្គការជីវិតនៅកម្ពុជា |

| | |
|---|---|
| | អង្គការស៊ីប៉ា |
| | អង្គការភ្លេនអន្តរជាតិអន្តរជាតិកម្ពុជា |
| ព្រះសីហនុ | សមាគមន៍បណ្ដុះកុមារ |
| ស្ទឹងត្រែង | អង្គការមូលនិធិសិទ្ធិកុមារ |
| | អង្គការអនុផលព្រៃឈើ |
| | អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា |
| | អង្គការសុវណ្ណភូមិ |
| | អង្គការភ្លេនអន្តរជាតិអន្តរជាតិកម្ពុជា |
| ស្វាយរៀង | អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា |
| | អង្គការអប់រំពិភពលោក |
| | វិទ្យាស្ថានស្រាវជ្រាវត្រីកោណ ( IPEA Project ) |
| | អង្គការជំនួយជនបទ |
| តាកែវ | អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា |
| ត្បូងឃ្មុំ | សមាគមគ្រួសារយើង |

## ឧបសម្ព័ន្ធ៤៖ ការបណ្តុះបណ្តាល និងការបំប៉នសមត្ថភាព

| ឈ្មោះអង្គការ/ស្ថាបន | តើអង្គការ/ស្ថាបនរបស់អ្នកមានផែនការក្នុងការបណ្តុះបណ្តាល និងបំប៉នងសមត្ថភាពបុគ្គលិកទាក់ទងនឹងវិស័យអប់រំដែរឬទេ ? | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ផ្នែកគរុកោសល្យ | មុខជំនាញជាក់លាក់ | សមាហរណកម្មបច្ចេកវិទ្យា | ការអប់រំបរិយាប័ន្ន | ការពិនិត្យ និងវាយតម្លៃ | ការគ្រប់គ្រងថ្នាក់រៀន | ការអភិវឌ្ឍន៍វិជ្ជាជីវៈ និងភាពជាអ្នកដឹកនាំ | សិក្សាសង្គម និងអារម្មណ៍ (SEL) | សិក្សាវប្បធម៌ និងសង្គម | ការចូលរួមរបស់អាណាព្យាបាល និងសហគមន៍ | ការគ្រប់គ្រងសាលារៀន | ការណែនាំគរុកោសល្យ | ការបណ្តុះបណ្តាលគ្រូបង្គោល/បណ្តុះបណ្តាលគ្រូបង្គោលស្នូល | ការអប់រំពិសេស | ផ្សេងៗ |
| អង្គការសកម្មភាពដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជនបទកម្ពុជា (អារីដុក) | | មាន | មាន | មាន | | | | មាន | | មាន | | | មាន | | |
| សមាគមសម្រាប់ជំនួយ និងសង្គ្រោះនៃប្រទេសជប៉ុន | | | | មាន | | | មាន | | | | | | | | Inclusive Career for people with disabilities |
| អង្គការសេរីភាពកម្ពុជាអូស្ត្រាលី | | | | | | | មាន | | | | | | មាន | | |
| សមាគមន៍បណ្តុះកុមារ | | មាន | | មាន | មាន | មាន | មាន | មាន | មាន | មាន | មាន | មាន | មាន | មាន | |
| អង្គការគម្រោងពុទ្ធិកបណ្ណាល័យកម្ពុជា | | | | | | | | | | មាន | | | | | |
| អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា | មាន | មាន | | | | | | | | | មាន | | | | |
| អង្គការមូលនិធិកុមារកម្ពុជា | មាន | មាន | មាន | | មាន | មាន | មាន | | | មាន | មាន | មាន | | | |
| អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ | | | | | | មាន | មាន | | | មាន | | | មាន | | |
| អង្គការកម្ពុជា ដើម្បីស្រាវជ្រាវ អភិវឌ្ឍន៍ និងអប់រំ | | | | | | មាន | មាន | | | មាន | | | មាន | | |
| អង្គការឃែរ | | មាន | មាន | មាន | មាន | | មាន | | មាន | | | | មាន | មាន | |
| អង្គការមូលនិធិសិទ្ធិកុមារ | | មាន | | | មាន | | | | | | | | មាន | | 1. Child Rights and Child participation.<br>2. Child Protection Guideline<br>3. Photos, video shooting and producing. |
| អង្គការបណ្តុះបណ្តាលសហគមន៍ដើម្បីអភិវឌ្ឍន៍ | | មាន | | មាន | មាន | | មាន | មាន | | មាន | មាន | | មាន | | |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា | | | មាន | | | | មាន | | | | | | មាន | | |
| អង្គការឌីវីអីអន្តរជាតិ | | | | | | | | | មាន | | | | | | Adult Learning Education |
| អង្គការពង្រឹងយុវជនកម្ពុជា | មាន | | មាន | | | មាន | មាន | | | | | | | | |
| អង្គការអេពិកអាត | | មាន | មាន | មាន | មាន | មាន | មាន | | មាន | មាន | | | | មាន | |
| អង្គការអាហារសម្រាប់ជនស្រេកឃ្លានកម្ពុជា | | មាន | | | | | | | | មាន | មាន | មាន | មាន | | |
| អង្គការហ្វូដណេបឺសកម្ពុជា | | | | | មាន | | | | | មាន | | | | | |
| អង្គការជនពិការអន្តរជាតិ | | | | មាន | | | | | | មាន | | | មាន | | Project Implement Management |
| អង្គការសហការគ្រប់ជ្រុងជ្រោយដើម្បីកម្ពុជា ( ស.គ.ក ) | | មាន | | មាន | មាន | | មាន | | មាន | មាន | | | មាន | | Support Staff to learning by doing and job reflection |
| អង្គការផ្កាយសមុទ្រកម្ពុជា | | មាន | មាន | | | មាន | | | | មាន | | | | | Inviting outside NGO, international specialist in Education to provide training to the teachers |
| អង្គការខេមរអភិវឌ្ឍន៍សហគមន៍ | មាន | | | មាន | | | | | | | | | | មាន | |
| អង្គការខ្មែរជំនាន់ថ្មី | មាន | មាន | មាន | មាន | មាន | មាន | មាន | | | មាន | | | មាន | មាន | |
| សមាគមយុវជនខ្មែរ | | | | | | | មាន | | | | | | មាន | | |
| អង្គការគ្រួសារថ្មី | | | | មាន | | | មាន | មាន | | | | | | | |
| សមាគមគ្រួសារយើង | មាន | មាន | | | | មាន | | | | | | មាន | | | |
| អង្គការឡូធឺសអៅរ៍ចខេមបូឌា | | | | | | | មាន | | | | | | | | |
| Mennonite Central Committee | | | | មាន | | មាន | | | | មាន | | | មាន | | |
| អង្គការមិត្តសំឡាញ់ | មាន | មាន | មាន | | មាន | មាន | មាន | មាន | មាន | មាន | | មាន | មាន | | |
| អង្គការអនុផលព្រៃឈើ | | | | | | មាន | មាន | មាន | | មាន | | | មាន | | |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| អង្គការប្រតិបត្តការកុមារកម្ពុជា | | | | | | | | | | | មាន | | | | |
| អង្គការភ្លេនអន្តរជាតិអន្តរជាតិកម្ពុជា | | | | | | | មាន | | | | | | | | |
| អង្គការIPE&D | មាន | | | | មាន | | មាន | មាន | | មាន | | | មាន | | |
| អង្គការសាលារៀនទន្សាយ | មាន | មាន | មាន | មាន | | | | | | | | | មាន | មាន | |
| វិទ្យាស្ថានស្រាវជ្រាវត្រីកោណ | | | | | | | | | | មាន | | | មាន | | |
| វិទ្យាស្ថានស្រាវជ្រាវត្រីកោណ (IPEA Project) | មាន | | | មាន | មាន | មាន | មាន | | | មាន | មាន | មាន | មាន | មាន | |
| អង្គការរួមធ្វើដែកម្ពុជា | មាន | | | | | មាន | | | | | | មាន | មាន | | |
| អង្គការជំនួយជនបទ | | | | មាន | | | មាន | | | | | | | | |
| អង្គការសង្គ្រោះកុមារកម្ពុជា | មាន | | មាន | មាន | | | | មាន | | | | | មាន | | |
| អង្គការសង្គ្រោះជនងាយរងគ្រោះកម្ពុជា | | មាន | មាន | មាន | មាន | | មាន | មាន | មាន | មាន | មាន | | | | |
| អង្គការស៊ីប៉ា | មាន | មាន | មាន | | មាន | | មាន | | | | | | | | |
| អង្គការសុវណ្ណភូមិ | | | | | | មាន | | | | | មាន | | | | |
| អង្គការពន្លឺកម្ពុជា | | | មាន | មាន | មាន | | មាន | មាន | | មាន | | | មាន | | |
| អង្គការគាំទ្រការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន | មាន | | មាន | | មាន | | មាន | | | | មាន | មាន | មាន | | |
| មណ្ឌលកុមារកំព្រាសំរាប់ក្មេងកម្ពុជា | | | | | | | | | | មាន | | | | | |
| អង្គការជីវិតនៅកម្ពុជា | | មាន | | | | | | | | | | | មាន | | |
| អង្គការ UWS កម្ពុជា | មាន | | | មាន | មាន | | | | | | | | មាន | | |
| អង្គការអ្នកស្ម័គ្រចិត្តបំរើការងារនៅបរទេស | | | | | | | មាន | | | | | | មាន | | |
| អង្គការវីអឺប៊ី | មាន | មាន | មាន | | | មាន | មាន | | | | | មាន | | | |
| អង្គការអប់រំពិតពលោក | មាន | មាន | មាន | មាន | មាន | មាន | មាន | | មាន | មាន | មាន | មាន | មាន | | |
| អង្គការទស្សនៈពិភពលោក | | | | | មាន | | | | | | | | | | |

## ឧបសម្ព័ន្ធ៖ ឈ្មោះអង្គការដែលបានចូលរួមក្នុងសំណួរអង្កេត

| ល.រ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះជាភាសាខ្មែរ | ប្រភេទអង្គការ |
|---|---|---|---|
| 1 | Action for Rural Economic Development of Cambodia (Aredoc) | អង្គការសកម្មភាពដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជនបទកម្ពុជា (អារីដុក) | អង្គការក្នុងស្រុក |
| 2 | Association for Aid and Relief, Japan | សមាគមសម្រាប់ជំនួយ និងសង្គ្រោះនៃប្រទេសជប៉ុន | អង្គការអន្តរជាតិ |
| 3 | AusCam Freedom Project | អង្គការសេរីភាពកម្ពុជាអូស្រ្តាលី | អង្គការអន្តរជាតិ |
| 4 | Bandos Komar Association | សមាគមន៍បណ្តុះកុមារ | សមាគមន៍ |
| 5 | Buddhist Library Cambodia Project (BLCP) | អង្គការគម្រោងពុទ្ធិកបណ្ណាល័យកម្ពុជា | អង្គការក្នុងស្រុក |
| 6 | Cambodian Children's Advocacy Foundation Organization | អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា | អង្គការក្នុងស្រុក |
| 7 | Cambodian Children's Fund | អង្គការមូលនិធិកុមារកម្ពុជា | អង្គការក្នុងស្រុក |
| 8 | Cambodian Organization for Children and Development | អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ | អង្គការក្នុងស្រុក |
| 9 | Cambodian Organization for Research Development and Education | អង្គការកម្ពុជា ដើម្បីស្រាវជ្រាវ អភិវឌ្ឍន៍ និងអប់រំ | អង្គការក្នុងស្រុក |
| 10 | CARE Cambodia | អង្គការឃែរ | អង្គការអន្តរជាតិ |
| 11 | Child Rights Foundation (CRF) | អង្គការ មូលនិធិសិទ្ធិកុមារ (ម.ស.ក.) | អង្គការក្នុងស្រុក |
| 12 | Child Rights Foundation Organization | អង្គការមូលនិធិសិទ្ធិកុមារ | អង្គការក្នុងស្រុក |
| 13 | Community Training Organization for Development (CTOD) | អង្គការបណ្តុះបណ្តាលសហគមន៍ដើម្បីអភិវឌ្ឍន៍ | អង្គការក្នុងស្រុក |
| 14 | CRC-Cambodia | អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា | សម្ព័ន្ធ/សមាជិកភាព |
| 15 | DVVI | អង្គការឌីវីវីអន្តរជាតិ | អង្គការអន្តរជាតិ |
| 16 | Empowering Youth in Cambodia | អង្គការពង្រឹងយុវជនកម្ពុជា | អង្គការក្នុងស្រុក |
| 17 | Epic Arts | អង្គការអេពិកអាត | អង្គការអន្តរជាតិ |
| 18 | Food for the Hungry Cambodia (FH Cambodia) | អង្គការអាហារសម្រាប់ជនស្រេកឃ្លានកម្ពុជា | អង្គការអន្តរជាតិ |
| 19 | Good Neighbors Cambodia | អង្គការហ្គូដណេប៊ឺសកម្ពុជា | អង្គការអន្តរជាតិ |
| 20 | Humanity & Inclusion | អង្គការជនពិការអន្តរជាតិ | អង្គការអន្តរជាតិ |
| 21 | Integral Cooperation Cambodia organization (ICC) | អង្គការសហការគ្រប់ជ្រុងជ្រោយដើម្បីកម្ពុជា (ស.គ.ក) | អង្គការក្នុងស្រុក |
| 22 | ISF Cambodia (Indochina Starfish Foundation) | អង្គការផ្កាយសមុទ្រកម្ពុជា | អង្គការអន្តរជាតិ |

| | | | |
|---|---|---|---|
| 23 | Khmer Community Development | អង្គការខេមអេភិវឌ្ឍន៍សហគមន៍ | អង្គការក្នុងស្រុក |
| 24 | Khmer New Generation Organization | អង្គការខ្មែរជំនាន់ថ្មី | អង្គការក្នុងស្រុក |
| 25 | Khmer Youth Association | សមាគមយុវនជនខ្មែរ | សមាគមន៍ |
| 26 | Krousar Thmey Organization | អង្គការគ្រួសារថ្មី | អង្គការក្នុងស្រុក |
| 27 | Krousar Yoeung Association | សមាគមគ្រួសារយើង | សមាគមន៍ |
| 28 | Lotus Outreach Cambodia | អង្គការឡូធឹសអៅរីចខេមបូឌា | អង្គការក្នុងស្រុក |
| 29 | Mennonite Central Committee (MCC) | N/A | អង្គការអន្តរជាតិ |
| 30 | Mith Samlanh | អង្គការមិត្តសំឡាញ់ | អង្គការក្នុងស្រុក |
| 31 | Non-Timber Forest Products (NTFP) | អង្គការអនុផលព្រៃឈើ | អង្គការក្នុងស្រុក |
| 32 | Operation Enfants du Cambridge (OEC) | អង្គការប្រតិបត្តការកុមារកម្ពុជា | អង្គការក្នុងស្រុក |
| 33 | Plan International Cambodia | អង្គការភ្លែនអន្តរជាតិអន្តរជាតិកម្ពុជា | អង្គការអន្តរជាតិ |
| 34 | Planete Enfants & Développement | អង្គការPE&D | អង្គការអន្តរជាតិ |
| 35 | Rabbit School Organization | អង្គការសាលារៀនទន្សាយ | អង្គការក្នុងស្រុក |
| 36 | Research Triangle Institute | វិទ្យាស្ថានស្រាវជ្រាវត្រីកោណ | អង្គការអន្តរជាតិ |
| 37 | Research Triangle Institute (RTI) (IPEA Project) | វិទ្យាស្ថានស្រាវជ្រាវត្រីកោណ ( IPEA Project ) | អង្គការអន្តរជាតិ |
| 38 | Room to Read Cambodia | អង្គការរូមធូរីដកម្ពុជា | អង្គការអន្តរជាតិ |
| 39 | Rural Aid Organization | អង្គការជំនួយជនបទ | អង្គការក្នុងស្រុក |
| 40 | Save the Children Cambodia | អង្គការសង្គ្រោះកុមារកម្ពុជា | អង្គការអន្តរជាតិ |
| 41 | Save Vulnerable Cambodians | អង្គការសង្គ្រោះជនងាយរងគ្រោះកម្ពុជា | អង្គការក្នុងស្រុក |
| 42 | SIPAR | អង្គការស៊ីប៉ា | អង្គការអន្តរជាតិ |
| 43 | Sovann Phoum | អង្គការសុវណ្ណភូមិ | អង្គការក្នុងស្រុក |
| 44 | Sunshine Cambodia Organization | អង្គការពន្លឺកម្ពុជា | អង្គការក្នុងស្រុក |
| 45 | Teacher Development Support Organization | អង្គការគាំទ្រការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន | អង្គការអន្តរជាតិ |
| 46 | The Orphanage for Cambodian Children Organization (OCCO) | អង្គការមណ្ឌលកុមារកំព្រាសំរាប់ក្មេងកម្ពុជា | អង្គការក្នុងស្រុក |

| | | | |
|---|---|---|---|
| 47 | This Life Cambodia | អង្គការជីវិតនៅកម្ពុជា | អង្គការអន្តរជាតិ |
| 48 | UWS Cambodia | អង្គការ UWS កម្ពុជា | អង្គការអន្តរជាតិ |
| 49 | Voluntary Service Overseas (VSO) | អង្គការអ្នកស្ម័គ្រចិត្តបំរើការងារនៅបរទេស | អង្គការអន្តរជាតិ |
| 50 | VVOB | អង្គការវីវីអូប៊ី | អង្គការអន្តរជាតិ |
| 51 | Word Education | អង្គការអប់រំពិភពលោក | អង្គការអន្តរជាតិ |
| 52 | World Vision International-Cambodia | អង្គការទស្សនៈពិភពលោក | អង្គការអន្តរជាតិ |

រៀបចំដោយ៖ អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
ខែមីនា ឆ្នាំ២០២៤
អសយដ្ឋាន៖ ផ្ទះលេខ១១០ ផ្លូវ២BT សង្កាត់បឹង ទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ
អ៊ីម៉ែល៖ info@nepcambodia.org
វែបសាយ៖ https://nepcambodia.org
គេហទំព័រហ្វេសបុក៖ NEP Cambodia - ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល